Formation, Dialogue, Cooperation

# អ្នកនាំសារ
# The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១០ សម្រាប់ខែវិច្ឆិកា ឆ្នាំ២០១៧ លក់តម្លៃ ១០០០រៀល

លេខ ១០៦



## ពលរដ្ឋកម្ពុជាមួយចំនួនអះអាងថា ថ្ងៃទី០៩ ខែវិច្ឆិកា ជាថ្ងៃនៃការចងចាំដូចថ្ងៃ០៧ ខែមករា ដែរ

Formation, Dailouge, Cooperation

ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ

Tel/Fax : (855) 23 224 120

Email : csccambodia@gmail.com / Website : www.catholiccambodia.org

Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org

https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh

ចាងហ្វាង : លោក លី សុវណ្ណា

សេចក្ដីប្រកាសលេខ: ១០១ ព.ម.ប្រ.ក/ ០៥-កុម្ភៈ-២០១៤

# មីហឹរហូរដូចទឹក អាហារថ្មីដែលពលរដ្ឋកម្ពុជាកំពុងតែល្បីទៅសាកល្បង

សរសៃទន់ស្វិត មានភាពហឹរខ្លាំង ដែលបណ្តុំដោយ រសជាតិប្លែកពីក្រៅប្រទេស ជាអាហារមួយដែលប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញ និយមជាពិសេស យុវវ័យសម័យថ្មី បុរស និងស្ត្រី និស្សិត សិស្ស បុគ្គលិក មន្ត្រីរាជការ និយមភ្លក់រសជាតិក្តៅៗយ៉ាងរីករាយ។

ដោយមានទីតាំងស្ថិតនៅជិតនឹងសាលាសន្ធរម៉ុក តាមបណ្តោយផ្លូវកម្ពុជាក្រោម នាកន្លែងដែលគេ ឃើញមានរថយន្ត ម៉ូតូចតតម្រៀបគ្នា នៅពីមុខហាងអាហារឯក-ជនមួយដែលជាអាហារបែប តាមដងផ្លូវនោះគឺ ជាទីតាំងនៃហាងអាហារ មីហឹរ ៧កម្រិត។

មីហឹរ៧កម្រិត បើស្តាប់មើលទៅនោះ មិនមែនជា ម្ហូបអាហារ កម្ពុជាយើងនោះទេ។ វាគឺជាអាហារថ្មីមួយ ដែលទើបតែមកដល់ និងកំពុងមានការគាំទ្រពីសំណាក់យុវវ័យ ប្រហែលជាមិនលើសពី១ឆ្នាំ នេះប៉ុណ្ណោះ។

មីហឹរ៧កម្រិត ជាឈ្មោះនៃហាងដែលមានសាខា ជាច្រើននៅទូទាំងប្រទេស ជាពិសេសរាជធានីភ្នំពេញ ត្រូវបានល្បីខាងរសជាតិ នៃភាពហឹររបស់គ្រឿងផ្សំដោយភាគច្រើនសុទ្ធតែប្រើ ម្ទេស ដែលមនុស្សវ័យចំណាស់មានភាពខ្លាច នឹងរសជាតិហឹរបែបនេះ ដោយសារពួកគាត់មិនដែលបានធ្លាប់ជួបពីមុន តែសម្រាប់យុវវ័យវិញ តែងតែសរសើរមិនដាច់ពីមាត់នៃរសជាតិប្រភេទនេះ។

មីហឹរ៧កម្រិតនេះ មានរសហឹរចាប់ពីកម្រិតទី១ ទៅដល់ទី៧ ដែលរសជាតិហឹរនេះ ចាប់ផ្តើមបន្តិចម្តងៗ ពី១ដល់៧ ដែលអាចធ្វើឲ្យអ្នកទទួលទានបែកញើសជូតថ្ងាស និងមើលមុខគ្នាទៅវិញទៅមក ប្រកបដោយភាព សប្បាយ ព្រមទាំងថតរូបបង្ហោះនៅលើបណ្តាញសង្គមរបស់ខ្លួនរៀងៗខ្លួន។

បើតាមស្តាប់មើលទៅ មីប្រភេទនេះ សុទ្ធតែប្រើម្ទេសទាំងអស់ហើយមើលទៅបានជារសជាតិហឹរបែបនេះ តែមិនដូចជាអ្វីដែលគិតទាំងអស់នោះទេ មីប្រភេទនេះ ប្រើនូវជាតុផ្សំច្រើនប្រភេទផ្សេងៗគ្នាខុសប្លែក ពីកម្រិតទី១ ដល់ កម្រិតទី៧ និងប្រភេទសាច់សម្រាប់បន្ថែមរសជាតិក៏ផ្សេងៗគ្នា។

លោក ប្រុស ឡា ដែលជាអ្នកមើលការខុសត្រូវលើហាងមីហឹរ៧កម្រិតខាងលើ បានថ្លែងប្រាប់ថា ហាង មីហឹរ៧ កម្រិតនេះ គឺ បានទិញសិទ្ធិពីកូរ៉េមកបើកបន្តនៅភ្នំពេញ និងទៅបើកនៅតាមបណ្តាខេត្តនានា ដូចជា កំពង់ចាម បាត់ដំបង ។

លោក ប្រុស ឡា បានបន្តទៀតថា សព្វថ្ងៃអាជីវកម្មរបស់លោក ពិតជាមានភាពមមាញឹកយ៉ាងខ្លាំង ដែលធ្វើឲ្យលោកសឹងរកពេលសម្រាកមិនបាន និងដោយហាងទាំងអស់គឺចាប់ដំណើរការពីម៉ោង ៩ព្រឹករហូតដល់ម៉ោង ១០យប់ និងពីថ្ងៃច័ន្ទដល់ថ្ងៃអាទិត្យ ៧ថ្ងៃក្នុងមួយសប្តាហ៍។

ទាក់ទិននឹងអាហារថ្មីនេះ កញ្ញា ហេង ស្រីពៅ ដែលបានមកញ៉ាំនៅទីនេះ ជាមួយនឹង អនាគតគូដណ្តឹង ព្រមទាំងគ្រួសារ បានថ្លែងប្រាប់ថា កញ្ញា និយមមកញ៉ាំមីហឹរនេះជារៀងរាល់ពេលដែល គូដណ្តឹងកញ្ញា ទំនេរពីការងារជាមន្ត្រីរាជការ។ ចំណែករសជាតិវិញគឺ កញ្ញា ញ៉ាំបានត្រឹមកម្រិតទី២តែប៉ុណ្ណោះដោយសារតែ រូបកញ្ញាមិនចូលចិត្តញ៉ាំហឹរ។

ផ្ទុយពី កញ្ញា កូនកាត់ចិនរូបនេះ លោក កូឌ (ឈ្មោះហៅក្រៅ) ដែលជាគូដណ្តឹង បានលើកឡើងថា លោកពិតជាចូលចិត្ត រសជាតិ ក្តៅហឹរបែបនេះ ដោយសារតែលោក ជាមនុស្សចូលចិត្តញ៉ាំហឹរ។ លោក ឧស្សាហ៍នាំក្រុមគ្រួសារមកទទួលទាននៅទីនេះណាស់ ដោយសារតែតម្លៃសមរម្យអាចទទួលយកបាន និងនៅជិតផ្ទះរបស់លោកផ្ទាល់។

ចំណែកលោក ដារា ដែលជាពលរដ្ឋរស់នៅខេត្តកោះកុង បានរៀបរាប់ថា លោក តែងតែមកញ៉ាំមីហឹរនៅទីនេះ តែលោក ទទួលទានបានត្រឹមតែកម្រិតទី៣តែប៉ុណ្ណោះ ដោយសារតែវាមានរសជាតិហឹរខ្លាំង។

យុវនារីមួយរូបទៀត កញ្ញា ហ្គិច បានថ្លែងថា កញ្ញាអាចញ៉ាំបានតែកម្រិតទី២ទេ បើទោះបីជាកញ្ញាជាអ្នកខេត្តកោះកុង ដែលចូលចិត្តហឹរក៏ដោយ។

លោក វិទូ បានរៀបរាប់ថា នេះជាលើកទី១ សម្រាប់លោក ដូច្នេះលោកញ៉ាំកម្រិតទី១សិន ដើម្បីសាកល្បង តែប្រសិនបើលោកមកលើកក្រោយនឹង ដំឡើងកម្រិតម្តង១ៗ។

លោក វិទូ បានបន្តថា បន្ទាប់ពីសាកល្បងហើយនោះ លោកមានអារម្មណ៍ថា មិនសូវហឹរនោះទេ លោកចំឡែកដែរ ប្រសិនបើរជារសជាតិតែមួយ ម្តេចក៏សាខាខ្លះរសជាតិហឹរខ្លាំង និងសាខាខ្លះទៀតមិនសូវហឹរនោះទេ ដែលពេលនេះលោកញ៉ាំកម្រិតទី៣ ប្រសិនបើលោកមកលើកក្រោយលោក និងយកកម្រិតខ្ពស់ជាងនេះ ឬអាចដល់កម្រិតកំពូលតែម្តង។

ប្រសិនបើស្តាប់ចំណាប់អារម្មណ៍របស់អតិថិជន បន្ទាប់ពីញ៉ាំហើយវិញ កញ្ញា ហ្គិច បានបន្តថា រសជាតិពិបាកក្នុងការនិយាយណាស់ លុះត្រាតែអ្នកទាំងអស់គ្នាមកញ៉ាំទើបដឹង ព្រោះថា អ្នកខ្លះចូលចិត្តហឹរ អ្នកខ្លះមិនចូលចិត្តហឹរនោះទេ ចំណែករូបនាងពេលញ៉ាំហើយ គឺចង់ហូរទឹកភ្នែកដែលគេតែងហៅថា មីហឹរហូរដូចទឹក។

តែក៏មានមតិខ្លះបានផ្ទុយពីការគាំទ្រខ្លះដែរ លោក សីហារ បានថ្លែងថា លោកមិនចូលចិត្តមីហឹរនេះទេ ដោយសារតែរសជាតិខុសប្លែកពីរសជាតិដែលប្រជាជនខ្មែរនិយមចូលចិត្ត និងម្យ៉ាងវាមិនមែនជាម៉ាកដែលខ្មែរយើងបង្កើតឡើងនោះទេ។

លោក សីហារ បានបន្តថា ប្រសិនបើខ្មែរយើង គាំទ្រផលិតផលខ្មែរយើងវិញល្អជាង យើងមានគុយទាវ នំបញ្ចុក ដែលមានរសជាតិឆ្ងាញ់ជាងនេះ ចុះហេតុអ្វីបានជាយើងមិនសូវគាំទ្រ និងម្យ៉ាងទៀតខ្ញុំយល់ថា មិនឆ្ងាញ់ជាងរបស់ខ្មែរនោះទេ។

មីហឹរនេះ មិនមែនជារបស់ដែលទើបនឹងបង្កើតក្នុងរាជធានីនោះទេ ក្នុងនោះប្រជាពលរដ្ឋអាចមានជម្រើសក្នុងការជ្រើសរើសយក អាហារផ្សេងៗទៀតជាច្រើនមុខ ដូចជា អាហារសម្រន់ ភីសារ នំប៉ុង ជើងមាន់ជ្រក់ជាដើម ដែលអាចសុទ្ធតែរកបាននៅតាមបណ្តោយផ្លូវក្នុងហាងក្នុងរាជធានី៕

*ដោយ សុផានិត*



ថតដោយៈ លី សុវណ្ណា

# តម្លៃម្រេចដាំក្បាលចុះដោយសារបរិមាណម្រេចលើសតម្រូវការប៉ុន្តែម្រេចកំពតមានស្ថានភាពផ្ទុយគ្នា



ថតដោយៈ សម្បត្តិ

ខណៈពេលដែលបរិមាណបង្កបង្កើនផលនៃផលិតផលម្រេចកម្ពុជាបានកើនឡើងជាលំដាប់រៀងរាល់ឆ្នាំ នៅឆ្នាំ២០១៧នេះ តម្លៃម្រេចបានធ្លាក់ដាំក្បាលចុះគួរឲ្យព្រួយបារម្ភ ហើយអ្នកជំនាញផ្នែកកសិកម្មកម្ពុជាបានសន្និដ្ឋានថា មូលហេតុដែលតម្លៃម្រេចនៅកម្ពុជា ដាំក្បាលចុះ ដោយសារការផ្គត់ផ្គង់ច្រើនហួសតម្រូវការ និងការរឹតបន្តឹងគុណភាពប៉ុន្តែសម្រាប់ម្រេចកំពតដែលជាផលិតផលសម្គាល់ភូមិសាស្ត្រមួយរបស់កម្ពុជានៅតែមានតម្រូវការនៅតែមានតម្លៃនៅក្នុងទីផ្សារនាំចេញ។

ផលិតផលម្រេចរបស់ប្រទេសកម្ពុជាបានកើនឡើងជាលំដាប់ចាប់តាំងពីឆ្នាំ២០១៣មកម្ល៉េះ។ បើតាមរបាយការណ៍ចុងក្រោយរបស់ក្រសួងកសិកម្មបានបង្ហាញថា ការផលិតម្រេចក្នុងឆ្នាំ ២០១៦ បានកើនឡើង ដល់ ២០.០៥៤ តោន ខ្ពស់ជាង ៨ដង បើធៀបនឹងឆ្នាំ២០១៣។ ប៉ុន្តែទោះជាយ៉ាងណា បើតាមរបាយការណ៍របស់ក្រសួងកសិកម្មផលិតផលម្រេចកម្ពុជាបានធ្លាក់ថ្លៃពី ១០,៥ដុល្លារ ក្នុងមួយគីឡូក្រាម នៅឆ្នាំ២០១៤ មកត្រឹម ៣,៤ដុល្លារ ក្នុងមួយគីឡូក្រាម នៅឆ្នាំ ២០១៧ប៉ុន្តែម្រេចកំពត គឺមានតម្លៃខុសពីនេះរាប់សិបដង។

លោក ភី ចាន់តារា អ្នកដាំម្រេចម្នាក់នៅស្រុកអង្គស្នួល បានឲ្យដឹងថាតម្លៃម្រេចធ្លាក់ថ្លៃខ្លាំងនៅឆ្នាំនេះ។ លោក ភី ចាន់តារា បានថ្លែងថា "ម្រេចខ្ញុំឆ្នាំទៅអត់ទាន់បានផលល្អទេ ទើបតែបានឆ្នាំហ្នឹង ហើយឆ្នាំនេះបានផលហើយ តែតម្លៃវាធ្លាក់ថ្លៃពេកធ្លាក់ថ្លៃខុសពីឆ្នាំទៅជាងពាក់កណ្ដាលឆ្នាំទៅបានពី៣៥.០០០ពាន់រៀល ទៅ ៤០.០០០រៀល តែឆ្នាំនេះបានមួយគីឡូមួយគីឡូ១៤.០០០ រៀល ឬក៏មួយ ១៥.០០០ រៀល ទេ"។

លោក ភី ចាន់តារា បានបន្តថា "បើសិនជាអ្នកដាំផ្សេងៗ បានទិន្នផលខ្ពស់ ឬក៏អី វាអត់សំខាន់ទេ សំខាន់តម្លៃទូទៅដែលខ្ញុំបានដឹងពីប្រភេទ ម្រេចនៅខេត្តជំនាលខាងកំពង់ចាម ក្រចេះ ឬខាងត្បូងឃ្មុំ វាតម្លៃប្រហាក់ប្រហែលគ្នាទាំងអស់។ លើកលែងតែម្រេចនៅខាងមេមត់ទេ ដែលនៅមានតម្លៃល្អ ១គីឡូ ១៥ដុល្លារ"។

លោក ភី ចាន់តារា សូមឲ្យរដ្ឋាភិបាលធានាដល់ទីផ្សារម្រេចរបស់ប្រជាកសិករដោយមិនចាំបាច់ពឹងផ្អែកលើដង្ហើមឈ្មួញមកពីប្រទេសជិតខាងដូចជាឈ្មួញមកពីប្រទេសវៀតណាមជាដើម។

កាលពីពេលថ្មីៗនេះលោក យង់ សាំងកុមារ ទីប្រឹក្សាអង្គការសេដាក ដែលជាអង្គការជំរុញកិច្ចអភិវឌ្ឍន៍កសិកម្មល្បីឈ្មោះមួយនៅកម្ពុជា បានលើកឡើងតាមបណ្ដាញសង្គមថាការធ្លាក់តម្លៃម្រេចនៅកម្ពុជាដោយសារការផ្គត់ផ្គត់ផលិតផលម្រេចច្រើនហួសលើសតម្រូវការ និងការរឹតបន្តឹងផ្នែកគុណភាពពីសំណាក់សហភាពអឺរ៉ុប និងសហរដ្ឋអាមេរិកជាដើម។ សហភាពអឺរ៉ុប និងអាមេរិកដែលជាទីផ្សារសំខាន់មួយសម្រាប់ផលិតផលមាសខ្មៅកម្ពុជានេះ។

លោក យង់ សាំងកុមារ បានថ្លែងថា អ្វីដែលជាមូលហេតុសំខាន់នៃការធ្លាក់ចុះនៃតម្លៃម្រេច គឺទីមួយ ការកើនឡើងនៃការផ្គត់ផ្គង់ និងការផលិតម្រេច ជាពិសេសនៅប្រទេសវៀតណាម កើនឡើងដល់ប្រមាណ ២សែនតោន។ ដោយឡែកម្ពុជាយើង ការផលិតម្រេច ក៏ការកើនឡើងដែររហូតដល់ប្រហែលជា ២ម៉ឺនតោន ហើយនេះបើតាមការប៉ាន់ស្មានរបស់ក្រសួងកសិកម្ម។ ហើយអ្វីដែលសំខាន់មួយទៀតនោះគឺទីផ្សារជាពិសេសអ្នកទិញម្រេច សហភាពអឺរ៉ុប ក៏ដូចជាសហរដ្ឋអាមេរិក គេចាប់ផ្ដើមរឹតបន្តឹងនូវបញ្ហាគុណភាព"។

លោក យង់ សាំងកុមារ បានបន្តថា ដើម្បីឆ្លើយតបនូវបញ្ហាគុណភាពផលិតផលម្រេចប្រទេសមួយចំនួន ជាពិសេសប្រទេសវៀតណាម បានកែលម្អនូវគុណភាពរបស់ម្រេចក៏ដូចជាបានត្រៀមខ្លួន ដើម្បីចូលទីផ្សាររបស់អឺរ៉ុប។ ហើយប្រទេសកម្ពុជាគួរកុំរំពឹងលើឈ្មួញមកពីប្រទេសវៀតណាម។

លោក យង់ សាំងកុមារ បានបន្តថា "ដោយឡែកនៅកម្ពុជាយើងហាក់មានការឆ្លើយតបយឺតយ៉ាវ ហើយណាមួយទីផ្សារយើងមានការពឹងពាក់ខ្លាំងតាមរយៈ ប្រទេសវៀតណាម។ ហើយខ្ញុំយល់ឃើញថា យើងមិនគួរទុកឱ្យស្ថានភាពនេះបន្តទៀតទេ ជាពិសេសរដ្ឋាភិបាលគួរតែលូកដៃដើម្បីជួយអន្តរាគមន៍ក្នុងវិស័យនេះ"។

ដើម្បីកែលំអរតម្លៃម្រេចអ្នកជំនាញបានជំរុញឲ្យភាគីពាក់ព័ន្ធត្រូវជួយដល់អ្នកដាំម្រេចពីរបៀបរៀបចំម្រេចឲ្យក្លាយទៅជាម្រេចស្អាត និងម្រេចល្អ ទៅតាមទីផ្សារដែលចង់បាន។ បន្ថែមពីនេះគួរត្រូវរៀបចំឲ្យមានកន្លែងកែច្នៃម្រេចដោយខ្លួនឯងនៅក្នុងប្រទេសដើម្បីឱ្យបានម្រេចដែលមានគុណភាពល្អសម្រាប់នាំចេញ។ ជាមួយគ្នាក៏ត្រូវធ្វើការគាំទ្រឲ្យមានក្រុមហ៊ុនដែលធ្វើការទៅលើទីផ្សារម្រេចផ្ទាល់ទៅទីផ្សារពិភពលោក ជាពិសេសទីផ្សារអឺរ៉ុប និងទីផ្សារអាមេរិក។ ជាងនេះទៅទៀតគួរមានការគាំទ្រផ្នែកមូលធន ដើម្បីបង្កើនទុនជាប្រាក់កម្ចីដែលមានការប្រាក់ទាប ហើយមានរយៈពេលវែងជូនទៅដល់អ្នកដាំម្រេចក៏ដូចជាក្រុមហ៊ុន ដើម្បីពង្រីកការវិនិយោគរបស់ពួកគេ។

លោក ហ៊ាន វណ្ណហាន អគ្គនាយក នៃអគ្គនាយកដ្ឋានកសិកម្មបាន គូសបញ្ជាក់ថា តម្លៃម្រេចបានធ្លាក់ចុះប៉ុន្តែទំនងជាមិនបណ្ដាលមកពីគុណភាពម្រេចនោះទេ តែវាអាចពាក់ព័ន្ធនឹងរឿងវេចខ្ចប់ រឿងកែច្នៃ។

លោក បានថ្លែងឲ្យដឹងបន្ថែមថា ដើម្បីឆ្លើយតបទៅនឹងស្តង់ដារគុណភាព ថ្មីៗនេះក្រសួងកសិកម្មបានបើកវគ្គបណ្ដុះបណ្ដាលមួយទាក់ទងនឹងការវេចខ្ចប់ ដែលមានការចូលរួមពីតំណាងមកពីមន្ទីរកសិកម្មនៃបណ្ដាខេត្តរាជធានី និងមានការចូលរួមពីសំណាក់ក្រុមពាណិជ្ជករផងដែរ។

ប្រទេសកម្ពុជាមានតំបន់ដាំម្រេចល្បីល្បាញក្នុងខេត្តកំពត ក្រៅពីនោះ មានការដាំដុះម្រេចនៅខេត្តត្បូងឃ្មុំ ខេត្តរតនគិរី និងខេត្តក្រចេះផងដែរ។ ទីផ្សារម្រេចរបស់កម្ពុជាពឹងផ្អែកភាគច្រើនលើឈ្មួញមកពីប្រទេសវៀតណាម និងប្រទេសថៃ។ នៅក្នុងចំណោមម្រេចទាំងនេះ ម្រេចកំពតគឺមាន តម្លៃខ្ពស់ហើយទីផ្សារម្រេចកំពត គឺនៅមិនទាន់សុត្រចុះនៅឡើយទេ ហើយតម្លៃម្រេចកំពតគឺ ខុសគ្នាពីម្រេចនៅតំបន់ផ្សេងៗរាប់សិបដង ដោយសារតែទីតាំងភូមិសាស្ត្រនៅទីនោះអំណោយផល អាចផលិតម្រេចមានគុណភាពពិសេសខុសពីកន្លែងដទៃ ដូច្នេះ ហើយទើបបានជាផលិតផលម្រេចនៅទីនោះ ត្រូវបានទទួលស្គាល់ និងចុះបញ្ជីជាទំនិញសម្គាល់ភូមិសាស្ត្រ ដែលមានតម្លៃដ៏ខ្ពស់នៅអឺរ៉ុប។

លោក ងួន ឡាយ ប្រធានសមាគមផលិតម្រេចកំពតបានមានប្រសាសន៍ថា ឆ្នាំនេះម្រេចកំពត គឺរំពឹងថា អាចផលិតបាន ៨០ តោន ខណៈដែល៨ ខែ ដើមឆ្នាំនេះ គឺបាននាំចេញទៅទីផ្សារនៅសហគមន៍អឺរ៉ុប អាមេរិក និងជប៉ុន បាន ៤៥ តោន ហើយ។

លោកបានបន្តថា ផលិតផលម្រេចកំពតមានបី ហើយតម្លៃវិញគឺថ្លៃ ដោយម្រេចខ្មៅគឺមានតម្លៃ ប្រមាណជា ១៥.០០០ ដុល្លារនៅក្នុងមួយតោន ម្រេចក្រហម មានតម្លៃ ២៥.០០០ ដុល្លារនៅក្នុង មួយតោន ហើយម្រេចស គឺ មានតម្លៃ ២៨.០០០ ដុល្លារឯណោះមួយតោន។

*ដោយ សុផានិត និងអរិយបុត្រ*

# ពលរដ្ឋដែលប្រើប្រាស់សេវាដឹកជញ្ជូនរថយន្តក្រុងសាធារណៈសាទរ



ថតដោយៈ សុផានិត

ទឹកមុខដែលប្រកបដោយស្នាមញញឹមពព្រាយ គឺកំពុងតែលេចចេញពីលើផ្ទៃមុខរបស់ពលរដ្ឋដែលមកពីកន្លែងខុសគ្នា ពេលដែលបានដាក់កាយអង្គុយនៅកៅអី និងទទួលផាសុកភាពជាមួយនឹងម៉ាស៊ីនត្រជាក់ស្រេបពីសេវាកម្មរថយន្តក្រុងសាធារណៈនៅក្នុងរាជធានីភ្នំពេញ។

ពលរដ្ឋដែលទទួលសេវាកម្មនេះ គឺតែងតែសើចក្អាកក្អាយ ប្រកបដោយភាពស្និទ្ធស្នាល ក្នុងមហាគ្រួសារខ្មែរតែមួយ ក្រោយពេលដែលបានឡើងជិះលើមធ្យោបាយដឹកជញ្ជូន ដែលដំណើរការក្រោមការគ្រប់គ្រងផ្ទាល់ពីរដ្ឋបាលរាជធានីភ្នំពេញ ដែលបាននឹងកំពុងបង្កភាពងាយស្រួល និងសន្សំសំចៃប្រាក់កាសរបស់ពួកគាត់។

មធ្យោបាយថ្មីដែលបាននឹងកំពុងដំណើរការ ប្រកបដោយសុវត្ថិភាពលើដងផ្លូវ ជាច្រើនក្នុងរាជធានីភ្នំពេញ ក្រោមការឧបត្ថម្ភពីរាជរដ្ឋាភិបាលកម្ពុជា ដែលបាននឹងកំពុងយកចិត្តទុកដាក់ លើជីវភាពប្រជាពលរដ្ឋ។

យុវសិស្ស សំ សុផារ៉ា ជាសិស្សកំពុងសិក្សា ថ្នាក់វិទ្យាល័យមួយក្នុងរាជធានីភ្នំពេញ ជាអ្នកនិយមគាំទ្រ នូវមធ្យោបាយថ្មីនេះ បានថ្លែងថា ប្អូនពិតជា មានការសាទរចំពោះសាលាក្រុងដែលបានបង្កភាពងាយស្រួលដល់ប្អូនក្នុងការធ្វើដំណើរមកកាន់សាលារៀន តាមមធ្យោបាយមួយមុខនេះ។

យុវសិស្សវ័យ ១៨ឆ្នាំខាងលើ បានបន្តទៀតថា ពីមុនប្អូនជិះម៉ូតូមករៀនខ្លួនឯង តែពេលជិះឡានក្រុងនេះ ស្រួល ដោយសារមិនចាំបាច់ហាត់ និងកាត់បន្ថយច្រើន ដូចជា ថ្លៃសាំង កកស្ទះចរាចរណ៍ ព្រមទាំងមិនចាំបាច់បែកញើស។

អ្នកនាង សុថាវី ដែលជាកម្មការិនីមួយរូប បានរៀបរាប់ថា អ្នកនាងពិតជារីករាយណាស់ ពេលដែលសម្តេចតេជោ ហ៊ុន សែន បានប្រកាសថា ឆ្នាំ២០១៨ រាល់កម្មករទាំងអស់អាចជិះឡានក្រុង មិនគិតលុយរយៈពេល ២ឆ្នាំ។ នេះពិត ជាដំណឹងរីករាយខ្លាំងដោយសារវាអាចជួយកាត់បន្ថយការចំណាយច្រើន និងម៉្យាងធ្លាប់តែជិះរថយន្តឈ្នួលអស់ថ្លៃច្រើន ព្រមទាំងក្តៅ តែជិះឡានក្រុងនេះត្រជាក់ស្រួល។

តែបើទោះបីជាមានការសាទរច្រើនពីសំណាក់ពលរដ្ឋមួយចំនួនធំ ក៏នៅមានពលរដ្ឋមួយចំនួនតូច បានលើកឡើងថាត្រូវរង់ចាំឡានក្រុងមកដល់បេនឡាន គោលដៅនិមួយៗយូរ (១០ទៅ១៥នាទី) ហើយពេលជិះមិនសូវជាទាន់ចិត្តនោះទេ ម៉្យាងខ្សែរថច្រើនមែនតែក៏មិនទាន់ទៅដល់កន្លែងដែលគាត់ចង់ទៅដល់បាននោះទេ។

បើទោះបីជាយ៉ាងណា ប្រជាពលរដ្ឋនៅតែសម្តែងការសាទរ ចំពោះការដាក់បន្ថែមខ្សែររថ នេះបន្ថែមទៀត អ្នកស្រីស្រីអូន បានបញ្ជាក់ថា "ការបន្ថែម (ឡានក្រុង) គឺកាន់តែច្រើនហើយ គេមិនអាចបន្ថែមតាមចិត្តអ្នកជិះគ្រប់គ្នាបាននោះទេ បងឃើញថា ចំនួនឡានក្រុងឥលូវនេះមានច្រើនជាងមុន នឹងចាំមិនសូវយូរដូចមុននោះទេ ឡានមកបន្តគ្នារហូតតើ"។

លោក លីណា ជាប្រជាពលរដ្ឋមួយរូបទៀត បានថ្លែងថា សេវាកម្មនេះវាអាចជួយកាត់បន្ថយការកកស្ទះច្រើនបើយើងរួមគ្នាជិះបានច្រើននោះ។

លោកបានបញ្ជាក់ថា "បើយើងជិះច្រើនអីចឹងឡានម៉ូតូក៏ថយចំនួននៅលើផ្លូវថ្នល់ដែរ តែបើយើងប្រញាប់យើងជិះម៉ូតូឡានខ្លួនឯងទៅ តែខ្ញុំអត់ប្រញាប់ ខ្ញុំជិះឡាននេះហើយ បើជិះម៉ូតូកង់បីថ្លៃជាងនេះឆ្ងាយណាស់។ អ៊ុំគ្រាន់តែសុំអោយគាត់ (អ្នកបើកបរ) ប្រុងប្រយ័ត្នអោយខ្លាំងជាងនេះបន្ថែមទៀត ព្រោះយើងបើកឡានធំផង តែប៉ុននេះ មិនអីទេ អាចទទួលយកបាន ។

ជុំវិញសេវាកម្មរថយន្តក្រុងសាធារណៈនេះ លោក ម៉េត មាសភក្តី អ្នកនាំពាក្យសាលារាជធានីភ្នំពេញ បានថ្លែងប្រាប់អ្នកសារព័ត៌មានកាលពីពេលថ្មីៗនេះថា រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) បានពង្រីកខ្សែរថ ៥ បន្ថែមទៀត ដើម្បីបង្កើនសេវាដឹកជញ្ជូនអ្នកដំណើរឲ្យកាន់តែប្រសើរ និងប្រកបដោយផាសុកភាព។

លោកបានបន្តថា "យ៉ាងណាក៏ដោយគម្រោងនេះត្រូវបានគេរំពឹងថានឹងធ្វើឲ្យកាន់តែប្រសើរទាំង សេវាដឹកជញ្ជូន និងការរួមចំណែកកាត់បន្ថយការកកស្ទះចរាចរណ៍ក្នុងរាជធានី ហើយក៏នឹងបន្ថែមរថយន្តបន្ថែមទៀតនៅពេលអនាគត"។

បន្ថែមលើសពីនេះទៀត អ្នកនាំពាក្យសាលារាជធានីរូបនេះ ក៏បានធ្វើការអំពាវនាវឲ្យជួយគាំទ្រដើម្បីរួមចំណែកកាត់បន្ថយការកកស្ទះ និងគ្រោះថ្នាក់ចរាចរណ៍ធ្វើឲ្យប្រសើរឡើងនូវបរិស្ថានក្នុងទីក្រុងផងដែរ។

លោកបានបន្តទៀតថា កុមារក្រោមអាយុ ៧ឆ្នាំ សិស្សនិស្សិត ចាស់ជរា ជនពិការ និងកម្មករដែលជិះរថយន្តក្រុងមិនតម្រូវឲ្យបង់ថ្លៃទេ។

*ដោយ សុផានិត*

## ខ្សែរថរបស់រថយន្តក្រុងទាំង៧ខ្សែ

**ខ្សែរថទី២** ចេញពីចំណតផ្សារអ៊ីអន ២ តាមផ្លូវឧញ៉ា ម៉ុងឬទ្ធី កាត់តាមរង្វង់មូលកាំកូស៊ីជី ឆ្ពោះទៅកាន់ផ្លូវជាតិលេខ ២ ដល់ក្រុងតាខ្មៅ ខេត្តកណ្តាល។ **ខ្សែរថទី៣** ចេញពីចំណតស្ទួនច្បារឫស្សីកែវ ផ្លូវជាតិលេខ៥ កាត់តាមរង្វង់មូលគួចកាណុង ឆ្ពោះទៅកាន់ផ្លូវជាតិលេខ៣ ចំណតបុរីសន្តិភាព២។ **ខ្សែរថទី៤A** ចេញពីស្ទួនច្បារឫស្សីកែវផ្លូវជាតិលេខ៥ កាត់តាមរង្វង់មូលគួចកាណុង ឆ្ពោះទៅផ្លូវវេងស្រេង ផ្សារទួលពង្រ ដល់ចំណតបុរីសន្តិភាព២។ **ខ្សែរថទី៤B** ចេញពីស្ទួនច្បារឫស្សីកែវផ្លូវជាតិលេខ៥ កាត់តាមរង្វង់មូលគួចកាណុង ឆ្ពោះទៅរង្វង់មូលចោមចៅ ផ្លូវជាតិលេខ៤ ដល់តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ។ **ខ្សែរថទី៥** ចេញពីចំណតផ្សារអ៊ីអន២ តាមផ្លូវលេខ១០០៣ កាត់ក្រោមស្ពានអាកាស៥មករា ឆ្ពោះវិថីសុធារស ចំណតផ្សារអ៊ីអន១។ **ខ្សែរថទី៦** ចេញពីបុរីរុងរឿង ផ្លូវជាតិលេខ៦ ដល់ចំណតផ្សារសែនជ័យផ្កាហ្វ្រា។ **ខ្សែរថទី៧A** ចេញពីគីឡូម៉ែត្រលេខ៩ ឆ្ពោះវិថីសុធារស ចំណតផ្សារអ៊ីអន១។ **ខ្សែរថទី៧B** ចេញពីគីឡូម៉ែត្រលេខ៩ ឆ្ពោះស្ពានព្រះមុន្នីវង្ស ដល់ចំណតច្បារអំពៅ។ **ខ្សែរថទី៨** ចេញពីគីឡូម៉ែត្រលេខ៩ ឆ្ពោះផ្លូវជាតិលេខ៦A ដល់ចំណតផ្សារបុរីរុងរឿង ហើយនៅត្រឹមឆ្នាំ ២០២០ នឹងពង្រីកឲ្យបាន ១០ ខ្សែបន្ថែមទៀត ក្នុងន័យឆ្លើយតបទៅនឹងតម្រូវការធ្វើដំណើរក្នុងរាជធានីភ្នំពេញ ៕

# យុវជនខ្មែរម្នាក់ កំពុងព្យាយាមសម្រេចក្តីស្រមៃផលិតគ្រឿងយន្តដោយខ្លួនឯង

យុវជនខ្មែរមួយរូបកំពុងតែព្យាយាម ធ្វើឲ្យក្តីស្រមៃរបស់ខ្លួនសម្រេច តាមរយៈការព្យាយាមផលិតនូវយានយន្តមួយប្រភេទ ដែលអាចបើកបរទាំងនៅលើផ្លូវគោកក៏បាន ផ្លូវទឹកក៏បាន និងហោះហើរលើផ្លូវអាកាសក៏បាន។

បើទោះបីជា រហូតមកដល់ពេលនេះ យានយន្តមួយប្រភេទនេះកំពុងតែស្ថិតក្នុងដំណាក់កាល សាកល្បងនៅឡើយក៏ដោយ តែនេះ គឺជាឆន្ទៈរបស់លោក ឆ គង់ម៉េង។

លោក ឆ គង់ម៉េង ជាអ្នកផលិតគ្រឿងយន្ត ដែលបច្ចុប្បន្ននេះលោកមានទីលំនៅក្នុងរាជធានីភ្នំពេញ បានកើតមានគំនិត និងការស្រលាញ់នូវការច្នៃប្រឌិតរបស់ខ្លួន តាំងពីវ័យកុមារភាព ហើយពីមុនលោក ក៏ជាជាងជួសជុលម៉ូតូ ដោយលោកយល់ឃើញថា ជំនាញនេះពាក់ព័ន្ធជាមួយគ្រឿងម៉ាស៊ីនច្រើន ទើបធ្វើឲ្យលោកសម្រេចចិត្តផលិតគ្រឿងយន្ត ដែលលោកស្រមៃនេះឡើង។

ជុំវិញក្តីស្រមៃបែបនេះ លោក ឆ គង់ម៉េង បានបង្ហើបឲ្យដឹងថា គម្រោងដែលលោករិះគិតកសាងយានយន្តថ្មីមួយខាងលើនេះ មិនមែនជាលើកទីមួយនោះទេ។ លោកបានបន្តថា កាលពីជាង១០ឆ្នាំមុន លោក បានសាកល្បងផលិតយន្តហោះ ដែលមានស្លាប ២ជាន់ អំឡុងពេលនោះ យាននោះមិនអាចហោះហើរបានទេ គឺអាចបើកបរបានតែលើផ្លូវគោកតែប៉ុណ្ណោះ។

លោក ឆ គង់ម៉េង បានបន្តឲ្យដឹងទៀតថា ពាក់ព័ន្ធជាមួយនឹងការផលិត និងតំឡើងគ្រឿងយន្តមួយនេះ គឺលោកបានប្រើប្រាស់ដែកអាលុយមីញ៉ូម គ្រឿងម៉ាស៊ីនម៉ូតូ ក្រណាត់ ឈើ ស្នោ ខ្សែភ្លើង កញ្ចក់ និងម៉ាស៊ីនសម្រាប់តំឡើង ដែលលោកត្រូវចំណាយ ថវិកាអស់ប្រមាណជាជាង ៣ពាន់ដុល្លារអាមេរិក។

លោកបានបញ្ជាក់ថា "ការផលិតគ្រឿងយន្តនេះគឺបានចាប់ផ្តើមតាំងពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧ និង រហូតដល់ពេលបច្ចុប្បន្ននេះ អាចដំណើរការសាកល្បងបាន១០០% ហើយពាក់ព័ន្ធជាមួយការនឹងការតំឡើងគ្រឿងយន្តមួយនេះ គឺមានបណ្តោយស្លាបប្រវែង ៣ម៉ែត្រកន្លះ"។

ពាក់ព័ន្ធនឹងការតម្លើងយានយន្តក្នុងក្តីស្រមៃដោយខ្លួនឯងនេះ លោក ឆ គង់ផេង ដែលត្រូវជាប្អូនប្រុស របស់លោក ឆ គង់ម៉េង និងត្រូវជាសហការី ក្នុងការឧបត្ថម្ភដល់ការផលិត និងតំឡើងយានយន្តនេះ បានឲ្យដឹងបន្ថែមទៀតថា ដោយសារតែលោក មើលឃើញពីការខិតខំប្រឹងប្រែង និងការច្នៃប្រឌិតរបស់បងប្រុសខ្លួន ដែលចិញ្ចឹមចិត្ត និងមានទេពកោសល្យព្រមទាំងមានការស្រលាញ់លើការសាកល្បងនេះតាំងពីវ័យកុមារភាពមកនោះ លោកគាំទ្រឲ្យបងប្រុសសាកល្បង។

លោកបានបន្តថា មកដល់ឆ្នាំ២០១៧ នេះ ប្រសិនបើបងប្រុសរបស់លោកមានគំនិតច្នៃបង្កើតថ្មីបែបនេះ លោកក៏លើកទឹកចិត្តបងប្រុស ឲ្យបន្តការផលិតគ្រឿងយន្ត ដោយមានការជួយជ្រោមជ្រែង ពីលោក ដែលជាអ្នកឧបត្ថម្ភ និងលើកទឹកចិត្តជូន ព្រោះអ្វីៗគ្រប់យ៉ាងទាំងអស់ គឺធ្វើឡើងដោយ កូនខ្មែរពិតៗ និងបានបញ្ចេញស្នាដៃទុកសម្រាប់យុវជនជំនាន់ក្រោយមកទស្សនា និងយកជាគំរូ ឲ្យកាន់តែមានគំនិតច្នៃប្រឌិត បន្ថែមទៀត។

លោក ឆ គង់ម៉េង ដែលជាអ្នកផលិត បានលើកឡើងបន្តថា ថ្ងៃទី២៧ សីហា នេះ លោកបាននាំយកយានដែលកែច្នៃរួច ហើយអាចបើកបរលើផ្លូវទឹក ផ្លូវគោក និងផ្លូវអាកាសមកសាកល្បង បើកបរនៅក្នុងទឹកថាតើវាអាចបើកបរបាន ឬយ៉ាងណា។ បន្ទាប់ពីសាកល្បងរួចមកនោះ យើងសង្កេតឃើញថា យាននោះអាចបើកនៅក្នុងទឹកបាន តែមិនអាចហោះហើរបាននោះទេ គឺអ្វីៗមិនដូចដែលលោកបានគ្រោងទុកនោះទេ នេះប្រហែលជាមកពីទំងន់នៃយានដែលមានទំងន់ធ្ងន់។

បើទោះបីជាការសាកល្បងនេះ វាមិនអាចជោគជ័យ១០០ ភាគរយដូចអ្វីដែលខ្លួនចង់បាន ប៉ុន្តែការដែលវាមិនអាចហោះបាន មិនធ្វើឲ្យលោកអស់សង្ឃឹមឡើយ ។

លោក ឆ គង់ម៉េង បានសង្ឃឹមថាក្រោយពេលបើកសាកល្បងក្នុងទន្លេចតុមុខ ដែលមានទីតាំងក្បែរនឹងមជ្ឈមណ្ឌលកោះពេជ្រ និងបើកបរលើផ្លូវគោកនេះរួច គឺជាភាពជោគជ័យមួយរបស់ខ្ញុំ។

លោកបានបន្តថា ដោយឡែកការកែច្នៃជាលើកទី៣ សម្រាប់ការហោះហើរលើអាកាសវិញ លោកនឹងព្យាយាម កែច្នៃស្លាបឲ្យបានសម្រេច។

លោក ឆ គង់ម៉េង បានបន្តថា ក្រោយពេល ដែលលោកបានកែច្នៃស្លាបនេះរួច វាប្រាកដជា អាចហោះហើរលើអាកាសបាន១០០% ព្រោះថាយន្តហោះអាចហោះហើរបានដោយមិនចាំបាច់ប្រើប្រាស់ម៉ាស៊ីន នឹងជួនកាលគេជាក់កង់ក៏គេអាចហោះហើរបានដែរ បែរជាលោកផលិតដោយម៉ាស៊ីន ហេតុអ្វីបានជាហោះមិនរួច។

នេះគ្រាន់តែជាការយល់ឃើញរបស់លោកឆ គង់ម៉េង ស្របពេល ដែលមនុស្សមួយចំនួនគិតថា ម៉ាស៊ីនម៉ូតូមិនអាចហោះហើរបានទេ។ ការពិតទៅគេអាចជាក់កង់ហោះហើរបានដែរលុះត្រាតែ អ្នកផលិតៗឡើងត្រឹមត្រូវ ទៅតាមក្បួនខ្នាត។

ជុំវិញការបង្ហាញស្នាដៃនៃការច្នៃប្រឌិតនេះ ប្រជាពលរដ្ឋមួយចំនួន បានសំដែងនូវការគាំទ្រ សម្រាប់គំនិតនេះ ដោយពួកគេបានបញ្ចេញយោបល់ថា នរណាក៏មានក្តីស្រមៃនិងក្តីសង្ឃឹម ដូច្នេះត្រឹមតែក្តីស្រមៃវាគ្មានអ្វីខុស ហើយបើក្តីស្រមៃនោះ វាចេញជាសកម្មភាពជាក់ស្តែង ដោយជាករណីដែលលោក ឆ គង់ម៉េង បានធ្វើទៀតវារឹតតែគួរឲ្យគាំទ្រ។

ពលរដ្ឋអ្នករស់នៅរាជធានីភ្នំពេញ២រូបដែលកំពុងតែឈរមើលការបើកសាកល្បងនេះ លោក គឹ មុន្នីតារា និងលោក សារ៉ុន បានថ្លែងថា នេះជាលើកទី១ ហើយដែលលោកទាំង២ បានឃើញកូនខ្មែរអាចផលិតរថយន្តដែលអាចបើកបរលើទឹកបាន បើកបរលើគោកបាន ហើយថែមទាំងដំណើរការបានល្អទៀតផង។

លោក ទេព ឧត្តម ដែលជាប្រជាពលរដ្ឋខ្មែរមួយរូបមានទីលំនៅនៅរាជធានីភ្នំពេញ បានថ្លែងថា លោកមិនបានដឹងអំពីសមិទ្ធផលនៃការកែច្នៃ និងប្រឌិតឡើងរបស់កូនខ្មែរដោយលោក ឆ គង់ម៉េង នោះឡើយ ប៉ុន្តែលោកសំដែងការគាំទ្រពេញទំហឹង លើការច្នៃប្រឌិតបែបនោះ ។

លោកបានបញ្ជាក់ថា "គ្រាន់តែឮហើយមិនបានឃើញពិតប្រាកដ តែខ្ញុំពិតជាគាំទ្រការច្នៃប្រឌិត ដោយករណី លោក ឆ គង់ម៉េង ហើយរដ្ឋគួរតែមានការឧបត្ថម្ភ និងគាំទ្រពួកគេ ដោយសារតែនេះ មិនមែនជារឿងដែលងាយស្រួលនោះទេ"។

លោកបានបន្តថា រដ្ឋគួរដែលបង្កើតមូលនិធិមួយ ដែលអាចគាំទ្រដល់គម្រោងណា ដែលគេអាចពិនិត្យទៅថា មានសក្តានុពល ពីព្រោះនេះគឺជាស្នាដៃកូនខ្មែរ ដែលគួរតែគាំទ្រ។ លោកបានបន្តថា មិនងាយទេ នៅក្នុងការរកជនជានមនុស្ស ដែលមានគំនិត មានការលះបង់ មានការតស៊ូ ស្រាវជ្រាវ បង្កបង្កើតជាយាន ជាឧបករណ៍ប្លែកៗបែបនេះនោះ។

គំនិតច្នៃប្រឌិតរបស់លោក ឆ គង់ម៉េង គឺមិនមែនជាគម្រោងច្នៃប្រឌិតលើកទីមួយ ដែលពលរដ្ឋខ្មែរ អាចធ្វើបាននោះទេ កន្លងមក មានអ្នកស្រាវជ្រាវ និងស្រមើស្រមៃមួយចំនួន អាចច្នៃប្រឌិតជា រថយន្តប្រើពន្លឺព្រះអាទិត្យ កង់ប្រើពន្លឺព្រះអាទិត្យ រថយន្តដ៏ស្រស់ស្អាត ដែលអាចបើកបរនៅលើផ្លូវនៅរាជធានីភ្នំពេញបាន និងការច្នៃប្រឌិតធ្វើយន្តហោះដែលគេឮកាលពីពេលថ្មីៗកន្លងទៅនេះ៕

*ដោយ សុផានិត និងអរិយបុត្រ*



ថតដោយ: សុផានិត

# មតិចម្រុះរបស់កម្មការិនីរោងចក្រកាត់ដេរជុំវិញការតម្លើងប្រាក់ខែ ១៧០ដុល្លារឆ្នាំក្រោយ

ក្រោយពេលដែលរាជរដ្ឋាភិបាលកម្ពុជាបានសម្រេចតម្លើងប្រាក់ខែគោលចំនួន ១៧០ដុល្លារនៅក្នុង មួយខែ នៅឆ្នាំក្រោយ កម្មការិនីរោងចក្រមួយចំនួនបានបញ្ចេញទស្សនៈរបស់ពួកគេខុសៗគ្នា ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយក៏ពួកគេរីករាយទទួលយកការតម្លើងនេះ។

កម្មការិនីមួយរូប ដែលអះអាងថា ខ្លួនឈ្មោះ ជិន សុខលាភ បានឲ្យដឹងថា ការតម្លើង១៧០ដុល្លារនៅ ក្នុងមួយខែនេះ គឺវាមិនច្រើនទេ សម្រាប់កម្មករ ប៉ុន្តែ បើគិតពីកម្មករទាំងអស់ច្រើន ដែរហ្នឹង ខណៈដែលរោងចក្រនីមួយៗ មួយរោងចក្រមានកម្មកររាប់ពាន់នាក់។

សុខលាភ បានរៀបរាប់ថា "១៧ ដុល្លារនេះ មិនអាចឲ្យជីវភាពខ្ញុំវាប្រសើរអីជាងឥឡូវនេះទេ ប៉ុន្តែហោចណាស់ក៏អាចជួយដោះស្រាយបញ្ហាថ្លៃជួលបន្ទប់បានដែរ បើម្ចាស់ផ្ទះអត់តម្លើងថ្លៃទេនោះ"។

លោកស្រី សេង សមដារី ជាកម្មការិនីរោងចក្រកាត់ដេរនៅស្ទួនកាណាឌីយ៉ា ម្តុំផ្លូវវែងស្រេងបាន បញ្ចេញយោបល់ថា ឲ្យតែគេតម្លើងប្រាក់ខែឲ្យទាំងខ្ញុំទាំងគេ គឺសប្បាយចិត្តហើយ ប៉ុន្តែបើឡើង ថែមជាងហ្នឹងបន្តិច ប្រហែលជាប្រសើរជាង។

លោកស្រីបានបន្តថា ប្រាក់ចំណូលពីប្រាក់ខែជាកម្មការិនីរោងចក្រកាត់ដេរនេះ វាមិនអាចឲ្យធូរធា ដូចគេអ្នករកស៊ី ដូចគេអ្នកធ្វើការងារល្អៗបានទេ ប៉ុន្តែសម្រាប់គ្រួសារលោកស្រី គឺវាអាចរស់នៅបាន។

លោកស្រីបានបញ្ជាក់ថា "បើទោះបីជាត្រូវរ៉ះថាំខ្លះៗ ប៉ុន្តែប្រាក់ចំណូលពីប្រាក់ខែនេះ គឺអាចចិញ្ចឹមកូន បាន ហើយ បើឆ្នាំក្រោយគេឡើងបាន ១៧ ដុល្លារទៀត ចឹងយើងអាចធូរជាងមុនដែរ បើថ្លៃម្ហូប ថ្លៃអង្ករនិង ថ្លៃផ្ទះជួលមិនឡើងថ្លៃ"។

លោក ចាន់ ប្រសើរ ជាម្ចាស់ផ្ទះជួលមួយរូប បានអះអាង នៅកន្លែងតូបកាហ្វេមួយនៅម្តុំចោម ចៅ ថា ១៧០ដុល្លារសម្រាប់អ្នកមានប្រាក់ខែច្រើន ឬប្រាក់ចំណូលខ្ពស់ វាមិនច្រើនទេ ប៉ុន្តែទោះបីជាយ៉ាងណាសម្រាប់កម្មករ និងកម្មការិនីដែលភាគច្រើន ទទួលទានតែ បាយដាក់ស្ល្បោង ៥០០ ទៅ១.០០០ រៀលអីគឺវាជួយបានខ្លះដែរ តែទោះបីជាយ៉ាងណា ក៏មិនអាចជួយជីវភាព ពួកគេឲ្យ ប្រសើរដូចគេដូចឯងបានឡើយ។

លោកបានបញ្ជាក់ថា "១៧០ដុល្លារមិនអាចឲ្យពួកគេភ្លេចបាយប្រហុកថង់បានទេ ប៉ុន្តែក៏ជួយដោះស្រាយថ្លៃទឹក ថ្លៃភ្លើង ថ្លៃបន្ទប់បាន បើពួកគេដេកចូលគ្នាបាន"។

លោកបានរៀបរាប់ទៀតថា ការដំឡើងប្រាក់ខែឲ្យដល់១៧០ដុល្លារនៅឆ្នាំក្រោយ គឺមិនច្រើនទេ ពីព្រោះ អ្វីៗក៏វាបានឡើងដែរ។

កញ្ញា ថន ស៊ីនឿន ដែលជាកម្មការិនីរោងចក្រមួយរូប ដែលកំពុងតែ កាន់ថង់បាយ និងថង់ត្រីអាំង ជ្រក់ ដោយម្ហូបដែលនាងទិញនេះ គឺថ្លៃជាង ៦.០០០ រៀល បានអះអាងថា ថ្ងៃនេះនាង ទិញម្ហូប រាងឆ្ងាញ់បន្តិច ពីព្រោះម្តាយមកពីស្រុក។

ស៊ីនឿនបានបន្តទៀតថា រាល់ថ្ងៃនាងចំណាយប្រហែលជា ត្រឹម ៣.០០០ រៀល ប៉ុណ្ណោះសម្រាប់អាហារបីពេល សម្រាប់ខ្លួននាងម្នាក់ ដើម្បីសន្សំប្រាក់ខ្លះផ្ញើទៅម៉ែ និងឲ្យប្អូនរៀន ជាមួយនឹងប្រាក់ខែ ដែលបានមកពីដេរថែមម៉ោងបានជិត ២០០ ដុល្លារ ដូច្នេះបើឆ្នាំក្រោយគេ តម្លើងប្រាក់ខែ បាន១៧០ដុល្លារថែមទៀត វាអាចសល់ថែមទៀតដែរ ប្រសិនបើស្អីៗមិនឡើងថ្លៃ។

គួររំលឹកដែរថា កាលពីថ្ងៃទី៥ ខែតុលា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចេញសេចក្តីប្រកាសព័ត៌មាន ថា ចាប់ពីខែ មករា ឆ្នាំ២០១៨ តទៅ ប្រាក់ខែគោលរបស់កម្មករនិងកម្មការិនី រោងចក្រកាត់ដេរគឺ នឹងត្រូវតម្លើងដល់ ១៧០ ដុល្លារនៅក្នុងមួយខែ។

ប្រភពដដែលបានបន្តថា នៅក្នុងកិច្ចប្រជុំរបស់គណៈកម្មការប្រឹក្សាការងារ ស្តីពីការចរចាប្រាក់ឈ្នួលគោលនៅថ្ងៃនោះ បានឈានដល់ការសម្រេចតម្លើងប្រាក់ឈ្នួលជូន បងប្អូនកម្មករ និងកម្មកានី រោងចក្រកាត់ដេរ ១៦៥ ដុល្លារ ប៉ុន្តែ សម្តេចតេជោ ហ៊ុន សែន ក៏បានសម្រេចបន្ថែម ៥ ដុល្លារនៅ ក្នុងមួយខែរថែមទៀត ។

លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអះអាងនៅលើបណ្តាញសង្គមថា ជាមួយនឹងការសម្រេចបែបនេះប្រាក់ខែកម្មករនៅក្នុងឆ្នាំ២០១៨ អាចនឹងទទួលបានចំនួនពី ១៨៧ ដល់១៩៨ ដុល្លារប្រសិនបើបូកបញ្ចូលប្រាក់អត្ថប្រយោជន៍ផ្សេងៗដទៃទៀត។

ដោយឡែក លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានថ្លែង នៅ ក្រោយបញ្ចប់កិច្ចប្រជុំរបស់គណៈកម្មការប្រឹក្សាការងារ ស្តីពីការចរចាប្រាក់ឈ្នួលគោលថា ក្រៅពីការសម្រេចតម្លើងប្រាក់ឈ្នួលហើយនោះ បងប្អូនកម្មករនិងកម្មការិនី ក៏ទទួលបានអត្ថប្រយោជន៍មួយចំនួន ដូចជាការធ្វើដំណើរនៅលើរថយន្តក្រុងសាធារណៈ នៅរាជធានីភ្នំពេញដោយមិនគិតប្រាក់ ការថែទាំសុខភាព និងការព្យាបាលជំងឺដោយមិនគិតថ្លៃ។

ទាក់ទិននឹងកម្មករនេះដែរកាលពីពេលថ្មីៗនេះ ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចតេជោ ហ៊ុន សែន ធ្លាប់បានថ្លែងថាក្រៅពីរឿងការសន្យាតម្លើងប្រាក់ខែ ដល់កម្មករ និងកម្មការិនីរោងចក្រ ហើយនោះសម្តេចក៏បានសន្យាថា បងប្អូនកម្មការិនីរោងចក្រកាត់ដេរដែលត្រូវសម្រាកមាតុភាពនឹងទទួលបានប្រាក់ខែ១២០ ភាគរយនៅក្នុងអំឡុងពេលសម្រាកមាតុភាពបីខែ ហើយក៏បានសន្យាថា កម្មករ និងកម្មការិនីរោង-ចក្រនឹងមានប្រាក់ចូលនិវត្តន៍នៅក្នុងឆ្នាំ ២០១៩ ខាងមុខ។

គិតរហូតមកដល់ពេលនេះ កម្ពុជាមានរោងចក្រសហគ្រាសសរុបប្រមាណជា ១១.១៦៨ កន្លែង ដោយផ្តល់ការងារធ្វើប្រមាណជា ១,២ លាននាក់ ។ ពួកគេទាំងនោះនៅក្នុងមួយខែ បានទទួលប្រាក់ខែសរុបប្រមាណជា២ ពាន់លានដុល្លារ ។ ក្រៅពីនោះ ក៏មានអ្នកដែលទទួលបានការងារ និងមុខរបរព្រមទាំងប្រភពប្រាក់ចំណូលដោយប្រយោលពី វិស័យនេះ ប្រមាណជា៣ លាននាក់ថែម ទៀត ។

*ដោយ អរិយបុត្រ*



ផតដោយៈ សុវណ្ណភូមិ

# កម្ពុជាជាទីផ្សារមួយដែលសំបូររូបិយប័ណ្ណបរទេស !



ថតដោយ: លីហៀង

នៅរាជធានីភ្នំពេញ និងបណ្តាខេត្ត ដែលមិនជាប់ព្រំដែនគេសង្កេតឃើញថា ពលរដ្ឋខ្មែរតែងតែដោះដូរ និងទូទាត់ទំនិញនានាជាប្រាក់រៀល និងដុល្លាររបស់អាមេរិក ចំណែកពលរដ្ឋនៅរស់នៅតាមព្រំដែនជាមួយប្រទេសជិតខាងវិញ គេសង្កេតឃើញពលរដ្ឋខ្មែរ ប្រើប្រាស់ប្រាក់ប្រទេសជិតខាងទាំងនេះ ក្នុងដំណើរការអាជីវកម្មរបស់ខ្លួន។

ទិដ្ឋភាពនៅក្នុងទីផ្សារនៅប្រទេសកម្ពុជាបែបនេះបានលេចចេញមកជិត ២ ទសវត្សរ៍មកហើយ ពោលគឺពលរដ្ឋខ្មែរបានចាយវាយរូបិយប័ណ្ណបរទេសដោយសេរី ពិសេសប្រាក់ដុល្លារអាមេរិក។

ចាប់ពីជនបទស្រុកស្រែ ទីប្រជុំជនពិសេសទីក្រុងស្រុកផ្សារ ពលរដ្ឋខ្មែរបានដោះដូរទំនិញដោយទូទាត់ជាសាច់ប្រាក់រៀលរបស់ខ្លួនឯង និងប្រាក់ដុល្លាររបស់អាមេរិកទាំងពីរ។ ចំណែកពលរដ្ឋតាមជាយដែនប្រទេសវិញ បានចាយវាយប្រាក់បាតថៃ ប្រាក់ដុងវៀតណាម និងប្រាក់គីបឡាវ ជាមួយពលរដ្ឋនិងឈ្មួញប្រទេសទាំងនោះក្នុងចង្វាក់ផលិតកម្មរបស់ពួកគេដោយសេរីនិងងាយ ស្រួលបំផុត។

ជាការពិតចរាចរណ៍រូបិយប័ណ្ណបរទេសពិសេសប្រាក់ដុល្លារអាមេរិកហាក់មានភាពសេរីប្រហាក់ប្រហែលនឹងប្រាក់រៀលជាម្ចាស់ស្រុក។ ការនិយមចាយវាយរូបិយ-ប័ណ្ណបរទេស បានធ្វើឱ្យអ្នកវិភាគផ្នែកសេដ្ឋកិច្ចសម្តែងការព្រួយបារម្ភថា អំណាចនៃរូបិយប័ណ្ណជាតិអាចនឹងត្រូវបាត់បង់។ ប៉ុន្តែនៅចំពោះមុខនៃការបើកដ៏ទូលាយសម្រាប់ការចាយវាយរូបិយប័ណ្ណបរទេសបែបនេះកម្ពុជាអាចមានផលវិជ្ជមានផង និងផលអវិជ្ជមានផងដែរ។

មុននឹងឈ្វេងយល់ពីផលវិជ្ជមាន និងអវិជ្ជមានជុំវិញចរាចរណ៍រូបិយប័ណ្ណបរទេសលើទីផ្សារកម្ពុជា យើងត្រូវក្រឡេកមើលបុព្វហេតុ និងមូលហេតុដែលប្រជាជនកម្ពុជា គឺនិយមចូលចិត្តចាយប្រាក់របស់បរទេសបន្តិចសិន។

តាមការឱ្យដឹងពីលោក សំ កុសល ជាសាស្ត្រាចារ្យផ្នែកសេដ្ឋកិច្ចមួយរូប បានបង្ហាញថា ប្រាក់ដុល្លារអាមេរិកបានបង្ហាញពីវត្តមានរបស់ខ្លួននៅកម្ពុជានៅអំឡុងឆ្នាំ១៩៩០ នៅពេលវត្តមានកងកម្លាំងរក្សាសន្តិសុខអង្គការសហប្រជាជាតិ ឬហៅកាត់ថា អ៊ុនតាក់(UNTAC) បានចូលមករៀបចំកាបោះឆ្នោតនៅកម្ពុជា។

ការហូរចូលនៃទាហានអ៊ុនតាក់ បាននាំមក ជាមួយប្រាក់ដុល្លារអាមេរិក និងត្រូវបានចាយវាយ យ៉ាងទូលំទូលាយ បើទោះបីជា កាលនោះធនាគារជាតិកម្ពុជាមិនទាន់អនុញ្ញាតឱ្យចាយវាយលុយដុល្លារអាមេរិកភ្លាមៗទេ។ ពេលនោះហើយ ដែលធនាគារជាតិបានបោះពុម្ពប្រាក់រៀល ដើម្បីធ្វើការដោះដូរក្នុងចង្វាក់ទីផ្សារ។ ប៉ុន្តែនៅពេលនោះ ការចរាចរប្រាក់ដុល្លារមានការកើនឡើង នាំឱ្យប្រាក់រៀលចុះថោកយ៉ាងលឿន រីឯទំនិញក៏ហក់ឡើងថ្លៃខ្លាំង ពោលគឺមានអតិផរណាយ៉ាងខ្លាំង ចំណែកម៉ាក្រូសេដ្ឋកិច្ចក៏ជួបបញ្ហាស្ថិរភាពផងដែរកាលនោះ។

លោកសាស្ត្រាចារ្យ បានបន្តថា ដើម្បីជាដំណោះស្រាយចំពោះមុខបញ្ហាដ៏ស្មុគស្មាញនេះ ធនាគារជាតិគ្មានផ្លូវផ្សេង ក្រៅពីទទួលយកដុល្លាររូបនីយកម្មនោះទេ មានន័យថា ដុល្លារអាមេរិកត្រូវអនុញ្ញាតឱ្យចរាចរណ៍ ឬចាយវាយដូចប្រាក់រៀលដែរ។

រហូតមកដល់ពេលនេះ រូបិយវត្ថុបរទេសពិសេស គឺដុល្លារ ទទួលបានទំនុកចិត្តពីពលរដ្ឋកម្ពុជា ច្រើនជាងរូបិយប័ណ្ណជាតិរបស់ខ្លួន នេះគឺអាចដោយសារតែបទពិសោធន៍នៃសង្គ្រាមកន្លងមក ដោយលុយរៀលធ្លាប់ត្រូវបានបោះបង់ចោល ខណៈពលរដ្ឋជាច្រើនបានខិតខំសន្សំវាទុក ប៉ុន្តែពួកគេបានត្រឹមតែការអស់សង្ឃឹម ដោយសារលុយរៀលដែលពួកគេខំប្រឹងសន្សំគ្មានតម្លៃទាល់តែសោះ។

លោកស្រី មាន ចិន្តា ជាស្ត្រីអាជីវករមួយរូប ដែលមានវ័យ ៥៦ ឆ្នាំ បានថ្លែងថា តាមការចងចាំរបស់លោកស្រីទាក់ទងនឹងប្រវត្តិលុយរៀល គឺថា គ្រួសារលោកស្រីសឹងតែចងករសម្លាប់ខ្លួននៅពេលដែលលុយរៀលដែលឪពុកម្តាយលោកស្រីខិតខំសន្សំកាលពីសម័យមុន គឺមិនត្រូវគេទទួលស្គាល់។

លោកស្រីបានរៀបរាប់ថា កាលពីសម័យនៃទស្សវត្សរ៍នៃឆ្នាំ១៩៧០ ពោល គឺក្រោយពេលដែល លោក សេនាប្រមុខ លន់ ណល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ គ្រួសារលោកស្រី គឺជាពាណិជ្ជករនៅក្នុងទីក្រុងភ្នំពេញ។ សម័យនោះ នរណាក៏ទទួលស្គាល់អំពីលុយរៀលដែរ ដោយឡែកលុយបរទេស ដូចជាដុល្លារក៏មានដែរ តែមិនសូវចរាចរណ៍ដូចជាបច្ចុប្បន្ននេះទេ។

លោកស្រីបានបន្តទៀតថា គ្រួសារលោកស្រីបានសន្សំលុយជាច្រើន ហើយពេលដែលបែកទីក្រុងភ្នំពេញ ពោលគឺនៅពេលដែលទាហានខ្មែរក្រហមបណ្តេញប្រជាពលរដ្ឋចេញពីទីក្រុង នៅពេលនោះលោកស្រី និងបងប្អូន ក៏បាននាំគ្នាដេរជាខ្នើយ ហើយញាត់លុយនោះ ទុកបានជាច្រើន ដោយសង្ឃឹមថា នឹងទទួលបានអនាគតល្អពេលសង្គ្រាម បានបញ្ចប់ ប៉ុន្តែមានឯណា នៅ សម័យ ប៉ុល ពត គឺគ្មានផ្សារ ដល់បែករបបប៉ុលពត នៅឆ្នាំ១៩៧៩ នៅពេលដែល ប្រទេសមានផ្សារឡើង វិញ ក៏នៅតែអស់សង្ឃឹម។

លោកស្រី បានបញ្ជាក់ថា "តាមដែលខ្ញុំចាំ កាលនោះ ដូចជា ប៉ា ខ្ញុំបានយកលុយនោះទៅដោះដូរ ប៉ុន្តែលុយនោះ មិនត្រូវបានទទួលស្គាល់។ កាលនោះបើសម័យនេះវិញ គាត់ប្រហែលជាសម្លាប់ខ្លួនបាត់ហើយ ពីព្រោះលុយនោះរាប់លានដែរ"។

លោក រ៉េត សុចិត្រា ជាប្រជាពលរដ្ឋមួយរូប បានថ្លែងថា ដោយសារតែប្រវត្តិនោះហើយ ដែលនាំឲ្យលុយរៀលមិនសូវជា មានតម្លៃ ដោយសារតែពលរដ្ឋចេះតែព្រួយបារម្ភរឿងប្រវត្តិសាស្ត្រប្រាំដែល។

លោកបានបញ្ជាក់ថា "សម័យនេះលុយរៀល គឺគ្រាន់តែសម្រាប់ដោះដូរទិញបាយទិញទំនិញតូចតាចទេ តែពេលធំដុំ ឬលុយសន្សំវិញ គឺច្រើនទុកដុល្លារអាមេរិក ពីព្រោះទីណាក៏អាចដូរបាន បើមិន អីចឹងទេ គឺគេទុកមាសតែម្តង"។

រហូតមកដល់ពេលនេះ ដើម្បីជាការលើកកម្ពស់ទំនុកចិត្តលើលុយរៀល ដែលជារូបិយប័ណ្ណជាតិ រាជរដ្ឋាភិបាលកម្ពុជាជាពិសេស គឺធនាគារជាតិនៃកម្ពុជា បានខិតខំ និងលើកកំពស់ពលរដ្ឋ ឲ្យប្រើប្រាស់លុយរៀល តាមរយៈការលើកទឹកចិត្តការប្រមូលបង់ពន្ធនានាជាលុយរៀល ហើយបណ្តាធនាគារពិសេស គឺស្ថាប័នមីក្រូ-ហិរញ្ញវត្ថុលើកទឹកចិត្តឲ្យដាក់ប្រាក់សន្សំជាលុយរៀល តាមការផ្តល់អត្រាការប្រាក់ខ្ពស់ជាង រូបិយប័ណ្ណបរទេស ប៉ុន្តែ ដុល្លារនីយកម្មនិងផ្នត់គំនិតកាលពីអតីតកាលនៅក្នុងចំណោមប្រជាពលរដ្ឋគឺមិនទាន់បាន ផ្លាស់ប្តូរនៅឡើយទេ។

រហូតមកដល់ពេលបច្ចុប្បន្ននេះ ដើម្បីស្ថិរភាពសេដ្ឋកិច្ច កម្ពុជាកំពុងតែខិតខំរក្សាស្ថិរភាពប្រាក់រៀលឲ្យនៅចន្លោះ ៣.៩០០ ទៅ ៤.១០០ រៀល នៅក្នុងមួយដុល្លារ ។

ដោយ អរិយបុត្រ

## ប្រធានាធិបតីអាមេរិក ប្រកាសដោះស្រាយវិបត្តិនៅឧបទ្វីបកូរ៉េនៅខែវិច្ឆិការ

លោក ដូណាល់ ត្រាំ ប្រធានាធិបតីអាមេរិកបានប្រកាសអំពីការប្តេជ្ញាចិត្តរបស់លោក ដើម្បីប្រឈមដោះស្រាយនឹងបញ្ហានៅឧបទ្វីបកូរ៉េនៅក្នុងអំឡុងពេលលោក ត្រូវធ្វើទស្សនកិច្ចនៅអាស៊ី។

សេតវិមានបានប្រកាសកាលពីថ្ងៃទី២៩ ខែកញ្ញាថា ប្រធានាធិបតីអាមេរិក លោក ដូណាល់ ត្រាំ នឹងធ្វើដំណើរទៅកាន់ប្រទេសអាស៊ី នៅខែវិច្ឆិកាខាងមុខ ដើម្បីចូលរួមកិច្ចប្រជុំកំពូលថ្នាក់តំបន់ ដែលគេស្គាល់ថា អាស៊ាន និងទស្សនកិច្ចជាលើកទីមួយរបស់លោកមកកាន់អាស៊ី ដែនដីដែលកំពុងតែចម្រូងចម្រាស់នឹង បញ្ហាជាច្រើនរួមមានតាំងពីវិបត្តិនៅឧបទ្វីបកូរ៉េ សមុទ្រចិនខាងត្បូង ។ល។

លោក ដូណាល់ ត្រាំ នឹងធ្វើទស្សនកិច្ចនៅប្រទេសជប៉ុន ចិន កូរ៉េខាងត្បូង វៀត-ណាម ហ្វីលីពីន និងនៅរដ្ឋហាវ៉ៃ សម្រាប់ដំណើរទស្សនកិច្ចចំនួន១១ថ្ងៃរបស់លោក។

សេចក្តីថ្លែងការណ៍របស់សេតវិមានបាននិយាយថា "ដំណើរទស្សនកិច្ចរបស់ប្រធានាធិបតី ដូណាល់ ត្រាំនឹងពង្រឹងការតាំងចិត្តជាអន្តរជាតិក្នុងការប្រឈមទៅនឹងការគំរាមកំហែងពីកូរ៉េខាងជើង"។

កាលពីដើមខែនេះ កូរ៉េខាងជើង បានសាកល្បងនុយក្លេអ៊ែរលើកទី៦របស់ខ្លួន ទោះបីជាមានការថ្កោលទោសជាអន្តរជាតិក៏ដោយ ហើយបានសន្យាថានឹងបាញ់សាកល្បងបន្ថែមទៀតនៅសមុទ្រប៉ាស៊ីហ្វិក ដោយឡែកនៅសមុទ្រចិនខាងត្បូងវិញ ហាក់ដូចជាស្ងប់ស្ងាត់បន្តិចក្រោយពេលដែលហ្វីលីពិនផ្លាស់ប្តូរមេដឹកនាំ។

## ហ្វីលីពីនធ្វើជាម្ចាស់ផ្ទះនូវកិច្ចប្រជុំកំពូលកសិកម្មអាស៊ានលើកទីមួយ

ក្រុមប្រឹក្សាពិគ្រោះយោបល់អាជីវកម្មនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ កាលពីថ្ងៃទី០៤ ខែតុលា បានរៀបចំនូវកិច្ចប្រជុំកំពូលកសិកម្មអាស៊ានលើកទីមួយនៅក្នុងទីក្រុង ផាសាយនៃ ប្រទេសហ្វីលីពីន។

កិច្ចប្រជុំកំពូលកសិកម្មអាស៊ាន ឆ្នាំ២០១៧នេះ ត្រូវបានផ្តួចផ្តើមឡើងដោយក្រុមប្រឹក្សាពិគ្រោះយោបល់អាជីវកម្មនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍-ហ្វីលីពីន ដើម្បីប្រមូលអ្នកដែលពាក់ព័ន្ធ ដើម្បីបង្កើតនូវគម្រោងការសមាហរណកម្ម សហគ្រិនកសិកម្មតំបន់មួយ។

កិច្ចប្រជុំកំពូលនេះ គឺបានផ្តោតការប្រមូលផ្តុំគំនិតនៅក្នុងការជំរុញការតភ្ជាប់អ្នកដែលពាក់ព័ន្ធទាំងអស់ នៅក្នុងប្រព័ន្ធនៃអេកូកសិកម្មអាស៊ាន ដើម្បីជំរុញឲ្យកសិកម្មក្លាយជាឧស្សាហកម្មក៏ដូចជា រៀបចំនូវយុទ្ធសាស្ត្រ ដើម្បីកាត់បន្ថយភាពក្រីក្រ ជំរុញកំណើន និងផ្សព្វផ្សាយអំពីកសិកម្មនៅក្នុងតំបន់ ក៏ដូចជាចូលរួមអភិវឌ្ឍន៍ជនបទនៅទូទាំងអាស៊ាន។

## សេដ្ឋកិច្ចអាស៊ានរំពឹងថា នឹងកើនឡើង៥ ភាគរយ នៅឆ្នាំ២០១៧ និង ២០១៨

ការព្យាករណ៍អំពី សេដ្ឋកិច្ចថ្មីមួយសម្រាប់តំបន់អាស៊ានដែលគេបានធ្វើកាលពីពេលថ្មីៗនេះ បានឲ្យដឹងថាជារួមបណ្តាប្រទេសអាស៊ាននឹងទទួលកំណើនសេដ្ឋ-កិច្ចជារួមប្រមាណជា ៥ភាគរយ សម្រាប់ឆ្នាំ២០១៧នេះ និងឆ្នាំ២០១៨ ខាងមុខ។

កំណើននេះ ត្រូវបានគេអះអាងថា គឺដោយសារតែ បណ្តាប្រទេសអាស៊ានទទួលបានការយកចិត្តទុកដាក់ខ្ពស់លើសកម្មភាពសេដ្ឋកិច្ចនៅក្នុងស្រុក ខណៈដែល តម្រូវការផ្នែកអេឡិចត្រូនិចគឺ កំពុងតែជំរុញឲ្យអាស៊ានផ្សារភ្ជាប់ខ្លួនទៅនឹងចរន្តនៃខ្សែចង្វាក់ផ្គត់ផ្គង់ឧបករណ៍អេឡិច-ត្រូនិចទៅសាកលលោក ។

នៅទូទាំងអាស៊ានគឺទទួលបានកំណើនសេដ្ឋកិច្ចនៅក្នុងកម្រិតខុសៗគ្នា ប៉ុន្តែសម្រាប់សិង្ហបុរីមួយ ដែលគេដឹងថា គឺជាប្រទេសដែលមានសេដ្ឋកិច្ចរឹងមាំជាងគេនោះ ទទួលបានកំណើនសេដ្ឋកិច្ច ២,៦ ភាគរយ សម្រាប់ឆ្នាំ២០១៧ និង២០១៨ នេះដោយសារតែកំណើននៃតម្រូវការពីខាងក្រៅ ។

ការសិក្សាបានអះអាងថា ភូមិសាស្ត្រនយោបាយគឺជាបញ្ហាប្រឈមមួយ សម្រាប់អាស៊ាន ប៉ុន្តែទោះ បីជាយ៉ាងណាក៏ដោយ គេរំពឹងថា វាមិនប៉ះពាល់ធ្ងន់ធ្ងរដល់កំណើនសេដ្ឋកិច្ចនោះទេ។

សម្រាប់ចិន ដែលគេដឹងថា គឺជាដៃគូសេដ្ឋកិច្ចយុទ្ធសាស្ត្រមួយរបស់អាស៊ាននោះ គឺនៅតែទទួលបានកំណើនសេដ្ឋកិច្ចនេះប្រមាណជា ៦,៥ភាគរយ ។

## អាថ៌កំបាំងនៅតែមានឥទ្ធិពលនៅក្នុងអាស៊ាននៅឡើយ

រយៈពេល ៥០ ឆ្នាំ គឺជាពេលវេលាដ៏យូរសម្រាប់លាតត្រដាងនូវអាថ៌កំបាំង ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ វានៅតែជាបញ្ហាសម្រាប់ប្រជាពលរដ្ឋអាស៊ានប្រមាណជា ៦៤០លាននាក់ដដែល ។

អ្វីដែលប្រជាជននៅអាស៊ានភាគច្រើននៅក្នុងចំណោមសមាជិកអាស៊ានទាំង១០ បានដឹងអំពី អាស៊ាន ត្រូវបានគេដឹងថា គឺដូចជា ដឹងពីកន្លែងពិភាក្សាតាមហាងតាមផ្លូវតាមផ្សារតែប៉ុណ្ណោះ ។

តាមរបាយការណ៍នៅក្នុងមួយឆ្នាំៗ អាស៊ានរៀបចំកិច្ចប្រជុំមិនតិចជាង ១.០០០ ប្រជុំទេ ប៉ុន្តែ អាស៊ានខ្លួនឯងនៅតែមិនសូវជាដឹងអំពីអាស៊ាន នោះគឺជាបញ្ហា ។

៥០ឆ្នាំមកនេះ អ្នកដែលនិយាយច្រើនអំពីអាស៊ាន គឺមានតែ មេដឹកនាំ នៃបណ្តាប្រទេសទាំងនេះតែប៉ុណ្ណោះ ដោយឡែកប្រជាជនគឺហាក់ដូចជា នៅឆ្ងាយពីការពិភាក្សា ពីវេទិការ ដោយបញ្ហាទាំងនេះមិនមែនតែនៅទីណាមួយឲ្យពិតប្រាកដនោះទេ គឺនៅទូទាំងអាស៊ានតែម្តង។

រហូតមកដល់ពេលបច្ចុប្បន្ននេះ បណ្តាមេដឹកនាំអាស៊ាន បានជជែកនឹងដាក់ចេញនូវយុទ្ធសាស្ត្រជាច្រើនសម្រាប់តំបន់ ដោយពួកគេមានការប្តេជ្ញាចិត្តថា នឹងដណ្តើមតួនាទីឲ្យក្លាយជាតំបន់មួយ ដែលមានសក្តានុពលសេដ្ឋកិច្ចធំជាងគេទី៥ របស់ពិភពលោក នៅឆ្នាំ២០៣០ ខាងមុខ ។

ដូច្នេះដើម្បីឲ្យសម្រេចគោលដៅនីមួយៗប្រកបដោយឧត្តមភាព អាស៊ានត្រូវបានគេលើកទឹកចិត្ត ឲ្យបកស្រាយនូវអាថ៌កំបាំងនៅក្នុងតំបន់បន្ថែមទៀត ។

## សាកលវិទ្យាល័យដ៏ល្បីបំផុតនៅអង់គ្លេសដករូបថតលោកស្រី អ៊ុង សានស៊ូជីចេញ

កិត្តិនាមរបស់លោកស្រីអ៊ុង សានស៊ូជី ដែលគេដឹងថា ជាម្ចាស់ពានរង្វាន់ណូបែលសន្តិភាព និង អ្នកប្រជាធិបតេយ្យដ៏មានប្រជាប្រិយភាព នៅពេលនេះ កំពុងតែរងនូវការរិះគន់ជុំវិញការអះអាងថា រដ្ឋាភិបាលលោកស្រីព្យាយាមបោសសម្អាតជនជាតិភាគតិចម៉ូស្លីមនៅភូមា រ៉ូហ៊ីនយ៉ា។

មហាវិទ្យាល័យមួយនៃសាកលវិទ្យាល័យអុកស្វ័តបានដករូបថតអ្នកនយោបាយនាំមុខរបស់មីយ៉ាន់ម៉ា គឺ លោកស្រីអ៊ុងសានស៊ូជីចំពេលដែលមានការអះអាងថា ប្រទេសដែលដឹកនាំដោយលោកស្រីនោះកំពុងអនុវត្តការបោសសម្អាតជនជាតិភាគតិច នៅរដ្ឋរ៉ាឃិន។

យោងតាមព្រឹត្តិបត្រព័ត៌មានរបស់និស្សិតបានឱ្យដឹងថា គណៈគ្រប់គ្រងមហាវិទ្យាល័យមួយនៅក្នុងសាកលវិទ្យាល័យដ៏ល្បីនោះ បានដករូបរបស់លោកស្រីអ៊ុងសានស៊ូជីចេញហើយ ជំនួសវិញដោយរូបគំនូរជប៉ុន គូរដោយលោកយ៉ូស៊ីហ៊ីរ៉ូ តាកេដា។

មេដឹកនាំស៊ីវិលមីយ៉ាន់ម៉ា លោកស្រី អ៊ុងសានស៊ូជី គឺជាអតីតនិស្សិតនៃមហាវិទ្យាល័យខាងលើ ហើយធ្លាប់បានទទួលសញ្ញាបត្រកិត្តិយសពីមុន។ ប៉ុន្តែលោកស្រីបានប្រឈមនឹងការរិះគន់យ៉ាងខ្លាំងចំពោះការដោះស្រាយរបស់គាត់លើវិបត្តិដែលបានឃើញជនម៉ូស្លីមរ៉ូហ៊ីងយ៉ា ៤០០.០០០ នាក់ភៀសខ្លួនពីមីយ៉ាន់ម៉ា និងរាប់សិបនាក់ កំពុងតែរងទុក្ខទោស និងការធ្វើទុក្ខបុកម្នេញ ។

ដោយសារតែសកម្មភាពយោធាប្រឆាំងនឹងជនជាតិរ៉ូហ៊ីនយ៉ានេះ មីយ៉ាន់ម៉ាបានប្រឈមនឹងការចោទប្រកាន់ថាព្យាយាមបោសសម្អាតជនជាតិភាគតិច ពីសំណាក់អង្គការសហប្រជាជាតិកាលពីដើមខែនេះ។

ផ្ទាំងរូបភាពលោកស្រីស៊ូជី ដែលត្រូវបានគូរដោយលោកចិន យ៉ាននីង នៅឆ្នាំ ១៩៩៧ ត្រូវបានគេព្យួរនៅច្រកចូលមហាវិទ្យាល័យចាប់តាំងពីឆ្នាំ ១៩៩៩។

រូបថតនេះជាកម្មសិទ្ធិរបស់ប្តីរបស់លោកស្រីស៊ូជី គឺលោកម៉ៃឃើល អារីស ហើយត្រូវបានប្រគល់ឱ្យទៅមហាវិទ្យាល័យ បន្ទាប់ពីការស្លាប់របស់គាត់ដើម្បីទុកជាអនុស្សាវរីយ៍ និងជានិមិត្តរូបនៃលទ្ធិប្រជាធិបតេយ្យ។

## កម្ពុជាមានជនបរទេសរស់នៅប្រមាណជា ២០ម៉ឺននាក់

ជនបរទេសដែលកំពុងតែរស់នៅក្នុងប្រទេសកម្ពុជាមកដល់ពេលនេះ ត្រូវបានក្រសួងមហាផ្ទៃអះអាងថា អាចមានប្រមាណជា ២០ម៉ឺននាក់ ។

លោក ឧត្តមសេនីយ៍ សុខ ផល អគ្គនាយកអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ បានមានប្រសាសន៍ប្រាប់អ្នកសារព័ត៌មានថា ផ្អែកតាមការស្រង់ស្ថិតិដែលសម្រេចបានប្រមាណជា ៨៥ភាគរយ គឺបានរកឃើញ ជនអន្តោប្រវេសន៍ទាំងអស់មានចំនួន ៤៦.៧៧៦គ្រួសារ ឬ១៧៦.៨១២ នាក់ ហើយបើគិតជាតួលេខ១០០% គឺយើងអាចប៉ាន់ប្រមាណថា ជិត២០ម៉ឺននាក់ ។

លោកបានបន្តថា ជនបរទេសដែលរស់នៅមិនប្រក្រតី មាន៥សញ្ជាតិ ដែលរួមមាន វៀតណាម ថៃ ឡាវ បង់ក្លាដេស និងចិន សរុបប្រមាណជា ៧ ម៉ឺននាក់។

ជុំវិញបញ្ហាជនបរទេសនេះ សម្តេច ក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានព្រមានទៅដល់មន្ត្រីនៅក្រោមបង្គាប់ឲ្យអនុវត្តច្បាប់ប្រឆាំងពួកគេ។

សម្តេចបានបញ្ជាក់ថា "ខ្ញុំមិនអាចទ្រាំនឹងបញ្ហានេះបានតទៅទៀតទេពីព្រោះរឿងនេះ ជារឿងរបស់ជាតិ មិនមែនជារឿងរបស់អ្នកណាម្នាក់ទេ ត្រូវតែដោះស្រាយ"។

## រឿងក្រុមតំណាងរាស្ត្ររត់គេចខ្លួន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃថា អត់ទាន់មានដីកាចាប់ខ្លួនទេ

ក្រុមអ្នកតំណាងរាស្ត្រ និងមន្ត្រីគណបក្សសង្គ្រោះជាតិជាច្រើនរូប បានចាកចេញពីប្រទេស បន្ទាប់ពីមានការចាប់ខ្លួនលោក កឹម សុខា ដែលជាប្រធានគណបក្សនេះ។

បណ្តាមន្ត្រី និងតំណាងរាស្ត្រគណបក្សប្រឆាំងដែលបានចាកចេញពីប្រទេស គឺត្រូវបានគេដឹងថា គឺមានចាប់ពីអនុប្រធានគណបក្ស អ្នកនាំពាក្យ និងអ្នកកាន់តំណែងសំខាន់ៗនៅក្នុងបក្ស។

តាមព័ត៌មានដែលផ្សព្វផ្សាយដោយកាសែតនៅក្នុងស្រុក គេដឹងថា ក្រុមមន្ត្រីគណបក្ស ប្រឆាំង ដែល បានចាកចេញទៅអាមេរិក មាន ៤នាក់ ទៅអឺរ៉ុប គឺមាន ៣ នាក់។ ដោយឡែកអ្នកដែលមិនដឹងគោលដៅថា ទៅទីណា គឺមាន ៤ នាក់ ។ ដោយឡែកកូនស្រី លោក កឹម សុខា ទាំងពីរក៏មិនបាននៅក្នុងស្រុកដែរ។

## សម្តេចហ៊ុនសែនប្រកាសទិញស្ពាន និងផ្លូវ ពីក្រុមហ៊ុនឧកញ៉ា លី យ៉ុងផាត់

ប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានប្រកាសថានឹងទិញយកស្ពាន និងផ្លូវរបស់ក្រុមហ៊ុនឧកញ៉ា លី យ៉ុងផាត់ មកធ្វើការគ្រប់គ្រងហើយផ្លូវនិងស្ពាននេះនិងអនុញ្ញាតឲ្យប្រជាពលរដ្ឋធ្វើដំណើរឆ្លងកាត់ទៅមកដោយមិនចាំបាច់បង់ថ្លៃ ចាប់ពីថ្ងៃទី១៥ ខែតុលា នេះតទៅ។

ហ្វេសប៊ុកសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាក់នៅថ្ងៃទី៥ ខែតុលា ថា "ដើម្បីដោះស្រាយនូវការលំបាក និងជួយលើកកម្ពស់ជីវភាពប្រជាជនពិសេសសម្រួលដល់ការធ្វើដំណើរទៅមករបស់ប្រជាពលរដ្ឋ ចាប់ពីម៉ោង ០០:០០នាទី ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៧នេះតទៅស្ពាន និងផ្លូវតភ្ជាប់ពីផ្លូវជាតិលេខ៦A ទៅផ្លូវជាតិលេខ៥ (ស្ពាន និងផ្លូវ លី យ៉ុងផាត់ ព្រែកព្នៅ) នឹងត្រូវធ្វើដំណើរដោយមិនបាច់បង់ថ្លៃឆ្លងកាត់ទៀតទេព្រោះរាជរដ្ឋាភិបាលនឹងទិញយកមកគ្រប់គ្រងវិញ"។

ស្ពានព្រែកព្នៅមានប្រវែង ៩៩៦ម៉ែត្រ និងទទឹងប្រវែង ១៤ ម៉ែត្រសាងសង់ឡើងឆ្លងកាត់ទន្លេសាបស្ថិតក្នុងរាជធានីភ្នំពេញ។ វាត្រូវបានសាងសង់ឡើងចាប់ពីថ្ងៃទី១៥ ខែមិថុនាឆ្នាំ២០០៨ហើយត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ ចំណាយថវិកាអស់ចំនួន ៤៣,៥៥ លានដុល្លារ។

## ក្រុមការងារជំនាញកម្ពុជាចាប់ផ្តើមបោះសម្អាតគ្រាប់បែកគីមីអាមេរិកដែលប្រមុខរដ្ឋាភិបាលរិះគន់

ក្រុមការងារជំនាញមកពីអាជ្ញាធរជាតិអាវុធគីមី និងមជ្ឈមណ្ឌលកំចាត់មីនកម្ពុជាហៅកាត់ថា ស៊ីម៉ាក កំពុងបន្តប្រតិបត្តិការរាវរកគ្រាប់បែកគីមី ដែលសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី កម្ពុជា បានរិះគន់អាមេរិកនិងបានបញ្ជាឲ្យដោះដើម្បីសង្គ្រោះប្រជាពលរដ្ឋ នៅក្នុងឃុំគគីរ ស្រុករមាសហែក ខេត្តស្វាយរៀង។

គ្រាប់បែកគីមីដែលអ្នកជំនាញកំពុងតែប្រតិបត្តិការបោសសំអាតនោះ មានពីរគ្រាប់ដែលត្រូវបានគេជឿថា ជាប្រភេទគ្រាប់Chlorobenzalmalononitrile (CS) ដែលទម្លាក់ពីលើយន្តហោះរបស់អាមេរិកកាលពីសម័យសង្គ្រាម។

គ្រាប់បែកគីមីនោះ ត្រូវបានសម្តេចតេជោហ៊ុនសែនបញ្ជាឲ្យអ្នកជំនាញកម្ពុជាដោះ និងបំផ្លាញចោល កាលពីចុងខែកញ្ញា ក្រោយពេលដែលសម្តេចបានរិះគន់អាមេរិកលើរឿងនយោបាយ ក៏ដូចជារឿងសំណល់នៃសង្គ្រាម នៅក្នុងតំបន់កាលពីទសវត្សរ៍នៃឆ្នាំ១៩៧០។

គ្រាប់បែកគីមីដែលអាជ្ញាធរកំពុងតែបោសសំអាតនេះ ត្រូវបានគេជឿថាមានសារធាតុគីមីប្រមាណជា ២២០ លីត្រ ដែលសារធាតុនេះ អាចប៉ះពាល់ដល់ទារកដែលនៅក្នុងផ្ទៃហូរទឹកភ្នែក និងផលប៉ះពាល់ដល់សុខភាពមនុស្ស សត្វជាច្រើនទៀត។

គ្រាប់បែកទាំងនេះជាប្រភេទគ្រាប់បែកដែលគេបានរកឃើញនៅផ្នែកផ្សេងៗនៃប្រទេស ដូចជានៅស្វាយរៀងនៅមណ្ឌលគិរី រតនគិរី និង ក្រចេះជាដើម។

## ប្រាក់ខែកម្មករក្នុងវិស័យឧស្សាហកម្មកាត់ដេរនឹងតម្លើងដល់ ១៧០ ដុល្លារក្នុងមួយខែ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានប្រកាសកាលពីថ្ងៃទី០៥ ខែតុលា ថា ប្រាក់ឈ្នួលអប្បរមា របស់កម្មករក្នុងវិស័យវាយនភណ្ឌកាត់ដេរ សម្រាប់ឆ្នាំ២០១៨ គឺ១៧០ដុល្លារ ក្នុងមួយខែ។

លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានប្រាប់អ្នកសារព័ត៌មាន ក្រោយបញ្ចប់កិច្ចប្រជុំមួយ ថា គណៈកម្មការប្រឹក្សាការងារបានបោះឆ្នោតយកតួលេខ ១៦៥ដុល្លារ ហើយនាយករដ្ឋមន្ត្រីបន្ថែម៥ដុល្លារទៀត សរុបនៅឆ្នាំ២០១៨ កម្មករនឹងទទួលបានប្រាក់ខែ១៧០ដុល្លារក្នុងមួយខែ។

លោកបានបន្ថែមទៀតថា ក្រៅពីនេះ បងប្អូនកម្មករនិងកម្មការិនី នឹងទទួលបានលក្ខខណ្ឌអនុគ្រោះ មួយចំនួនទៀត ដូចជាការពិនិត្យ និងព្យាបាលជំងឺរួមទាំងការជិះឡានក្រុងរបស់រដ្ឋដោយមិនគិត ប្រាក់។

បច្ចុប្បន្ននេះប្រាក់ឈ្នួលគោលកម្មករមានចំនួន១៥៣ដុល្លារហើយប្រាក់ឈ្នួល ១៧០ដុល្លារនឹងចាប់នៅឆ្នាំ ២០១៨ខាងមុខនេះ។ នៅកម្ពុជាមានរោងចក្រសហគ្រាសសរុប ១១.១៦៨ កន្លែងដែលផ្តល់ការងារធ្វើដល់កម្មករសរុប ១,២ លាននាក់។ ដោយនៅក្នុងនោះ ពួកគេអាចទទួលបានប្រាក់សរុប ប្រមាណជា ២ ពាន់លានដុល្លារនៅក្នុងមួយឆ្នាំ និងអាចផ្តល់ការងារ និងមុខរបរដែល មាន ប្រយោជន៍ដោយប្រយោល ដល់ពលរដ្ឋជាង ៣ លាននាក់ថែមទៀត។

## ទិវារំលឹកគុណគ្រូនឹងក្លាយជាចលនាជាតិមួយ

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជានៅថ្ងៃទី០៥ ខែតុលា បានបង្ហាញអំពីការប្តេជ្ញាចិត្តបន្តទៀតដើម្បី គាំទ្រដល់ វិស័យអប់រំ និងអ្នកដែលពាក់ព័ន្ធនឹងការអប់រំនៅក្នុងប្រទេស។

ថ្លែងនៅក្នុងពិធីរំលឹកគុណគ្រូ ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៧ នៅវិទ្យាស្ថានជាតិអប់រំ សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ទិវានេះ ត្រូវតែក្លាយជាចលនាជាតិមួយដើម្បីរំលឹកគុណគ្រូ ឲ្យបានទូទាំងប្រទេស នៅគ្រប់សាលារៀន និងស្ថាប័នអប់រំទាំងអស់។

នៅក្នុងឱកាសនោះ សម្តេចតេជោ ហ៊ុន សែន ក៏បានជំរុញឲ្យក្រសួងអប់រំ និងមុខងារសាធារណ បង្កើនអាយុចូលនិវត្តន៍ដល់លោកគ្រូ អ្នកគ្រូ ពីអាយុ ៦០ ទៅ ៦៥ ឆ្នាំ ដោយមានប្រសាសន៍ថា លោកគ្រូអ្នកគ្រូគឺនៅតែមានសក្តានុពលសម្រាប់ការអប់រំនៅកម្ពុជា ដោយសារតែពួកគាត់មានទាំងបទពិសោធន៍ និងជំនាញគ្រប់គ្រាន់។

សម្តេចតេជោ ហ៊ុន សែន ក៏បានថ្លែងទៀតថា សម្រាប់ប្រាក់ខែ រាជរដ្ឋាភិបាលនឹងសម្រួលសម្រាប់ការតម្លើងប្រាក់ខែពី៩៥ម៉ឺនរៀនទៅទាបបំផុតឲ្យបាន ១ លានរៀលនៅឆ្នាំ២០១៨ ។

នៅកម្ពុជានៅពេលនេះ គេដឹងថា មានសាលាបឋមសិក្សាចំនួន ៧.១៤៤ កន្លែង អនុវិទ្យាល័យចំនួន១.២៤០កន្លែង វិទ្យាល័យចំនួន ៤៨៦ កន្លែង និងស្ថាប័នឧត្តមសិក្សាមាន១១៥កន្លែងដែលកំពុងបណ្តុះបណ្តាលនិស្សិត និងសិស្ស ប្រមាណជា ៣ លាននាក់ ។

គួររំលឹកដែរថា កាលពី នៅក្នុងដំណើរប្រមាណជា ៥ ពាន់គីឡូម៉ែតរបស់សម្តេចកាលពីពេលថ្មីៗនេះ សម្តេចតេជោ នាយករដ្ឋមន្ត្រីបានសម្រេចផ្តល់វិភាគទាននៅក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ ជារូបវន្តសម្រាប់វិស័យអប់រំ និងសាលារៀន ប្រមាណជា ១៥០ លានដុល្លារ។



# ពលរដ្ឋកម្ពុជាមួយចំនួនអះអាងថា ថ្ងៃទី០៩ ខែ វិច្ឆិកា ជាថ្ងៃនៃការចងចាំដូច

កម្ពុជាជាប្រទេសដែលមានប្រវត្តិសាស្ត្រវែងឆ្ងាយនិងសំបូររឿងរ៉ាវច្រើនដែលគួរចងចាំ ហើយនៅក្នុងចំណោមរឿងរ៉ាវប្រវត្តិ-សាស្ត្រដ៏វែងទាំងនោះ ថ្ងៃទី០៩ ខែវិច្ឆិកា ជាថ្ងៃនៃការចងចាំដូចថ្ងៃ០៧ ខែមករា ផងដែរ នៅក្នុងប្រវត្តិសាស្ត្រ៦៤ ឆ្នាំកន្លងមកនេះ ។

រហូតមកដល់ពេលបច្ចុប្បន្ននេះ នរណាក៏អាចចាំបានថា ថ្ងៃទី០៩ ខែវិច្ឆិកា គឺជាថ្ងៃបុណ្យឯករាជ្យជាតិ ដែលខ្មែរបានរួបរួមគ្នាដណ្តើមបានភាពជាម្ចាស់ប្រទេសពីអាណានិគមនិយមបារាំងមកវិញ នៅក្នុងឆ្នាំ១៩៥៣ ហើយដោយឡែកថ្ងៃទី០៧ ខែ មករា គឺជាថ្ងៃនិមិត្តរូប នៃថ្ងៃរំដោះពីបនប្រល័យពូជសាសន៍ប៉ុលពត ឬរបបកម្ពុជាប្រជាធិបតេយ្យ ។

លោក តែង ម៉ៅភិរុណ ជាប្រជាពលរដ្ឋអាយុ ៣៥ឆ្នាំ បានឲ្យដឹងថា ចំពោះថ្ងៃទាំងពីរនេះនៅក្នុងចំណោមប្រជាពល-រដ្ឋកម្ពុជាទាំងអស់នរណាក៏ដឹងថា នោះគឺជាថ្ងៃអ្វីដែរ ដោយសារតែថ្ងៃនោះគឺជា ថ្ងៃឈប់សម្រាក ហើយថ្ងៃនោះ គឺជាថ្ងៃ ដែលប្រព័ន្ធផ្សព្វផ្សាយ និងជាថ្ងៃដែលគេរំលឹកអំពីព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនោះជារៀងរាល់ឆ្នាំឲ្យតែដល់ថ្ងៃនោះ។

លោកបានបន្ថែមទៀតថា លោកកើតមិនទាន់ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រទាំងពីរនេះទេ ប៉ុន្តែលោកបាន ចងចាំវាដោយសារតែបានរៀន បានអាន បានមើល និងបានឃើញ គេរំលឹករាល់ឆ្នាំ។

លោកបានបញ្ជាក់ថា "មិនដឹងយ៉ាងម៉េច ថ្ងៃទាំងនោះជាថ្ងៃក្រហមទាំងពីរលើកាឡង់ទ្រីយេ (ប្រតិទិន) ហើយទូរទស្សន៍ កាសែតអីគេផ្សាយរាល់តែ ឆ្នាំ"។

លោក ភិរុណ បានឲ្យដឹងបន្ថែមទៀតថា លោកមានជំនឿថា គ្មានអ្នកណាមិនដឹងថ្ងៃនោះជាថ្ងៃអ្វីនោះទេពីព្រោះ វាគឺជាថ្ងៃប្រវត្តិសាស្ត្ររបស់កម្ពុជាឲ្យតែពួកគេបានរៀន បានទស្សនាបានអាន បានស្តាប់ព័ត៌មានដែលគេនិយាយ បើទោះបីជាម្នាក់ៗគេអាចភ្លេចនូវរឿងរ៉ាវសាវតានៃព្រឹត្តិការណ៍ក៏ដោយ ប៉ុន្តែគេដឹងថ្ងៃនោះគឺជាថ្ងៃអ្វី។

លោក ប៉េង ពិសិដ្ឋ ដែលអះអាងថាត្រឹមជាមន្ត្រីនៃអង្គការសង្គមស៊ីវិលមួយរូប បានមានប្រសាសន៍ថា អ្នកមិនដឹងអំពីព្រឹត្តិការណ៍ទាំងពីរនេះ លុះត្រាតែ អ្នកទាំងនោះមិនបានរៀន មិនបានយកចិត្តទុកដាក់ មិនរវល់អីសោះតែម្តងបានមិនដឹង។

លោកបានបន្តថា អ្នកដែលកើតទាន់ព្រឹត្តិការណ៍ទាំងពីរនេះ គឺនៅមានច្រើននៅឡើយ ប៉ុន្តែពួកគាត់ ប្រហែលជាចាស់ៗពីព្រោះវាជាព្រឹត្តិការណ៍ដែលកើតឡើងមកអស់រយៈពេល ៦៤ឆ្នាំមកហើយ។ លោកបានបន្តថា បើយើងចង់រកសាក្សីរស់មកបកស្រាយ ប្រហែលជាពិបាករកបន្តិច ដោយសារតែអ្នកទាន់ព្រឹត្តិការណ៍នោះតែម្តង លុះត្រាតែគាត់អាចមានអាយុយ៉ាងហោចណាស់ ក៏ជាង ១០ឆ្នាំឡើងដែរ ដូច្នេះបើមកដល់ឥឡូវពួកគាត់អាចនឹងមានអាយុ យ៉ាងហោចណាស់ក៏ជិត ៨០ឆ្នាំដែរ។ ម្យ៉ាងទៀតបើយើងចង់រកអ្នកដែលប្រឡូកនៅក្នុងព្រឹត្តិការណ៍នោះផ្ទាល់ រឹតតែពិបាកទៅទៀតពីព្រោះគាត់អាចមានអាយុលើសពី ៨០ឆ្នាំ ហើយ អាចចូល ៩០ឆ្នាំផង ប៉ុន្តែយើងអាចមានសៀវ-ភៅប្រវត្តិសាស្ត្រ មានមេរៀន មានឯកសារដែលគេបានចងក្រងពីព្រឹត្តិការណ៍នោះ។

លោកបានបញ្ជាក់ថា "ខ្ញុំជឿថា នរណាក៏ដឹង! នរណាក៏ស្គាល់! មហាព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រទាំងពីរនេះដែរ ពីព្រោះវាជាថ្ងៃចាប់ផ្តើមពីររបស់ប្រជាពលរដ្ឋកម្ពុជា"។

លោកបានបន្តទៀតថា បើតាមការចេះចាំរបស់លោក ដែលបានអាននិងបានសិក្សាប្រវត្តិសាស្ត្រប្រទេស ថ្ងៃ០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ គឺជាថ្ងៃដែលខ្មែរបានដណ្តើមឯករាជ្យ ពោលគឺភាពជាម្ចាស់ ប្រទេសឡើងវិញ ក្រោយពេលដែលបានបាត់បង់ឥស្សរភាពរបស់ខ្លួន តាំងពីឆ្នាំ១៨៦៣ ដូច្នេះវាគឺជាថ្ងៃចាប់ផ្តើមរស់នៅក្រោមជោគវាសនាដែលខ្មែរជាអ្នកសម្រេច ប៉ុន្តែថ្ងៃទី ០៧ ខែមករា ឆ្នាំ១៩៧៩ ក៏ជាថ្ងៃចាប់ផ្តើមដែរ ពីព្រោះសង្គ្រាមស៊ីវិលនិងរបបប្រល័យពូជសាសន៍របស់ប៉ុលពត ដែលដឹកនាំ



រូបភាពឯកសារ ថតដោយ សម្បត្តិ

### កំណត់ចំណាំអំពីព្រឹត្តិការណ៍ដែលកើតមាននៅថ្ងៃបុណ្យឯករាជ្យជាតិ

ឆ្នាំនេះក៏ប្រហែលមិនខុសពីឆ្នាំមុនដែរ ប្រជាពលរដ្ឋ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ថ្នាក់ដឹកនាំ និងព្រះមហាក្សត្រនៃកម្ពុជានឹងប្រារព្ធពិធីបុណ្យឯករាជជាតិ ១៩៥៣-២០១៧។

ជារៀងរាល់ឆ្នាំ នៅថ្ងៃបុណ្យឯករាជជាតិ ប្រជាពលរដ្ឋ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ថ្នាក់ដឹកនាំប្រទេស ក្រោមអធិបតីភាពព្រះករុណាព្រះបាទសម្តេចព្រះបរមនាថនរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា តែងតែជួបជុំគ្នានៅវិមានឯករាជ្យ ដើម្បីប្រារព្ធពិធីជាប្រវត្តិសាស្រ្តនេះ។

នៅថ្ងៃនោះ ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះអង្គតែងតែយាងព្រះប្រទានភ្លើងជ័យ នៅវិមានឯករាជ្យនាព្រឹកថ្ងៃទី០៩ ខែវិច្ឆិកា ដោយអមព្រះរាជដំណើរដោយសម្តេច ប្រធានរដ្ឋសភា ព្រឹទ្ធសភា សម្តេចនាយករដ្ឋមន្ត្រី និងថ្នាក់ដឹកនាំកំពូលជាច្រើនទៀត។

ដោយឡែកនៅថ្ងៃទី១១ ខែវិច្ឆិកា ព្រះមហាក្សត្រដោយអមព្រះរាជដំណើរដោយប្រជាពលរដ្ឋ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ថ្នាក់ដឹកនាំប្រទេស ស្តេចតែងតែយាង ចូលរួមពិធីពន្លត់ភ្លើងជ័យ ។

ក្រៅពីពិធីផ្លូវការនៅក្នុងព្រឹត្តិការណ៍នេះ គឺតែងតែមានព្រឹត្តិការណ៍មនុស្សធម៌ផ្សេងៗ ព្រឹត្តិការណ៍ នៃកំសាន្តនានា ការអុជកាំជ្រួច ជាដើម ។

### កំណត់ចំណាំអំពីថ្ងៃ ៧ ខែ មករា ថ្ងៃកំណើតទីពីរនៃពលរដ្ឋកម្ពុជា

ជារៀងរាល់ឆ្នាំ ដោយរួមទាំងឆ្នាំនេះផង គណបក្សប្រជាជនកម្ពុជាក៏បានរៀបចំជាអង្គមីទិ្ទញមួយ យ៉ាងឧឡារឹក នៅទីស្នាក់ការកណ្តាលរបស់គណបក្ស ដើម្បីអបអរខួបនៃថ្ងៃជ័យជំនះ ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩។

អង្គមីទិ្ទញអបអរសាទរខួបនៃ ថ្ងៃជ័យជំនះគឺមិនខុសពីថ្ងៃបុណ្យឯករាជជាតិប៉ុន្មានឡើយ ដោយថ្ងៃនោះប្រជាពលរដ្ឋ មន្ត្រីរាជការ សិស្សនិស្សិត កងកម្លាំងប្រដាប់អាវុធ និង ថ្នាក់ដឹកនាំ ប្រទេស ព្រមទាំងអង្គទូត តែងតែចូលរួមព្រឹត្តិការណ៍ជាប្រវត្តិសាស្រ្តនេះជារៀងរាល់ឆ្នាំ ដើម្បីអបអរថ្ងៃកំណើតទីពីររបស់ខ្លួន។

នាថ្ងៃនោះ ថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជាតែងតែមានសារនយោបាយសំខាន់ៗដើម្បី បញ្ជាក់អំពីជំហរនយោបាយនិងគោលនយោបាយ ក៏ដូចជា បង្ហាញនូវសមិទ្ធផលសេដ្ឋកិច្ច និងសង្គមនានា ជូនប្រជាពលរដ្ឋកម្ពុជាទូទៅបានដឹង ។

ក្រៅពីនៅទីស្នាក់ការកណ្តាលរបស់គណបក្សនៅតាមខេត្តនានាក៏មានរៀបចំមហាព្រឹត្តិការណ៍បែបនេះផងដែរ ។

## ...ថ្ងៃ០៧ ខែមករា ដែរ

ដោយរបបដែលមានឈ្មោះជាផ្លូវការថា កម្ពុជាប្រជាធិបតេយ្យនោះ បំផ្លាញឫសគល់ នៃសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ដល់កម្រិតសូន្យតែម្តង។

លោកស្រី ហេង ច័ន្ទធូ ដែលជាបុគ្គលិករដ្ឋបាលនៅរោងចក្រកាត់ដេរ នៅចាក់អង្រែក្រោម បានឲ្យដឹងថា ទាំងថ្ងៃបុណ្យឯករាជ្យ និងថ្ងៃ៧មករា គឺសុទ្ធតែជាមេរៀនប្រវត្តិ-សាស្រ្តដែលលោកស្រី បានទទួលពីសាលាពេលដែលលោកស្រីរៀននៅសាលាចំណេះទូទៅ។

លោកស្រីបានបញ្ជាក់ថា "ថ្ងៃនោះ គឺសុទ្ធតែសំខាន់ ដោយសារតែជាថ្ងៃដែលយើងដឹងថា សម្តេចតា នរោត្តម សីហនុ ដណ្តើមបានឯករាជ្យពីបារាំង ហើយថ្ងៃ ៧ មករា គឺជាថ្ងៃ ដែល គណបក្ស ប្រជាជនផ្តួលរំលំ ពីរបបខ្មែរក្រហម ដែលគេដឹងថា បានសម្លាប់ប្រជាពលរដ្ឋខ្លួនឯងជាង ៣ លាននាក់"។

លោកស្រីច័ន្ទធូដែលមានវ័យទើបតែ ២៨ឆ្នាំ បានថ្លែងទៀតថា ព្រឹត្តិការណ៍ទាំងពីរ គឺជាព្រឹត្តិការណ៍ដែលងាយស្រួលចាំ ដោយសារតែនរណាក៏និយាយអំពីវាដែរ ហើយណាមួយទៀត នៅរោងចក្រឥឡូវនេះ ក៏កំពុងតែនិយាយពីព្រឹត្តិការណ៍នេះដែរ ដោយសារតែគេចាំបានថា ពួកគេនឹងអាចឈប់សម្រាកបាននៅថ្ងៃនោះ។

ជុំវិញបញ្ហានេះ សាស្រ្តាចារ្យប្រវត្តិសាស្រ្តមួយរូបនៅវិទ្យាល័យមួយ ដែលសូមមិនបញ្ចេញអត្តសញ្ញាណ បានមានប្រសាសន៍ថា ព្រឹត្តិការណ៍ទាំងពីរគឺជាថ្ងៃស្លាប់រស់របស់កម្ពុជាទាំងពីរ ប៉ុន្តែលោកបានញែកព្រឹត្តិការណ៍ទាំងពីរថា ថ្ងៃបុណ្យឯករាជភាព គឺជាថ្ងៃដែលខ្មែររួបរួមគ្នា ផ្តួលបរទេសពោលគឺផ្តួលនិងបណ្តេញរបបអាណានិគមនិយមបារាំង ប៉ុន្តែថ្ងៃជ័យជម្នះ ៧ មករា គឺជា ថ្ងៃដែលប្រទេសជិតខាងមួយបានមកលុកលុយកម្ពុជាយើងហើយជួយសង្គ្រោះកម្ពុជានៅក្នុង ខណៈដែលរបបកម្ពុជាសម្លាប់ប្រជាពលរដ្ឋកម្ពុជា។

លោកបានបញ្ជាក់ថា "នេះគឺជាពីរផ្សេងគ្នា ប៉ុន្តែជារឿងប្រវត្តិសាស្រ្តដែលយើងមិនអាចប្រកែកបាន ពីព្រោះសាក្សីនៅរស់មានច្រើនជាពិសេស គឺសម្រាប់ថ្ងៃ ៧ មករា"។

លោកបានពន្យល់ទៀតថា សម្រាប់ព្រឹត្តិការណ៍ថ្ងៃ០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ គឺថា ជាផ្លូវការរបបអាណានិគមគឺពិតជាចាកចេញ ប៉ុន្តែកេរដំណែលផ្នែកគំនិតនិងផ្នែកអាណានិគមប្រហែលជា ពិបាកចាកចេញ ដោយសារតែខួរក្បាលនៃបញ្ញជននៅសម័យនោះ ភាគច្រើនសុទ្ធតែទទួលការអប់រំ ដោយអាណានិគម ដូច្នេះហើយបានជាចលនានៃការតស៊ូវណ្ណៈនៅតែមានទោះបីជាមិនសូវ ទទួលការគាំទ្រពីប្រជា-ពលរដ្ឋ ប៉ុន្តែចលនានោះមិនរលត់ និងបន្តរីកធំធាត់រហូតដល់ដណ្តើមអំណាចបាននៅក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយកំហឹងនៃសង្គម ក៏បានប្រែក្លាយកម្ពុជាទៅជារបបប្រល័យពូជសាសន៍ ពីពេលនោះមករហូតដល់ថ្ងៃ០៧ ខែមករា ឆ្នាំ១៩៧៩ ក្រោយពេលដែលកម្ពុជាទទួលការលុក-លុយពីវៀតណាម ក្រោយការអំពាវនាវពីរណសិរ្សសាមគ្គី និងសង្គ្រោះជាតិកម្ពុជា ដែលគេដឹងថា គឺគណបក្សប្រជាជនកម្ពុជា ប៉ុន្តែរបត់ប្រវត្តិសាស្រ្តបានប្រែប្រួល ដោយឆ្នាំ១៩៨៩ កងទ័ពរំដោះវៀតណាម បានចាកចេញពីកម្ពុជា ហើយនៅពេលនោះកម្ពុជា ក៏ចាប់ផ្តើមមានឥស្សរភាព ហើយបានឈានដល់រួបរួមគ្នាបោះឆ្នោតនៅក្នុងឆ្នាំ១៩៩៣ ហើយឈាន ទៅដណ្តើមបានសន្តិភាពទាំងស្រុងនៅឆ្នាំ១៩៩៨។ ដែលពេលនោះ គឺជាថ្ងៃដែលអង្គការចាត់តាំងនយោបាយ និងយោធា ដែលមានប្រវត្តិយូរលង់មួយ ពោលគឺតាំងពីសម័យអាណា-និគមមក បានត្រូវបញ្ចប់និងបិទទំព័រប្រវត្តិ-សាស្រ្តរបស់ខ្លួន ។

លោកបានបន្តទៀតថា នេះគឺជាទំព័រប្រវត្តិសាស្រ្តដ៏គួរឲ្យឈឺចាប់ ដែលពីនេះតទៅ កម្ពុជាគួរតែ មានប្រវត្តិសាស្រ្តដែលល្អ សម្រាប់មនុស្សជំនាន់ក្រោយ ពីព្រោះយើងមានបញ្ញាជនដែលទទួល ការអប់រំពីទីកន្លែងផ្សេងៗគ្នាជាច្រើន ដូច្នេះគួរតែរួបរួមគ្នា ជាឧត្តមប្រយោជន៍សម្រាប់ជាតិកុំ ប្រមូលផ្តុំជម្លោះដើម្បីតែអំណាចកិត្តិយស និងទ្រព្យសម្បត្តិ។

*ដោយ អរិយបុត្រ*

# ព្រះសហគមន៍សន្តយ៉ូសែប ផ្សារតូច ប្រារព្ធខួប២៥ឆ្នាំ

គ្រីស្តបរិស័ទប្រមាណជាង ១000 នាក់មកពីព្រះសហគមន៍នានា ទូទាំងប្រទេសកម្ពុជា ជាពិសេសគ្រីស្តបរិស័ទនៃ ព្រះសហគមន៍កាតូលិកសន្តយ៉ូសែប ផ្សារតូច រាជធានីភ្នំពេញបានជួបជុំគ្នា ក្នុងពិធីបុណ្យអភិបូជាយ៉ាង ឱឡារិកដើម្បីអរព្រះគុណ និងលើកតម្កើងព្រះជាម្ចាស់សម្រាប់ខួប២៥ឆ្នាំនៃការកើតឡើងវិញរបស់ព្រះសហគមន៍នេះ។ ពិធីនេះប្រារព្ធខួបធ្វើឡើងនៅទីតាំងព្រះសហគមន៍សន្តយ៉ូសែបផ្ទាល់ កាលពីថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៧កន្លងនេះ ក្រោមវត្តមានដ៏ខ្ពង់ខ្ពស់របស់លោកអភិបាលព្រះសហគមន៍កាតូលិកទាំង៣ភូមិភាគ។ លោក រឿង ធ័ត្រសីរី ជាបូជាចារ្យទទួលខុសត្រូវព្រះវិហារសន្តយ៉ូសែបផ្សារតូច និងមណ្ឌលសកម្មភាពភ្នំពេញខាងជើងនៃភូមិភាគភ្នំពេញមានប្រសាសន៍ថា ពិធីនេះឡើងគឺជួយ-រំឭក គ្រីស្តបរិស័ទឲ្យនឹកឃើញព្រះសហ-គមន៍របស់ខ្លួនដែលបានកើតឡើងវិញដោយចេះចែករំលែកសកម្មភាពជាមួយគ្នា និងរួមចិត្តគំនិតគ្នាជាធ្លុងតែមួយ ដោយអរព្រះគុណព្រះជាម្ចាស់ ដែលជួយក្នុងបង្កើតព្រះវិហារសន្តយ៉ូសែបនៃព្រះសហ-គមន៍ផ្សារតូចនៅភ្នំពេញនេះ។ លោកបន្តថា ដោយចាប់ផ្ដើមមានជីវិតជាថ្មីក្រោយសង្គ្រាម និងរបបប្រល័យពូជសាសន៍ប៉ុលពត។ ទាក់ទងនឹងប្រវត្តិព្រះសហ-គមន៍នេះ លោកបូជាចារ្យ រឿង ធ័ត្រសិរី មានប្រសាសន៍ថា "បើយោងតាមឯកសារយើងបានទទួលកម្មសិទ្ធិដី និងអាគារនៅទីនេះឡើងវិញ នៅថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩២ គឺមានន័យថា ក្រោយពេលព្រះសហគមន៍ ត្រូវបានរដ្ឋអំណាចនៅសម័យនោះ ផ្ដល់សិទ្ធិសេរីភាពក្នុងការគោរពបូជាតាមជំនឿរបស់ខ្លួនឡើងវិញ"។ ព្រះសហគមន៍កាតូលិកនៅកម្ពុជាក៏ដូចជាប្រទេសជាតិទាំងមូលត្រូវបានបំផ្លាញដោយសារសង្គ្រាមស៊ីវិលក្នុងរបបប្រល័យពូជសាសន៍។ អគារជាច្រើនដែលរួមមានព្រះវិហារ សាលារៀន អារាមអ្នកបួសមណ្ឌលស្នាក់នៅ ត្រូវបានកម្ទេចស្ទើរតែគ្មានសល់។ មិនតែប៉ុណ្ណោះ លោកអភិបាលព្រះសហគមន៍កាតូលិក អស់លោកបូជា-ចារ្យ និងគ្រីស្តបរិស័ទជាតិខ្មែរជាច្រើននាក់ត្រូវបានស្លាប់ និងត្រូវបានគេសម្លាប់។ ក្រោយពីរបបខ្មៅងងឹតបានបញ្ចប់ទៅ គ្រីស្ត-បរិស័ទដែលរស់រានមានជីវិតបានខិតខំប្រមូលគ្នាផ្គុំគ្នាបង្កើតព្រះសហគមន៍ឡើងវិញ។ តាមប្រវត្តិមុនសង្គ្រាមអគារព្រះវិហារនេះ គឺជាអតីតអនុទេវវិទ្យាល័យ អប់រំយុវជន ដែលស្វែងរកយល់អំពីជីវិតជាអ្នកបួស មុនពួកគេចូលទៅទេវវិទ្យាល័យ ក្រោយសង្គ្រាមអគារទាំងនេះត្រូវបានរដ្ឋាភិបាលប្រើប្រាស់ជាកន្លែងស្នាក់នៅរបស់សិស្សសាលាពេទ្យទាហាន។

ក្រោយទទួលបានការអនុញ្ញាត្តិពីរដ្ឋមកវិញ ព្រះវិហារនេះជាសេនាធិការដ្ឋាននៃព្រះសហគមន៍កាតូលិកនៅកម្ពុជា។ មានសកម្មភាពជាច្រើនដែលបានកើតចេញពីកន្លែងនេះ មានការរិះគិត គម្រោងការណ៍ផែនការណ៍នានាកសាងព្រះសហគមន៍នៅកម្ពុជា។

ក្នុងធម្មទេសនា លោកអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ អូលីវីយេ ឆ្មីតអីស្លែរក៏បាន រំលឹកគ្រីស្តបរិស័ទអំពីសកម្មភាពជាច្រើនរបស់ព្រះសហគន៍សន្តយ៉ូសែបផ្សារតូចដោយបានបង្កើត ដូចជាក្រុមយុវជន មណ្ឌលសុខភាព ក្រុមចំរៀង និងក្រុមគ្រូអប់រំជំនឿជាដើម។ លោកបន្តថា ក្នុងថ្ងៃនេះខ្ញុំសូមអរគុណយ៉ាងខ្លាំងចំពោះវត្តមានលោកបូជាចារ្យមួយចំនួនដែលបានធ្វើសកម្មភាពជាច្រើនជួយឲ្យព្រះសហគមន៍នេះមានជីវិត្តយ៉ាងរស់រវើកក្រោយរបបប្រល័យពូជសាសន៍ប៉ុលពតរហូតមកដល់បច្ចុប្បន្ននេះ។ ជាពិសេសវត្តមានលោកវីរៈជ័យដែលបានបំរើព្រះសហ-គមន៍ស្ទើរទាំងអស់ក្នុងប្រទេសកម្ពុជា។

លោកអភិបាលអូលីវីយេបានបន្តទៀតថា នៅពេលនេះយើងបានជួបជុំគ្នាកោត-សរសើរ លើកតម្កើងព្រះជាម្ចាស់យ៉ាងឱឡារឹក ដែលទ្រង់បានប្រទានគ្រប់សកម្ម-ភាពរបស់ព្រះសហគមន៍សន្តយ៉ូសែបផ្សារ-តូច រយៈពេល២៥ឆ្នាំកន្លងមកនេះ ដើម្បីប្រកាសដំណឹងល្អទៅមនុស្សទាំងអស់។ បងប្អូនជាទីស្រលាញ់ថ្ងៃនេះយើងរួមជាមួយសន្តយ៉ូសែប អរព្រះគុណព្រះជាម្ចាស់សម្រាប់សេចក្ដីសុខសាន្តរបស់ព្រះសហ-គមន៍នៅក្នុងប្រទេសកម្ពុជាទាំងមូល។ លោកថា សព្វថ្ងៃនេះយើងមានព្រះសហ-គមន៍រច្រើនហូតដល់ ៩ មណ្ឌលសកម្ម-ភាព ដូច្នេះហើយយើងជាគ្រីស្តបរិស័ទត្រូវរួមជាមួយសន្តយ៉ូសែប ដើម្បីបន្តប្រកាសដំណឹងល្អទៅមនុស្សទូទៅឲ្យកាន់តែច្រើនឡើងៗ ក្នុងពេលនេះ និងពេលអនាគតដោយមិនត្រឹមតែឮសម្លេងខ្លាំងៗ ពីការច្រៀងកោតសរសេរី ការអធិដ្ឋាន។ យើងត្រូវបន្តសកម្មភាពឲ្យបានច្រើនជាងមុនដូចជាក្រុមសង្គហៈ ក្រុមមេត្តាករុណា ចំពោះប្រជាជននៅក្នុងទីក្រុងភ្នំពេញទាំងមូល។

អ្នកស្រី ឡេង សូនី គឺជាគ្រីស្តបរិស័ទមួយរូបក្នុងចំណោមគ្រីស្តបរិស័ទជាច្រើននៅព្រះសហគមន៍ផ្សារតូចបានឲ្យដឹងថាអ្នកស្រីពិតជាសប្បាយចិត្តខ្លាំងណាស់ដែលព្រះសហគមន៍នៅក្នុងប្រទេសកម្ពុជាមានសកម្មភាពឡើងវិញ ជាពិសេសព្រះសហ-គមន៍ផ្សារតូចដែលបានប្រារព្ធខួប២៥ឆ្នាំក្នុងថ្ងៃនេះ។ អ្នកស្រីបន្តថា យើងសង្កេតឃើញថា ផលផ្លែជាច្រើនដែលទទួលបានដូចជាចំនួនគ្រីស្តបរិស័ទកើនឡើងជារៀងរាល់ឆ្នាំ សកម្មភាពដែលបង្ហាញពីសេចក្ដីស្រលាញ់ជាច្រើននៅក្នុងសង្គម ព្រមជាមួយនិងសំណង់អាគាថ្មីផងដែរ។ អ្នកស្រីបន្តទៀតថា សកម្មភាពប្រកាសដំណឹងល្អរបស់ព្រះសហគមន៍នេះ បានប្រមែប្រមូលបងប្អូនគ្រីស្តបរិស័ទដែលបោះបង់ព្រះវិហារ ឲ្យត្រឡប់មករួមរស់ជាមួយមហាគ្រួសាយើងវិញ ដើម្បីរួមគ្នាលើកតម្កើងព្រះជាម្ចាស់ និងរួមគ្នាប្រកាសដំណឹងល្អឲ្យកាន់តែទូលំទូលាយ។

សូមជម្រាបថា ព្រះសហគមន៍សន្តយ៉ូសែបផ្សារតូច មានអាស័យដ្ឋានផ្ទះលេខ១៧៨៨B ផ្លូវជាតិលេខ៥ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ ព្រះសហគមន៍មានសកម្មភាពមកដល់ថ្ងៃនេះដោយមានវត្តមានលោកបូជាចារ្យចំនួន៥អង្គគឺ លោកបូជាចារ្យ អេមីល ដេតម្បក្រោយមកជាអភិបាល លោកបូជាចារ្យវីរៈជ័យ លោកបូជាចារ្យ បប់ ពិសេ លោកបូជាចារ្យ ប្រ៊ុយណូ កូសម៍ និងលោកបូជាចារ្យរឿង ធ័ត្រសិរីនាពេលបច្ចុប្បន្ននេះ។

*ដោយ ឆាក លាំង*



# យុវជនកាតូលិករួមគ្នាដាំកូនឈើ

យុវជនប្រមាណជា២០០ នាក់ដែលមកពីព្រះសហគមន៍នានា នៃភូមិភាគបាត់ដំបង បានរួមគ្នាដាំកូនឈើប្រភេទដើមបេង ចំនួនប្រមាណជាង១០០ដើម នៅក្នុងបរិវេណព្រះវិហារព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ ក្រុងបាត់ដំបង។

ការដាំដើមឈើនេះបានប្រព្រឹត្តឡើងនារសៀលថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៧ បន្ទាប់ពីយុវជនទាំងនោះបានសិក្សាឈ្វេងយល់ នៅក្នុងផ្នែកមួយនៃអង្គសន្និបាតយុវជនកាតូលិក ភូមិភាគបាត់ដំបង។ ដែលបានសិក្សា អំពីសារៈប្រយោជន៍នៃបរិស្ថាន តាមឯកសារ ឡោដាតូស៊ី របស់សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ដែលបានជំរុញឲ្យព្រះសហគមន៍ទាំងអស់យកចិត្តទុកដាក់បង្រៀនឲ្យគ្រីស្តបរិស័ទចេះស្រលាញ់ និងការពារបរិស្ថានធម្មជាតិ។

យុវជនកាតូលិកភូមិភាគបាត់ដំបង បានជួបជុំគ្នាក្នុងអង្គសន្និបាតរបស់ខ្លួន ចាប់ពីថ្ងៃទី០៣ ដល់ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៧។ អង្គសន្និបាតនេះបានរិះគិតលើប្រធានបទ "ព្រះបន្ទូលជាគ្រឹះនៃជីវិត"។

តាមប្រសាសន៍របស់លោកបូជាចារ្យ មួង រស់ តំណាងគណៈកម្មការរៀបចំអង្គសន្និបាតបានឲ្យថា អង្គសន្និបាត បាននាំយុវជនយុវនារីរិះគិតអំពីតម្លៃព្រះបន្ទូលក្នុងជីវិតរបស់គេ រិះគិតអំពីការត្រាស់ហៅរបស់ព្រះជាម្ចាស់ក្នុងជីវិតជាអ្នកបួស ជីវិតជាគូស្រករ ព្រមទាំងព្រឹត្តិការណ៍សង្គមមួយចំនួន។ ជាមួយគ្នានេះក្រុមយុវជនទាំងអស់ ក៏រិះគិតបានឈ្វេងយល់អំពីបរិស្ថាន និងធម្មជាតិ តាមលិខិតរបស់សម្តេចប៉ាប ដែលមានចំណងជើងថា "ឡោដាតូស៊ី"។

លោកថា អំពីបរិស្ថានព្រះសហគមន៍នាំឲ្យយុវជនអនុវត្តផ្ទាល់គឺដាំដើមឈើរួមគ្នា។ គ្រប់គ្នាបានដឹងហើយថា បរិស្ថានរបស់យើងកំពុងធ្លាក់ចុះខ្សោយ ត្រូវបំផ្លាញបន្តិចម្តងៗ ត្រូវការថែរក្សាការពារឡើងវិញ។ យើងធ្វើតាមកម្លាំងរបស់យើង តាមសមត្ថភាព។ ដោយយើងស្រលាញ់ព្រះអង្គ យើងស្គាល់ព្រះបន្ទូលរបស់ព្រះអង្គ ព្រះអង្គឲ្យការពារពិភពលោក ការពារបរិស្ថាន។

ចំណែកលោកអេរីគេ ហ្វេការេដ្ជូ អភិបាលព្រះសហគមន៍ភូមិភាគបាត់ដំបង មានប្រសាសន៍ថា បរិស្ថានជាព្រះអំណោយទានរបស់ព្រះជាម្ចាស់។ យើងទាំងគ្នាអស់ដាំកូនឈើ ជាសញ្ញាថាយើងចង់ការពារបរិស្ថានធម្មជាតិ និងធ្វើឲ្យព្រះអំណោយទានរបស់ព្រះជាម្ចាស់រីកចម្រើន។ ឲ្យមានដើមឈើល្អ ដែលឲ្យយើងមានសេចក្តីសង្ឃឹម និងមានម្លប់ការពារជីវិត ដូចព្រះជាម្ចាស់ជាម្ចាស់ជាម្លប់ សម្រាប់យើងដែលដើរតាមព្រះអង្គ។

លោកអភិបាលក៏បានមានប្រសាសន៍ផ្តាំ ទៅយុវជន ឲ្យយកព្រះបន្ទូលដាក់ចូលក្នុងជីវិតរបស់ខ្លួន។ លោកអភិបាលថា ដោយសារព្រះបន្ទូលឲ្យយើងមានមោទនភាព និងឲ្យមានកម្លាំងយ៉ាងខ្លាំងផងដែរ។ លោកបន្តថា យុវនារីយុវជនស្គាល់បញ្ហាសង្គម បញ្ហាក្នុងជីវិត ការដោះស្រាយបញ្ហាមិនមែនចេះតែធ្វើតាមចិត្តតាមអារម្មណ៍របស់ខ្លួននោះឡើយ។ យើងត្រូវមានរបៀប ត្រូវដឹងថាជីវិតយើងមានគុណតម្លៃ ដោយសារព្រះបន្ទូល។ ព្រះបន្ទូលនាំឲ្យយើងគិតត្រូវ ដើរតាមមាគ៌ាដ៏សុភាពរាបសារបស់ព្រះអង្គ។ លោកអភិបាលបន្តថា យុវជនត្រូវប្តូរទម្លាប់ កុំធ្វើតាមចិត្តតាមអារម្មណ៍ យុវជនបច្ចុប្បន្ននេះធ្វើតាមអារម្មណ៍ច្រើន នាំឲ្យយើងខុសរហូត។ ពេលណាយើងយកព្រះបន្ទូលដើម្បីណែនាំជីវិត យើងមានអនាគត និងសុភមង្គលរហូត។

ព្រះសហគមន៍ភូមិភាគបាត់ដំបងបានយកចិត្តទុកដាក់ខ្លាំងក្នុងការការពារបរិ-ស្ថានធម្មជាតិ ជារៀងរាល់អង្គប្រជុំ គ្រប់កម្រិត និងជាមួយសាសនាផ្សេងៗ ភូមិភាគនេះតែងមានបញ្ចូល សកម្មភាពដាំដើមឈើជានិច្ច។



## ព្រះសហគមន៍កាតូលិកក្នុងភូមិភាគបាត់ដំបង ធ្វើជំរឿនចំនួនគ្រីស្តបរិស័ទ និងឈ្វេងយល់បញ្ហាមួយចំនួន

ព្រះសហគមន៍បាត់ដំបង បានធ្វើជំរឿនចំនួនគ្រីស្តបរិស័ទ នៅតាមព្រះសហគមន៍នានានៃភូមិភាគទាំងមូល។ ដើម្បីជាប្រយោជន៍ក្នុងការកសាងគម្រោងផែនការសកម្មភាពរបស់ព្រះសហគមន៍ ការថែរក្សាជំនឿរបស់គ្រីស្តបរិស័ទ និងការចូលរួមក្នុងកិច្ចការអភិវឌ្ឍសង្គម។ ការធ្វើជំរឿននេះលោកគីគែ ហ្វីការេដ្ជូ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង បានចាត់លោក បូជាចារ្យម៉ាក ឲ្យទទួលខុសត្រូវ រៀបចំ និងអនុវត្តគម្រោងនេះ។

លោកបូជាចារ្យម៉ាក មានប្រសាសន៍ថា សម្រាប់ជំរឿនចំនួនគ្រីស្តបរិស័ទនៅក្នុងព្រះសហគមន៍ភូមិភាគបាត់ដំបងទាំងមូលនេះ គឺមានគោលបំណងស្វែងរកឲ្យឃើញនូវចំនួនគ្រួសារគ្រីស្តបរិស័ទឲ្យបានជាក់លាក់ និងជាប្រយោជន៍សម្រាប់ចូលរួមក្នុងការអភិវឌ្ឍន៍ព្រះសហគមន៍ និងសង្គម គឺដើម្បីការកសាងធនធានមនុស្ស ផ្នែកសង្គម-កិច្ច សុខភាព និងវិស័យផ្សេងៗទៀត ។

លោកបន្តថា ការងារនេះលោកបានចាប់ផ្តើមតាំងពីដើមឆ្នាំ២០១៧។ នៅតាមព្រះសហគមន៍នីមួយៗ តាមរយៈលោកបូជាចារ្យ ដែលគ្រប់គ្រងនៅព្រះសហគមន៍ទាំងនោះជួយបំពេញ និងធ្វើកិច្ចការនេះ ដោយមានសមាជិកគណៈកម្មការ និងមានសហការពីក្រុមយុវជន។

លោកបូជាចារ្យរូបនេះបន្ថែមទៀតថា រហូតមកដល់ពេលនេះ ដំណើរការជំរឿនេះមិនទាន់បានបញ្ចប់នៅឡើយទេ គឺយើងសម្រេច និងទទួលបានទិន្នន័យខ្លះៗមានប្រមាណ៦០ ភាគរយហើយ។ បច្ចុប្បន្នកំពុងតែបន្តកិច្ចការនេះ ជាបន្តទៀតជាមួយព្រះសហគមន៍មួយចំនួន ដែលមិនទាន់ធ្វើរួចនោះ។ តាមគម្រោង គឺត្រូវបញ្ចប់នៅចុងឆ្នាំ២០១៧នេះ។

នៅក្នុងព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង មានព្រះវិហារចំនួន២៤ កន្លែង ចែកចេញជា៤តំបន់សកម្មភាព គឺតំបន់បាត់ដំបង តំបន់អង្គរ តំបន់កំពង់ធំ និងតំបន់ទន្លេ នៅក្នុងចំណោមខេត្ត ចំនួន៨ មានដូចជា ខេត្តបាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ ឧត្តរមានជ័យ ព្រះវិហារ សៀមរាប កំពង់ធំ កំពង់ឆ្នាំង និងខេត្តពោធិ៍សាត់៕

*ដោយឡុង សម្ភស្ស*

# លោកអូលីវីយេថា "ត្រូវត្រៀមខ្លួនជានិច្ច ដើម្បីបង្ហាញខ្លួននៅមុខតុលាការព្រះជាម្ចាស់"

លោកអភិបាល អូលីវីយេ បានមានប្រសាសន៍ថា ក្នុងពេលលោកធ្វើជាអធិបតីក្នុងពិធីបុណ្យអភិបូជា នាឱកាសបុណ្យភ្ជុំនៅព្រះវិហារសន្តយ៉ូសែបផ្សារតូច កាលពីថ្ងៃទី២១ កញ្ញា ២០១៧ កន្លងទៅនេះ ដោយមានគ្រីស្តបរិស័ទចូលរួមជាច្រើនកុះករ។

បុណ្យភ្ជុំបិណ្ឌជាបុណ្យប្រពៃណីជាតិខ្មែរ ដែលមានតាំងពីយូរណាស់មកហើយ។ ព្រះសហគមន៍កាតូលិកនៅកម្ពុជាប្រារព្ធបុណ្យរួមជាមួយប្រជាពលរដ្ឋកម្ពុជា ដើម្បីនឹករឭកដល់មរណបុគ្គលទាំងឡាយ។ ព្រះសហគមន៍កាតូលិកសកលប្រារព្ធបុណ្យនឹករឭកដល់សន្តបុគ្គលនៅថ្ងៃទី១ ខែវិច្ឆិការ តាមប្រតិទិនរបស់ខ្លួន។ តែព្រះសហគមន៍នៅកម្ពុជាបានទទួលការអនុញ្ញាតិពីសន្តអាសនៈ មានសិទ្ធិប្រារព្ធបុណ្យនេះនៅថ្ងៃបុណ្យភ្ជុំតែម្តង។

នៅក្នុងធម្មទេសនាលោកអភិបាល បានណែនាំគ្រីស្តបរិស័ទដោយនឹករឭកដល់បងប្អូនទាំងអស់ដែលទទួលមរណភាព។ លោកថា ពេលមានមនុស្សស្លាប់ យើងនឹកឃើញ ដល់ព្រះយេស៊ូដែលបានសោយទិវង្គត តែបីថ្ងៃក្រោយមកព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញដ៏រុងរឿង ដែលជាពេលមួយយើង នឹកដល់សេចក្តីស្លាប់ដែលជាដំណាក់កាលមួយនៅក្នុងជីវិតរបស់យើង មុននឹងទទួលជីវិតអស់កល្បជានិច្ច។

លោកអភិបាលបញ្ជាក់ថា ជីវិតរបស់យើងមិនមែនអស់កល្បជានិច្ចនៅផែនដីនេះទេ ដូច្នេះ ត្រូវត្រៀមខ្លួនជានិច្ចដើម្បីបង្ហាញខ្លួននៅមុខតុលាការព្រះជាម្ចាស់ ហើយព្រះជាម្ចាស់នឹងពិនិត្យមើលសេចក្តីស្រឡាញ់របស់យើងចំពោះមនុស្សទាំងអស់ គឺយើងត្រូវបង្ហាញអ្វីទាំងអស់ដែលយើងបានប្រព្រឹត្ត។

លើសពីនេះទៅទៀតលោកបានក្រើនរំឭកគ្រីស្តបរិស័ទទាំងអស់ថា ជីវិតរបស់យើងមិនទៀងទាត់ មិនដឹងថាស្លាប់នៅពេលណា? ដូច្នេះត្រូវប្រុងប្រៀបពន្លឺនៃជំនឿ ពន្លឺនៃក្តីសង្ឃឹម និងពន្លឺនៃធម៌មេត្តាករុណានៅក្នុងខ្លួន ដោយអធិដ្ឋានជានិច្ច ដើម្បីឲ្យព្រះជាម្ចាស់ប្រទានជំនឿឲ្យរឹងមាំដូចមរណសាក្សីពីដើម។

លោកអូលីវីយេបន្ថែមថា ត្រូវមានក្តីសង្ឃឹមនឹងទទួលបានជីវិតអស់កល្បជានិច្ច ដែលជាជំនឿរបស់ព្រះសហគមន៍ និងបង្ហាញពីធម៌មេត្តាករុណាដោយយកចិត្តទុកដាក់ចំពោះមនុស្សឯទៀតៗដូចអ្នកម្តាយតេរេសា។


ថតដោយ: សម្បត្តិ

ក្រោយពីអភិបូជាគ្រីស្តបរិស័ទទាំងអស់រួមជាមួយលោកអភិបាលបានទៅអធិដ្ឋាននៅមុខវិមានចេតិយ ដើម្បីឧទ្ទិសដល់មរណបុគ្គលទាំងឡាយ ដោយទូលសូមអង្វរព្រះជាម្ចាស់ឲ្យលើកលែងទោស និងទទួលពួកគេឲ្យនៅស្ថានបរមសុខរួមជាមួយព្រះអង្គ។

ដោយ ដាលីស

សម្ភាស

# កញ្ញា ស្រី បុញ្ញកា ជាគ្រីស្តបរិស័ទកុំខ្លាចការរិះគន់ពីអ្នកដទៃ


កញ្ញា ស្រី បុញ្ញកា ថតដោយ លីហ៊ឿង

"បើសិនជាយើងពិតជាមានជំនឿ និងស្គាល់អំពីរបៀបនៃសាសនារបស់ខ្លួនពិតប្រាកដមែន យើងមិនគួរ អន់ចិត្ត ឬឈឺចាប់ចំពោះការរិះគន់ ឬការសើចចំអកពីសំណាក់អ្នកដទៃនោះទេព្រោះគេមិនបានស្គាល់យើងច្បាស់" នេះជាសំដីបញ្ជាក់របស់កញ្ញា ស្រី បុញ្ញកា ជានាយិកាមណ្ឌលនិស្សិតកាតូលិកកម្ពុជា។

កញ្ញា ស្រី បុញ្ញកា កើតនៅភូមិព្រែកស្បូវ សង្កាត់អូរគន្ធរ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ បានក្លាយជាគ្រីស្តបរិស័ទ ដោយសារបានមើលឃើញគំរូមួយចំនួនរបស់អ្នកជឿលើព្រះយេស៊ូ ជាពិសេសលោកបូជាចារ្យ និងដូនជីកាតូលិក។

ពេលជាយុវជនក្នុងព្រះសហគមន៍កាតូលិកស្រី បុញ្ញកា និយាយថា នាងពិតជាមានអំណរសប្បាយរីករាយ ក្នុងការចូលរួមសកម្មភាពជាច្រើនដូចជា ចូលរួមក្នុងក្រុមចម្រៀងព្រះសហគមន៍កាតូលិក ចែករំលែកបទពិសោធន៍ផ្សេងៗ និងទទួលការរៀនអប់រំជំនឿពីលោកបូជាចារ្យ ធ្វើពលកម្មរួមគ្នា អធិដ្ឋានរួមគ្នា ទៅសួរសុខទុក្ខអ្នកក្រីក្រចាស់ជរាជាដើម។ បុញ្ញកា បន្តថា សកម្មភាពទាំងនេះ គឺយុវជនទូទៅខ្លះគ្មានឱកាសធ្វើដូចយុវជនកាតូលិកនោះទេ។

កញ្ញា ស្រី បុញ្ញកា មានវ័យ ៣៧ឆ្នាំ ជាកូនទី៧ ក្នុងចំណោមបងប្អូន៨នាក់ នៃគ្រួសារពុទ្ធបរិស័ទដែលមានជំនឿមាំមួន។ ក្នុងចំណោមបងប្អូនទាំងអស់មាន បងស្រីទី២ ទី៥ និងរូបកញ្ញាជាគ្រីស្តបរិស័ទកាតូលិក។

នាយិការូបនេះបានបន្ថែមថាអ្វីដែលជាកម្លាំងចិត្តឲ្យនាងអាចដើរទៅមុខដោយស្នាមញញឹមគឺវត្តមានរបស់ព្រះជាម្ចាស់ដែលស្ថិតនៅក្នុងចិត្ត។ បើទោះបីជាពេលខ្លះនាងមានការលំបាក ការពិបាកចិត្ត និងមានអារម្មណ៍ថាឯកោ តែនាងអាចអធិដ្ឋានទូលអង្វរព្រះជាម្ចាស់ដែលតែងតែនៅក្បែរ និងចាំស្តាប់នាងគ្រប់ពេល។ ដោយអគ្គសញ្ញាជ្រមុជទឹក បុញ្ញកាតែងលើកខ្លួនឯងជានិច្ចនូវអត្ថន័យ និងពាក្យសន្យារបស់ខ្លួនថា នឹងរួមស្លាប់រួមរស់ជាមួយព្រះជាម្ចាស់។

បុញ្ញកាបញ្ជាក់ថា "ខ្ញុំពេញចិត្តសម្រាប់ជីវិតខ្ញុំដែលក្លាយជាគ្រីស្តបរិស័ទម្នាក់ក្នុងចំណោមមនុស្សជាច្រើនទៀត។ យើងខ្ញុំក៏មិនដែលភ័យខ្លាច ឬខ្មាសគេនៅពេលមានអ្នកដទៃនិយាយមិនល្អ អំពីសាសនាខ្ញុំ។ ផ្ទុយទៅវិញខ្ញុំគិតថា ព្រះជាម្ចាស់តែងតែលើកលែងទោសឲ្យមនុស្សទាំងអស់មិនថាអ្នកនោះស្មប់ស្រលាញ់ព្រះអង្គយ៉ាងណា ហើយរហូតដល់បូជាជីវិតព្រោះតែសេចក្តីស្រលាញ់ទៀតផង។ ចំពោះខ្ញុំវិញ ខ្ញុំមិនអាចលះបង់ជីវិតដូចទ្រង់ តែខ្ញុំអាចលើកលែងទោសឲ្យអ្នកដទៃ និងបង្ហាញឲ្យគេស្គាល់ព្រះយេស៊ូតាមរបៀបផ្សេង"។

ស្រី បុញ្ញកាបានទទួលអគ្គសញ្ញាជ្រមុជទឹកនៅព្រះវិហារសន្តយ៉ូសែប ផ្សារតូចក្នុងភូមិភាគភ្នំពេញអំឡុងឆ្នាំ២០០០ ក្នុងពេលដែលនាងកំពុងបន្តការសិក្សាថ្នាក់បរិញ្ញាបត្រនៅទីក្រុងភ្នំពេញ។

កញ្ញា ស្រីបុញ្ញកាបានបន្ថែមថា ក្នុងសម័យនោះកញ្ញារួម និងយុវជនមួយក្រុមបានស្ម័គ្រចិត្តទៅជួយបង្រៀនអប់រំក្មេងៗមួយក្រុមធំដែលមានចំនួនប្រហែលជា៥០នាក់នៅក្នុងភូមិតាំងគោកខេត្តកំពង់ធំ មួយសប្តាហ៍ម្តង បង្រៀនអប់រំជំនឿ អប់រំយុវជន និងស្ម័គ្រចិត្តចូលរួមក្រុមផ្សេងៗដើម្បីជួយសម្រួលកិច្ចការក្នុងព្រះវិហារនៅភ្នំពេញជាដើម។

ក្រោយបញ្ចប់ការសិក្សា នៅភ្នំពេញ កញ្ញា ស្រី បុញ្ញកា បានទៅបម្រើការងារជាគ្រូបង្រៀន នៅខេត្តបាត់ដំបង និងធ្វើជាប្រធានមណ្ឌលសិស្សវិទ្យាល័យ នៅក្នុងព្រះសហគមន៍បាត់ដំបង។ ក្រោយមកក៏ប្តូរមកបង្រៀននៅភ្នំពេញ និងទទួលធ្វើជានាយិកាមណ្ឌលនិស្សិតព្រះសហគមន៍កាតូលិកកម្ពុជា។ អស់រយៈពេលជាង១០ឆ្នាំក្នុងមុខងារជានាយិកាមណ្ឌលនិស្សិត។ បច្ចុប្បន្ន ស្រីបុញ្ញកាក៏ជាប្រធានគណៈកម្មការព្រះវិហារព្រះកុមារយេស៊ូបឹងទំពុន និងស្ម័គ្រចិត្តសម្រាប់គណៈកម្មការពិធីបុណ្យ និងក្រុមសង្គហៈ។

ស្ត្រីរូបនេះបន្តថា ក្នុងជីវិតជាគ្រីស្តបរិស័ទកញ្ញាមានអំណរសប្បាយនៅពេលដែលបានទៅព្រះវិហាររាល់ថ្ងៃអាទិត្យ ឬក្នុងពេលមានកម្មវិធីផ្សេងៗ ព្រោះអភិបូជាបានសម្រាលនូវទុក្ខកង្វល់មួយចំនួនក្រោយស្តាប់ការទេសនារបស់លោកបូជាចារ្យ និងក្រោយពេលចែករំលែកយោបល់ល្អៗជាមួយគ្រីស្តបរិស័ទផ្សេងៗទៀត។ ជាពិសេស អត្ថបទព្រះគម្ពីរដំណឹងល្អជួយកែប្រែនូវចំណុចខុសឆ្គងរបស់នាង ធ្វើឲ្យនាងគ្មានអារម្មណ៍ចង់ឃ្លាតឆ្ងាយពីព្រះជាម្ចាស់ឡើយ។

ស្រីបុញ្ញកាបានផ្តាំផ្ញើទៅដល់យុវជនកាតូលិកឲ្យចាប់អារម្មណ៍អំពីតួនាទីរបស់ខ្លួនជាគ្រីស្តបរិស័ទ និងសូមឲ្យពួកគាត់យកចិត្តទុកដាក់ក្នុងការប្រកាសដំណឹងល្អ ទោះបីជាមានគេមើលងាយ ឬសើចចំអក ឬរើសអើងសាសនាយ៉ាងណាក៏ដោយត្រូវដើរទៅមុខដោយមានជំនឿរហូតដល់គេទទួលស្គាល់យើង។ បើយើងមានជំនឿមាំមួនព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជាកាន់តែមានភាពរីកចម្រើនទៅមុខ។

ដោយៈរឿន ស្រីម៉ាច

# បងស្រី ហ្សាកឺលីន សួន ( 1917-1975 )

## Sr.Jacaueline SOEUN

## បព្វជិតា ក្រុមគ្រួសារឧបការគុណ



បងស្រីកើតនៅឆ្នាំ ១៩១៧។ ចូលជាអ្នកត្រៀមខ្លួនជាអ្នកបួសនៅឆ្នាំ ១៩៣៧។ បងស្រីចូល ជានវកជន នៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ១៩៣៨ ហើយថ្វាយសច្ចាប្រណិធានលើកដំបូងនៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ១៩៣៩ ក្រោយមក ថ្វាយសច្ចាប្រណិធានអចិន្ត្រៃយ៍នៅថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ១៩៥២។

បងស្រីត្រូវចាត់ឲ្យធ្វើការនៅក្រុងបាត់ដំបង នៅឆ្នាំ១៩៧៥ ដែលជាអ្នកផ្ទះសម្រាប់កុមារកំព្រា ដោយធ្វើការរួមជាមួយបងស្រី សាំងម៉ារី នុម ផល្លី និងកុមារកំព្រា ១៥នាក់។ បងស្រីត្រូវចាកចេញពីផ្ទះ នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៧៥ វេលាម៉ោង ៧ ព្រឹក តាមបញ្ជារបស់ខ្មែរក្រហម។

បន្ទាប់ពីបានធ្វើដំណើរអស់រយៈពេលបួនថ្ងៃ បងស្រីទៅដល់ភូមិអន្លង់វុន ហើយរស់នៅទីនោះចំនួន ៥ ខែកន្លះ។ នៅទីនោះ ដូនជីទាំងពីរនិងកុមារកំព្រាទាំងនោះសង់ខ្ទមមួយនៅ និងចុះធ្វើស្រែដូចប្រជាជនឯទៀតៗដែរ។ នៅថ្ងៃទី១៥ ខែកញ្ញា ដូនជីទាំងពីរ និងពួកកុមារកំព្រាទទួលការអនុញ្ញាតពីអង្គការឲ្យត្រឡប់ទៅប្រទេសវៀតណាមវិញ។ ពួកគេទៅដល់ព្រំដែនវៀតណាម នៅថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៧៥។ ប៉ុន្តែបងស្រី ហ្សាកកឺលីន ដែលមានកំណើតជាខ្មែរ និងកុមារកំព្រា ដែលសុទ្ធតែជាខ្មែរសុទ្ធសាធ ត្រូវអាជ្ញាធរវៀតណាមបញ្ជូនមកវិញ ព្រោះគេមិនទទួលជនជាតិខ្មែរទេ។ ប្រហែលខ្មែរក្រហមសម្លាប់បងស្រី ព្រោះនៅសម័យនោះ ខ្មែរក្រហមសម្លាប់ជនជាតិខ្មែរជាច្រើន ដែលពួកវៀតណាមបញ្ជូនមកវិញ។



សន្ត អ៊ីញ៉ាស នៅឡូយ៉ូឡា

លោកអ៊ីញ៉ាសកើតនៅភូមិឡូយ៉ូឡា នៅប្រទេសអេស្ប៉ាញ។ គាត់ធ្វើជាទាហាន តែត្រូវរបួសនៅសមរភូមិ។ ពេលកំពុងព្យាបាលរបួស អ៊ីញ៉ាសចាប់ផ្ដើមអានគម្ពីរ និងជីវប្រវត្តិសន្តបុគ្គលជាច្រើន ហើយគាត់កែប្រែចិត្តគំនិត ដោយទទួលស្គាល់ថា ព្រះយេស៊ូជាព្រះសង្គ្រោះ។ ក្រោយមក គាត់ធ្វើសមាធិ ហើយចែកបទពិសោធន៍ខាងផ្លូវវិញ្ញាណឲ្យមិត្តសម្លាញ់។ នៅពេលគាត់អាយុ៣៥ឆ្នាំ គាត់ទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យ ហើយទៅទីក្រុងប៉ារីស (ប្រទេសបារាំង) បង្កើតក្រុមបព្វជិតមួយដែលមាន ឈ្មោះថា សមាគមសហជីវិនរបស់ព្រះយេស៊ូ។ នៅក្នុងក្រុមគ្រួសារនេះ មានសន្ត ហ្វ្រង់ស៊ីស្កូ សាវីយេ។ ក្រុមបព្វជិតនេះមានគោលដៅជួយអប់រំយុវជន ប្រកាសដំណឹងល្អទូទាំងពិភពលោក និងរៀបចំសំណាក់ធម៌ ដើម្បីពង្រឹងជំនឿរបស់គ្រីស្តបរិស័ទ និងជួយណែនាំពួកគេខាងផ្លូវវិញ្ញាណ។ សន្ត អ៊ីញ៉ាសទទួលមរណភាពនៅឆ្នាំ ១៥៥៦ នៅ ពេលអាយុ៦៥ឆ្នាំ។

## ច្បាប់ចរាចរណ៍ផ្លូវគោកថ្មី

**មាត្រាទី ៣៩៖**

បណ្ណបើកបរជាតិនិងបណ្ណបើកបរអន្តរជាតិសម្រាប់អ្នកបើកបរយានយន្តគ្រប់ប្រភេទ ត្រូវចេញដោយក្រសួងសាធារណការនិងដឹកជញ្ជូន លើកលែងតែបណ្ណបើកបរសម្រាប់អ្នកបើកយានយន្តយោធានិងនគរបាលគ្រប់ប្រភេទ ជាពិសេសសម្រាប់បម្រើជំនាញដូចជា រថក្រោះ រថពាសដែក រថយន្តបំពាក់ឧបករណ៍ យានយន្តប្រដេញម៉ូតូកង់បី ម៉ូតូហែហម ដែលជាទ្រព្យសម្បត្តិរដ្ឋ ក្រោមការគ្រប់គ្រងរបស់ក្រសួងមហាផ្ទៃ ឬក្រសួងការពារជាតិដែលត្រូវចេញដោយក្រសួងសាមី។

នីតិវិធីនៃការចេញបណ្ណបើកបរអន្តរជាតិត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។

ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវផ្ដល់បញ្ជីស្ថិតិអ្នកមានបណ្ណបើកបរមកក្រសួងមហាផ្ទៃមួយខែម្ដង។

**មាត្រាទី ៤០៖**

បណ្ណបើកបរជាតិសម្រាប់បើកបរយានយន្តក្នុងព្រះរាជាណាចក្រកម្ពុជាមាន ៥ (ប្រាំ) ប្រភេទដូចខាងក្រោម៖

**ប្រភេទ ក ទោចក្រយានយន្ត និងត្រីចក្រយានយន្តមាន៖**

**ក១.** ទោចក្រយានយន្តដែលមានទំហំស៊ីឡាំងចាប់ពី ៤៩ ដល់១២៥ សង់ទីម៉ែត្រគូប ឬទោចក្រយានយន្តប្រើប្រាស់ថាមពលអគ្គិសនី ដែលគ្មានឈ្នាន់ធាក់ដូចទោចក្រយាន។

**ក២.** ទោចក្រយានយន្តដែលមានទំហំស៊ីឡាំងលើសពី ១២៥សង់ទីម៉ែត្រគូប។

- ទោចក្រយានយន្តមានសណ្ដោង និងត្រីចក្រយានយន្ត។

**ប្រភេទ ខ រថយន្តដឹកអ្នកដំណើរមិនលើសពី ៩នាក់ ដោយគិតទាំងអ្នកបើកបរ៖**

- រថយន្តដឹកទំនិញដែលមានទម្ងន់សរុបអតិបរិមាលើសពី ៣,៥ តោន។
- រថយន្តក្នុងប្រអប់ខ នេះ អាចសណ្ដោងរ៉ឺម៉កដែលមានទម្ងន់សរុបអតិបរិមាមិនលើសពី ០,៧៥ តោន។

**ប្រភេទ គ៖** រថយន្តដឹកទំនិញដែលមានទម្ងន់សរុបអតិបរិមាលើសពី ៣,៥ តោន និងអាចសណ្ដោងរ៉ឺម៉កដែលមានទម្ងន់សរុបអតិបរិមាលើសពី ០,៧៥ តោន ។

**ប្រភេទ ឃ រថយន្តដឹកអ្នកដំណើរ ៖**

ឃ១ រថយន្តដឹកអ្នកដំណើរចាប់ពី ១០នាក់ ដល់ ២០នាក់ ដោយគិតទាំងអ្នកបើកបរ និងអាចសណ្ដោងរ៉ឺម៉កដែលមានទម្ងន់សរុបអតិបរមាមិនលើសពី ០,៧៥ តោន ។

**ប្រភេទ ង ៖** រថយន្តប្រភេទ ខ គ និង ឃ មានសណ្ដោងរ៉ឺម៉កដែលមានទម្ងន់សរុបអតិបរមាលើសពី ០,៧៥តោន ត្រូវចែកជាបីប្រភេទ គឺប្រភេទ ង (ខ) ប្រភេទ ង (គ) និង ប្រភេទ ង (ឃ) ។

(មានតនៅលេខក្រោយ)

# ទេវវិទ្យាល័យកម្ពុជា បានប្រកាសទទួលបេក្ខជន ប្រាក់ ប៊ុនហុង និងវិន កាន់ ជានិស្សិតផ្លូវការ


ថតដោយៈ លី ហៀង

ទេវវិទ្យាល័យព្រះសហគមន៍កាតូលិកកម្ពុជា នៅក្រុងភ្នំពេញ បានប្រកាសទទួលលោកប្រាក់ ប៊ុនហុង និងលោក វិន កាន់ ជានិស្សិតផ្លូវការនៅក្នុងថ្ងៃបើកឆ្នាំសិក្សាថ្មីនេះ ដើម្បីរៀន និង រិះគិតអំពីការត្រាស់ហៅរបស់ព្រះជាម្ចាស់ក្នុងជីវិតជាបូជាចារ្យ។

កម្មវិធីនេះធ្វើឡើង ក្រោមអធិបតីភាពរបស់លោកអភិបាលព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ អូលីវីយេ ដ្មឹតអឺស្លែរ លោកអន់តូនី សាមី ស៊ូសៃរាជ្យ អភិបាលនៃព្រះសហគមន៍ភូមិភាគកំពង់ចាម និងលោកបូជាចារ្យ ជានាយកទេវវិទ្យាល័យ ដោយមានអ្នកចូលរួមជាច្រើននាក់ កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧នេះ។

ទេវវិទ្យាល័យកម្ពុជាបានបើកទ្វារឡើងវិញក្នុងដើមទសវត្សឆ្នាំ១៩៩០ នៅបាត់ដំបង និងបានប្តូរមកភ្នំពេញក្នុងឆ្នាំ១៩៩៨។ ទេវវិទ្យាល័យជាកន្លែងអប់រំយុវជន ដើម្បីក្លាយជាបូជាចារ្យកាតូលិក។

ក្នុងធម្មទេសនាលោកអភិបាលអន់តូនីបានចែករំលែកនូវបទពិសោធន៍របស់លោកក្នុងនាមជាអភិបាលព្រះសហគមន៍ភូមិភាគកំពង់ចាម ព្រមទាំងបានទទួលការលើកទឹកចិត្តពីសម្តេចប៉ាបបេណេឌិកតូទី១៦ លោកបង្ហាញថា ការលំបាករបស់យើងមានឥទ្ធិពលច្រើនមកលើជំនឿ និងមានការលំបាកមិនអាចដោះស្រាយបញ្ហាផ្សេងៗបានទាំងអស់ក្តី តែត្រូវទុកចិត្ត និងឲ្យខិតខំព្យាយាមអធិដ្ឋាន ទោះបីជាមានការលំបាកក៏ដោយ សូមឲ្យយើងផ្ញើនូវរាល់ទុក្ខលំបាកទាំងនោះទៅព្រះជាម្ចាស់។

លោកអន់តូនី ក៏បានពន្យល់អំពីអត្ថន័យនៃធម៌ "ឱព្រះបិតា" ដែលគ្រីស្តបរិស័ទបានទទួលពីព្រះយេស៊ូ ហើយសូត្រសព្វថ្ងៃដើម្បីឲ្យយកចិត្តទុកដាក់ទទួលកម្លាំងពីព្រះជាម្ចាស់ និងឲ្យចេះលើកលែងទោសឲ្យអ្នក។

លោកបប់ ពីសេ នាយកទេវវិទ្យាល័យ បានស្នើសុំលោកអភិបាល ដើម្បីទទួលលោក ប្រាក់ ប៊ុនហុង និងលោក វិន កាន់ ជានិស្សិតទេវវិទ្យាល័យជាផ្លូវការ ឬអាចហៅថាជាកូនសិស្សលោកអភិបាលពេញសិទ្ធិ។ លោកបញ្ជាក់ថាបងប្រុស បានរៀននៅទេវវិទ្យាល័យបីឆ្នាំកន្លងមក គាត់បានរិះគិតអំពីការត្រាស់ហៅរបស់ព្រះជាម្ចាស់ និងត្រៀមខ្លួនចូលឆ្លើយតបទៅនឹងការត្រាស់ហៅនេះដោយមានទាំងចំណេះដឹង និងកាន់អប្បកិរិយាមាយាទត្រឹមត្រូវ។ លោកក៏បានស្នើឲ្យគ្រីស្តបរិស័ទ បន្តអធិដ្ឋាន សម្រាប់និស្សិតទេវវិទ្យាល័យទាំងអស់ផងដែរ។

លោក ប្រាក់ ប៊ុនហុង ជាបេក្ខជនមកពីព្រះសហគមន៍ មណ្ឌលគិរី ក្នុងភូមិភាគកំពង់ចាម និងលោក វិន កាន់ មកពីភូមិភាគភ្នំពេញ។

លោកអូលីវីយេ និងលោកអន់តូនី បានប្រកាសសួរបេក្ខជនអំពីការស្ម័គ្រចិត្ត ដើម្បីថ្វាយជីវិតបម្រើព្រះសហគមន៍ និងប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ព្រោះតែស្រឡាញ់ព្រះយេស៊ូ ដោយបន្តទទួលការអប់រំ និងត្រៀមខ្លួនធ្វើជាបូជាចារ្យដើម្បីបម្រើភូមិភាគរៀងៗខ្លួន។

បន្ទាប់ពីបេក្ខជនទាំងពីររូប បានប្រកាសស្ម័គ្រចិត្ត តាមការសាកសួរខាងលើ លោកអភិបាលអូលីវីយេ និងលោកអភិបាលអន់តូនី បានយល់ព្រមទទួលបងប្រុសហុង និងបងប្រុសកាន់ឲ្យទៅជានិស្សិតផ្លូវការតាមប្រពៃណីរបស់ព្រះសហគមន៍កាតូលិក ដោយមានលិខិតស្នាមជាផ្លូវការ។

បេក្ខជន វិន កាន់ បានឲ្យដឹងអំពីគោលបំណង និងការតស៊ូដើម្បីទទួលការអប់រំជាបូជាចារ្យព្រោះ ជីវិតជាលោកបូជាចារ្យគឺ មានអំណរសប្បាយខ្លាំង មិនថាតាមលោកីយ៍ ឬខាងវិញ្ញាណនោះទេ។ លើសពីនេះទៅទៀត លោក កាន់ ចាប់អារម្មណ៍ខ្លាំងអំពីបូជាចារ្យ ដែលមានតួនាទីនាំសេចក្តីសុខសាន្ត ព្រះពរ និងការសង្គ្រោះរបស់ព្រះយេស៊ូដល់មនុស្សឯទៀតៗ។ បេក្ខជនរូបនេះបន្តថា បំណងជាបូជាចារ្យគឺ រស់នៅជាមួយព្រះយេស៊ូ ត្រូវអធិដ្ឋាន ស្រឡាញ់កិច្ចការព្រះសហគមន៍ និងបំពេញតួនាទីរបស់ខ្លួនឲ្យបានគ្រប់គ្រាន់ ដែលជាសញ្ញាដែលព្រះជាម្ចាស់កំពុងត្រាស់ហៅយើង។

ព្រះសហគមន៍កាតូលិក នៅកម្ពុជាបានខិតខំជួយយុវជនក្នុងការរិះគិតអំពីការត្រាស់ហៅនេះយ៉ាង ដើម្បីឲ្យហ៊ានសម្រេចចិត្តឆ្លើយតបទៅព្រះជាម្ចាស់តាមជំនឿរបស់ខ្លួន។ ដោយឡែកភូមិភាគភ្នំពេញបានខិតខំរៀបចំការអធិដ្ឋានសម្រាប់ការត្រាស់ហៅយុវជនជារៀងរាល់ខែ។ ជាក់ស្តែងការអធិដ្ឋាននេះបានផ្តល់នូវផលផ្លែ ដោយមានយុវនម្នាក់ថ្មី និងនិស្សិតចាស់៨នាក់ទៀតបានស្ម័គ្រចិត្តចូលទេវវិទ្យាល័យដើម្បីរិះគិតអំពីដំណើរជីវិតជាបូជាចារ្យ ក្នុងឆ្នាំ២០១៧-២០១៨នេះ។

*ដោយ ដាលីស*

# គ្រីស្តបរិស័ទ១៨និកាយទទួលទានអាហារសាមគ្គីរួមគ្នាដើម្បីមិត្តភាព និងសុខដុមនីយកម្ម

ក្រុមប្រឹក្សានៃក្រុមជំនុំ ក្រុមប្រឹក្សានៃព្រះវិហារ សហគមន៍គ្រីស្តបរិស័ទ ព្រះសហគមន៍កាតូលិក និងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ត នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ចំនួន១៨ ក្រុមបានមកជួបជុំ គ្នាទទួលទានអាហារសាមគ្គីរួមគ្នាដើម្បីមិត្តភាព និងសុខដុមនីយកម្ម អន្តរនិកាយ។ ពិធីនេះប្រព្រឹត្តទៅកាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧ នៅសណ្ឋាគារ ហ្គាឌិនស៊ីធី ភ្នំពេញ ក្រោមអធិបតីរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី ហ៊ឹម ឆែម រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា។

លោកអេដវើត ដោរ តំណាងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្តនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ក្នុងនាមអ្នករៀបចំកម្មវិធី បានថ្លែងថា លោកសូមស្វាគមន៍ បងប្អូនទាំងអស់ ដោយរីករាយ ដែលមកជួបជុំគ្នានៅថ្ងៃនេះ។ លោកក៏ អរគុណ ចំពោះការគាំទ្ររបស់ថ្នាក់ដឹកនាំក្រសួងធម្មការ និងសាសនាលើកិច្ចការនានាដើម្បីសុខដុមរមនានៅកម្ពុជា។ លោកថាគោលបំណងនៃការជួបជុំនៅថ្ងៃនេះគឺ ទទួលអាហាររួមគ្នា ចែករំលែកសេចក្តីស្រឡាញ់ ស្គាល់គ្នាកាន់តែជិតស្និទ្ធ និងជួយជ្រោមជ្រែងគ្នាទៅវិញទៅមក។

កិច្ចសន្ទនានានាជាអន្តរនិកាយ នៃគ្រីស្តបរិស័ទនៅកម្ពុជា តែងប្រារព្ធធ្វើឡើងក្នុងទម្រង់ផ្សេងៗគ្នា។ ក្នុងនោះក៏មានការជួបផ្ទាល់សំណេះសំណាល រវាងសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជណាចក្រកម្ពុជាផងដែរ។




មានប្រសាសន៍ ក្នុងឱកាសនោះ ឯកឧត្តមទេសរដ្ឋមន្ត្រី ហ៊ឹម ឆែម រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា បានលើកឡើងថា គ្រប់ព្រះនៃសាសនាទាំងអស់សុទ្ធតែជួយឲ្យមនុស្ស រស់នៅក្នុងសន្តិភាពសុខដុមនីយកម្ម នៅលើផែនដីនេះ។

ឯកឧត្តម បន្តថា នៅថ្ងៃនេះយើងជួបជុំគ្នានៅទីនេះមិនមែនត្រឹមតែទទួលទានអាហារនោះទេ តែដើម្បីកសាងសន្តិភាពសុខដុមនីយកម្ម តាមការប្រៀនប្រដៅរបស់ព្រះយេស៊ូ ជាព្រះរបស់បងប្អូន។ ក្នុងលោកយើងនេះ មនុស្សអ្នកជឿទាំងអស់ស្រលាញ់សន្តិភាព។ គ្មានអ្វីប្រសើរជាងសន្តិភាពទេ។ កម្ពុជាមានពិសោធន៍សង្គ្រាម យ៉ាងជូរចត់ហើយ។ គ្មានទេពេលវេលាជួបជុំគ្នាដូចថ្ងៃនេះ។

ឯកឧត្តម ហ៊ឹម ឆែម ក៏បានអធិដ្ឋានបួងសួង ដល់ព្រះយេស៊ូ សូមឲ្យយើងទាំងអស់គ្នាបានពោរពេញដោយសន្តិភាព។ ចេះស្រលាញ់រាប់អានគ្នា និងរួមគ្នារក្សាសន្តិភាព និងសុខដុមនីយកម្មនៅកម្ពុជា។

# ពលកររួមគ្នាដើម្បីសិទ្ធិគ្រប់គ្រាន់នៅក្នុងការងារ



ថតដោយៈ សុវណ្ណភូមិ

នៅព្រះវិហារសនសិល្តា និងសន្តប៉ូល នៃមណ្ឌលសកម្មភាពភ្នំពេញថ្មី នៅកាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៧កន្លងទៅនេះគណៈកម្មការពលករ នៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានរៀបចំកម្មវិធីមហោស្រពពលករមួយដែលទាក់ទងទៅនឹងប្រធានបទ ពលកររួមគ្នាដើម្បីសិទ្ធិគ្រប់គ្រាន់នៅក្នុងការងារ ។

កម្មវិធីនេះមានការចូលរួមជាកិត្តិយសពីសំណាក់លោកអភិបាលអូលីវីយេ និងលោកបូជាចារ្យមួយចំនួន ដែលជួយនៅក្នុងគណៈកម្មការពលករ រួមនិងបងប្អូនកម្មករ កម្មការិនីប្រមាណជាង១០០នាក់ ហើយកម្មវិធីនេះមានគោលបំណងជួបជុំជាមួយបងប្អូនជាកម្មករ កម្មការិនីនៅតាមបណ្តារោងចក្រមួយចំនួននៅក្នុងរាជធានីភ្នំពេញ ដើម្បីឲ្យពួកគេមានឱកាសកម្សាន្តរួមគ្នា ចែករំលែកបទពិសោធន៍នៃជីវិតរស់នៅរបស់ពួកគេម្នាក់ៗ ដែលធ្លាប់បានជួបប្រទះក្នុងជីវិតរស់នៅប្រចាំថ្ងៃ។

លោកអូលីវីយេ ជ្មីតអឺស្លែរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញបានមានប្រសាសន៍លើកទឹកចិត្តកម្មករ កម្មការិនី ដែលចូលរួមកម្មវិធីនោះថា នេះជាឱកាសមួយសម្រាប់ព្រះសហគមន៍កាតូលិក ដើម្បីបង្ហាញពីការយកចិត្តទុកដាក់សម្រាប់កម្មករ ដែលសព្វថ្ងៃនេះ នៅប្រទេសកម្ពុជាមានកម្មករប្រមាណជា៨០ម៉ឺននាក់។ បើទោះបីព្រះសហគមន៍កាតូលិកគ្មានសកម្មភាពច្រើនក្តី ប៉ុន្តែព្រះសហគមន៍បានរៀបចំឲ្យមានមណ្ឌលមួយ សម្រាប់ទទួល និងជួយដល់កម្មករ កម្មការិនីខ្លះៗ ដែលធ្វើការតាមរោងចក្រ។ យើងមានក្រុមចលនាយុវកម្មករគ្រីស្តបរិស័ទ ដើម្បីប្រមូលកម្មករ កម្ម-ការិនី ដើម្បីរិះគិតអំពីតម្លៃនៃជីវិត ដើម្បីរិះគិតអំពីអត្ថន័យនៃការងារ និងរិះគិតអំពីជីវិតនកោររស់នៅជាក្រុមជាដើម។

លោកជីហ្វុង យ៉ាន ជាអ្នកទទួលខុសត្រូវគណៈកម្មការពលករ នៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានឲ្យដឹងថា មហោស្រពពលករ គឺជារួមគ្នារៀបចំឡើងដោយក្រុមកម្មករ ដែលភាគច្រើនពួកគេធ្វើការនៅតាមរោងចក្រ។ ចំពោះប្រធានបទនាឆ្នាំនេះ គឺពួកគេបានជ្រើសរើសប្រធានបទពលកររួបរួមគ្នាដើម្បីសិទ្ធិគ្រប់គ្រាន់នៅក្នុងការងារ។ ប្រធានបទនេះ គឺចង់ផ្ញើសារទៅដល់ថ្នាក់ដឹកនាំរោងចក្រ ត្រូវគោរពសិទ្ធិរបស់ពួកគាត់ដែលជាកម្មករ។ នេះហើយជាអ្វីដែលពួកគាត់ទាមទារ និងចង់បានសិទ្ធិគ្រប់គ្រាន់នៅក្នុងការងារ។

លោកឆោម សុជា អាយុ៣៣ឆ្នាំ ជាកម្មករនៅក្រុមហ៊ុនISI ក្នុងរាជធានីភ្នំពេញ ដែលបានចូលរួមកម្មវិធីនោះ បានចាប់អារម្មណ៍ថា កម្មវិធីជំនួបកម្មករ កម្មការិនីនាឱកាសនេះ គឺមានគោលបំណងជួយលើកទឹកចិត្តបងប្អូនកម្មករ ទាំងអស់ឲ្យមានការតស៊ូ និងចេះរួបរួមគ្នា ដោយស្វែងយល់អំពីច្បាប់ការងារផ្សេងៗ និងចេះតស៊ូមតិ ដោយចេះទាមទារសិទ្ធិការងារ របស់ខ្លួន ដូចដែលមានចែងក្នុងច្បាប់ការងារ នៃព្រះរាជាណាចក្រកម្ពុជាយើង។

គណៈកម្មការពលករ គឺជាគណៈកម្មការមួយ ដែលបានបង្កើតឡើងដោយព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ក្នុងគោលបំណង ជួយដល់បងប្អូនកម្មករ កម្មការិនី នៅតាមរោងចក្រមួយចំនួន ទាក់ទងទៅនឹងសិទ្ធិការងារ ការរួបរួមគ្នា និងការតស៊ូមតិ ដើម្បីឲ្យមានការគោរពសិទ្ធិ និងគោរពច្បាប់ការងារជាដើម។

ការិយាល័យគណៈកម្មការពលករ ស្ថិតនៅផ្លូវរុងរឿង១ ភូមិទួលពង្រ សង្កាត់ចោមចៅ៣ ខណ្ឌពោធិ៍សែនជ័យ មុំរោងចក្រដំបូលខៀវ៕

*ដោយ ឡុង សម្ផស្ស*

# ក្រុមគ្រួសារបងស្រី ព្រះមាលាត្រូវចាកចេញពីកម្ពុជា

ក្រុមបព្វជិតាបងស្រីព្រះមាលា បានបង្កើតឡើងក្នុងឆ្នាំ១៨៣២ នៅក្នុងប្រទេសបារាំងត្រូវបានរំលាយ ក្នុងឆ្នាំ២០១៧នេះ។ បងស្រីអាន ម៉ារីហ្គាលីស ជាអ្នកទទួលខុសត្រូវក្រុមគ្រួសារបងស្រីព្រះមាលានៅប្រទេសកម្ពុជាមានប្រសាសន៍ថា "ដោយសារតែក្រុមយើងមានតែមនុស្សចាស់ៗ នៅបារាំងអត់មានយុវនារីចង់បួសក្នុងក្រុមយើង ដូច្នេះក្រសួងបព្វជិត-ជិតានៅទីក្រុងរ៉ូមស្នើសុំឲ្យយើងបញ្ចប់សកម្មភាព"។ បងស្រី ឲ្យដឹងថា សព្វថ្ងៃនេះ នៅប្រទេសបារាំងមានសុទ្ធតែដូនជីចាស់ៗ "ហើយអ្នកដែលក្មេងជាងគេគឺខ្ញុំ និងបងស្រីម្នាក់ទៀត។ ខ្ញុំមានអាយុ៦៩ឆ្នាំហើយ ក្រៅពីនោះគេចាស់ជាងខ្ញុំច្រើនណាស់"។

ក្រុមគ្រួសារបងស្រីព្រះមាលា បានបំពេញបេសកកម្មនៅក្នុងទ្វីបអាស៊ី និងអាហ្វ្រិក។ ក្រុមគ្រួសារនេះ មានវត្តមាននៅប្រទេសកម្ពុជា ក្នុងឆ្នាំ១៩៩៣ និងធ្លាប់មានបេសកកម្មនៅក្នុងជំរំជនភៀសខ្លួននៅព្រំដែន ខ្មែរ ថៃជាច្រើនឆ្នាំ គឺបងស្រីហ្ស៊ីលបែត ម៉ាសុងជាបេសកជនដែលមកបំពេញកិច្ចការងារមនុស្សធម៌។

បងស្រីអាន ម៉ារី បានរៀបបន្តថា បេសកកម្មរបស់ក្រុមគ្រួសារបងស្រីព្រះមាលានៅតាមបណ្តាប្រទេសនីមួយៗគឺធ្វើតាមជំនាញ និងសមត្ថភាពរបស់ខ្លួនដើម្បីបម្រើព្រះជាម្ចាស់ និងព្រះសហគមន៍ក្នុងតំបន់។ កិច្ចការទាំងនោះរួមមាន អប់រំជំនឿ ធ្វើកិច្ចការងារក្នុងព្រះសហគមន៍ ធ្វើកិច្ចការមនុស្សធម៌នៅខាងក្រៅ ជួយដល់គ្រួសារក្រីក្រ និងកុមារឲ្យទទួលបានការសិក្សារៀនសូត្រជាដើម។

នៅក្នុងប្រទេសកម្ពុជាក្រុមបងស្រីព្រះមាលា មានសមាជិកចំនួន៣នាក់ គឺបងស្រីអានម៉ារីហ្គាលីស,បងស្រីហ្ស៊ីលបែត ម៉ាសុង ដែលជាជនជាតិបារាំង និងបងស្រីឃឹម សុខា ជាជនជាតិខ្មែរដែលក្មេងខ្ចី។ បងស្រីអានម៉ារីមានប្រសាសន៍ទៀតថា ពេលឮដំណឹងរំលាយក្រុមនេះ គាត់មានការឈឺចាប់យ៉ាងខ្លាំង។ បងស្រីអានម៉ារី ពោលទាំងក្រៀមក្រំថា "ឈឺចាប់មែនទែន ជាពិសេសចេញពីសុខា ដូចបោះចោលកូន សម្រាប់ខ្ញុំពិបាកៗ។ ប៉ុន្តែអ្វីដែលយើងកំពុងអធិដ្ឋានរាល់ព្រឹក( ក្នុងអភិបូជា )គឺអំពីរឿងលោកអប្រាហាំ។ ព្រះជាម្ចាស់ត្រាស់ហៅគាត់អាយុ១០០ឆ្នាំ គាត់ឆ្លើយបាទ។ ឥឡូវនេះ( ខ្ញុំ )ត្រូវនិយាយថា "ចាស"។ អ្វីដែលខ្ញុំដឹងគឺព្រះជាម្ចាស់ស្រឡាញ់ខ្ញុំ ព្រះជាម្ចាស់ស្រឡាញ់បងស្រីសុខា"។

ក្នុងប្រទេសកម្ពុជាក្រុមគ្រួសារបងស្រីបានបង្កើតអង្គការពន្លកថ្មី គឺជួយឧបត្ថម្ភដល់គ្រួសាក្រីក្រដើម្បីឲ្យកុមារទទួលបានការសិក្សានៅតាមសាលារដ្ឋ ជួយដល់កិច្ចការងាររបស់ព្រះសហគមន៍ក្នុងភូមិភាគភ្នំពេញ ជួយអប់រំជំនឿ និងធ្វើការសហការចងក្រងសៀវភៅអប់រំជំនឿសម្រាប់អ្នកឈ្វេងយល់ជំនឿ។

បងស្រីបន្តថា "ខ្ញុំត្រូវតែមានអំណរសប្បាយ និងមានសេចក្តីសង្ឃឹម និងត្រូវតែជឿទុកចិត្តលើព្រះជាម្ចាស់ ទោះបីព្រះជាម្ចាស់បានបិទក្រុមនេះក៏ដោយ តែព្រះអង្គមិនបិទការត្រាស់ហៅរបស់ខ្ញុំដែលព្រះជាម្ចាស់យកខ្ញុំទៅកន្លែងណាក៏ដោយគឺខ្ញុំឆ្លើយចាសនិងធ្វើតាម។ សូមបងប្អូនគ្រីស្តបរិស័ទទាំងអស់អធិដ្ឋានសម្រាប់ខ្ញុំ"។



ថតដោយៈ សុវណ្ណភូមិ

# ពិធីបញ្ចុះបឋមសិលា សាងសង់ព្រះវិហារថ្មី





ពិធីបញ្ចុះបឋមសិលា សាងសង់ព្រះវិហារថ្មីនៅព្រះវិហារសន្ត យ៉ូសែប ជុំគីរី នៃមណ្ឌលសកម្មភាពព្រះសហគមន៍កាតូលិកតំបន់កំពត។ ពិធីនេះបានប្រារព្ធឡើងក្រោមអធិបតីភាព របស់លោកអូលីវីយេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគ ភ្នំពេញ កាលពីថ្ងៃទី ១៥ ខែតុលា ឆ្នាំ២០១៧ កន្លងទៅ ដោយមានវត្តមានលោកបូជាចារ្យ និងគ្រីស្តបរិស័ទ ចូលរួមយ៉ាងច្រើនកុះករ។

ក្នុងធម្មទេសនា លោកអភិបាលបានមានប្រសាសន៍ថា៖ បងប្អូនជាថ្ម ដ៏មានជីវិត បងប្អូនជាកម្លាំង ដើម្បីឲ្យព្រះសហគមន៍យើងបន្តមានជីវិត ក្នុងអំណរសប្បាយរបស់ព្រះជាម្ចាស់។ លោកបន្តថាបន្តិចទៀតយើងប្រារព្ធពិធីបញ្ចុះបឋមសិលា ដោយមានថ្មរឹង ដែលភ្ជាប់ដោយស៊ីម៉ង់ត៍សម្រាប់អាគារ ដែលមេជាងនឹងសាងសង់។ ប៉ុន្តែយើងជាព្រះសហគមន៍ជាថ្មដ៏មានជីវិត និងភ្ជាប់ដោយ ស៊ីម៉ង់ត៍របស់យើងគឺ ដង្ហើមរបស់ព្រះជាម្ចាស់ ដែលជាសេចក្ដីស្រឡាញ់បងប្អូនទទួលពីព្រះវិញ្ញាណដ៏វិសុទ្ធណែនាំឲ្យព្រះសហគមន៍មានកម្លាំងដូចជាក្រុមគ្រីស្តទូតដែរ។

លោកអភិបាលបន្តថា នៅទៅនេះមិនទាន់មានព្រះវិហារអស់រយៈពេល២៥ឆ្នាំ តែព្រះសហគមន៍ មានកម្លាំង និងជីវិតរស់រវើក។ សូមបន្តកសាងនៅកន្លែងនីមួយៗ សូមលោកឪពុកជួយបន្ថែមទៀត។ ក្នុងពេលនោះ លោកអភិបាលក៏បានរំឭកយុវជនថា លោកឪពុកម្នាក់ឯងទៅមិនរួចទេ ដើម្បីធ្វើអ្វីៗទាំងអស់ សូមយុវជនចូលរួមទៅជាថ្មពិសេស ដើម្បីឲ្យព្រះសហគមន៍មានគង្វាលជាច្រើន និងបងស្រីច្រើនទៀតដែរ។

តាមប្រសាសន៍លោក ចនលូកា ជាបូជាចារ្យទទួលខុសត្រូវមណ្ឌលសកម្មភាពតំបន់កំពតបានឲ្យដឹងថា ព្រះវិហារថ្មីនេះមានទំហំ ១៤ម៉ែត្រ គុណនិង ២២ម៉ែត្រ ។ លោកថាការសាងសង់ អាចនឹងបញ្ចប់រួចរាល់ប្រហែលជាចុងឆ្នាំ២០១៨។

ព្រះសហគមន៍នៅជុំគីរី បានចាប់ផ្ដើមឡើងតាំងពីឆ្នាំ១៩៩៣ ដោយគ្រីស្តបរិស័ទដែលបានធ្វើមាតុភូមិនិវត្តន៍មកពីជំរំជនភៀសខ្លួន តាមបណ្ដោយព្រំដែនខ្មែរថៃ។ មកដល់ស្រុកកំណើត គ្រួសារគ្រីស្តបរិស័ទខិតខំអធិដ្ឋាន បង្ហាញជំនឿ និយាយអំពីព្រះយេស៊ូ ជួយអ្នកជំងឺក្នុងភូមិ ជួបជុំច្រៀងចម្រៀងអធិដ្ឋានជាមួយយុវជន កុមារ និងបងប្អូនដែលនៅជុំវិញ។បន្តិចម្ដងៗមានបងប្អូនចង់ស្គាល់ព្រះសហគមន៍។ គ្រួសារនេះបានទំនាក់ទំនងជាមួយបូជាចារ្យនៅភ្នំពេញ ដើម្បីជួយអប់រំជំនឿ។ ក្នុងដើមឆ្នាំ ២០០០ លោកបូជាចារ្យវិរៈជ័យ បានកសាងផ្ទះមួយដើម្បីជួបជុំគ្នា។ ផ្ទះនេះបានដាក់ឈ្មោះថា ព្រះវិហារសន្តយ៉ូសែប។

តាមប្រសាសន៍របស់លោកបូជាចារ្យ ចនលូកា សព្វថ្ងៃនេះព្រះសហគមន៍នេះមានជីវិតរស់រវើក មានសកម្មភាពជួយអ្នកក្រីក្រ មានក្រុមស្រ្តី មានថ្នាក់បង្រៀនភ្លេង មានសាលាមត្តេយ្យដែលមានសិស្សជាច្រើន បានជួយយុវជនជាច្រើនឲ្យបន្តការសិក្សានៅមហាវិទ្យាល័យជាដើម។ លោកបន្តថា សព្វថ្ងៃដោយសារ សកម្មភាពមេត្តាករុណា មានបងប្អូនពីរភូមិទៀតបានកំពុង ទទួលការអប់រំជំនឿអំពីព្រះយេស៊ូ។

តាមការរៀបរាប់របស់លោកបូជាចារ្យ សព្វថ្ងៃព្រះសហគមន៍នេះមាន គ្រីស្តបរិស័ទប្រមាណជាង២០០នាក់ និងមានកុមារ យុវជន និងមនុស្សពេញវ័យកំពុង ទទួលការអប់រំជំនឿបន្តដែរ។ ក្នុងមួយឆ្នាំៗមានគូស្រករប្រមាណ៥គូ បានរៀបអាពាហ៍-ពិពាហ៍។ មានកូនង៉ែនថ្មីៗទទួលជ្រមុជទឹក ព្រមទាំងមានកុមារមួយចំនួនរៀនទទួលព្រះកាយព្រះគ្រីស្តផងដែរ ព្រោះពួកគេបានទទួលអគ្គសញ្ញាជ្រមុជទឹកតាំងពីតូចមក។

តាមលោកបូជាចារ្យចនលូកា កិច្ចការទាំងអស់ក្នុងព្រះសហគមន៍ ដែលមានជីវិតរស់រវើកនេះ គឺដោយសារព្រះឧបការគុណរបស់ព្រះជាម្ចាស់។ ពីព្រះសហ-គមន៍ដ៏តូចនេះ ក៏មានយុវជនរិះគិតអំពីការត្រាស់ហៅជាបូជាចារ្យ និងមានដូនជីមួយរូបកើតចេញពីកន្លែងនេះផងដែរ គឺបងស្រី ស្រី សុជាតិ ស្ថិតក្នុងក្រុមបងស្រីអ្នកស្រឡាញ់ព្រះឈើឆ្កាង។

# អ្នកណាស្ដាប់ព្រះបន្ទូលហើយអនុវត្តតាម អ្នកនោះមានសុភមង្គលហើយ ( បើកឆ្នាំសិក្សាសាលាយ៉ូស្ទីន )

"អ្នកណាស្ដាប់ព្រះបន្ទូលហើយអនុវត្តតាម អ្នកនោះមានសុភមង្គលហើយ" នេះជាប្រសាសន៍របស់លោកអូលីវីយេ ឆ្មីតអីស្លែរ ជាអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ ក្នុងធម្មទេសនា នៃអភិបូជាបើកឆ្នាំសិក្សាថ្មី ២០១៧-២០១៨ នៃសាលាអប់រំជំនឿសន្ត យ៉ូស្ទីន ឆ្នាំទីពីរ ជំនាន់ទី៣ កាលពីថ្ងៃទី១៤ តុលា ២០១៧ នៅព្រះវិហារ សន្តសិលា និងសន្តប៉ូល ភ្នំពេញថ្មី ដោយមាននិស្សិត និងលោកបូជាចារ្យ ដែលជាសាស្រ្តាចារ្យតាមមុខវិជ្ជានានាចូលរួមជាច្រើនកុះករ។

ក្នុងឱកាសនេះ លោកអភិបាល បានពន្យល់ណែនាំគ្រីស្តបរិស័ទដែលជានិស្សិតទាំងអស់ ឲ្យយកចិត្តទុកដាក់ស្ដាប់ និងអនុវត្តតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ ដោយលោកបានលើកឡើងនូវកម្មវិធីសិក្សានានារបស់សាលាសន្តយ៉ូស្ទីន សុទ្ធតែជាវិធីក្នុងការស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ ដូចជាសីលធម៌ព្រះសហ-គមន៍ ប្រវត្តិសាស្រ្តព្រះសហគមន៍ អភិបូជាជារៀងរាល់ព្រឹក និងរបៀបរស់នៅជាក្រុមជាដើម ។ល។

លោកអូលីវីយេ បញ្ជាក់ទៀតថា ក្នុងឆ្នាំសិក្សាថ្មីនេះ ជាពេលដែលយើងត្រូវយកចិត្តទុកដាក់ស្ដាប់ព្រះបន្ទូលបន្ថែមទៀត ដើម្បី ឲ្យខ្លួនយើងម្នាក់ៗ និងសាលារបស់យើងមានជីវិតរីកចម្រើនថែមទៀត និងជាពិសេសតាមរយៈទំនាក់ទំនងរបស់បងប្អូន។ ឲ្យអ្នកឯទៀតៗនៅជុំវិញ អាចស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានដែរ ជាពិសេសតាមរយៈបណ្ដាញសង្គមសម័យទំនើប។ យកចិត្តទុកដាក់ចំពោះក្រុមពន្លកថ្មី ដែលទើបតែទទួលអគ្គសញ្ញាជ្រមុជទឹក និងជួយឲ្យយុវជន យុវនារីយល់អំពីតម្លៃជីវិតនៃការត្រាស់ហៅហើយក្លាហានដើម្បីឆ្លើយតបចំពោះការត្រាស់ហៅនោះ។

កញ្ញា វ៉ាន់ នីផៃអេង ជានិស្សិតឆ្នើម និងជាគ្រូអប់រំជំនឿនៃព្រះវិហារ សន្តសិលា និងសន្តប៉ូល បានឲ្យដឹងថា រយៈពេលមួយឆ្នាំកន្លងផុតទៅ សាលាអប់រំជំនឿគ្រីស្តបរិស័ទ សន្តយ៉ូស្ទីន បានជួយច្រើនដើម្បីឲ្យនាងយល់អំពីគ្រីស្តសាសនាកាន់តែច្រើនឡើង ជាពិសេសជួយឲ្យនាងមានគំនិតថ្មីៗដើម្បីអប់រំជំនឿដល់ក្មេងៗ។ ផៃអេង បន្ថែមថា ក្នុងចំណោមមុខវិជ្ជាទាំងអស់ គឺនាងចូលចិត្តមុខវិជ្ជាជីវិតខាងផ្លូវវិញ្ញាណ ដោយមុខវិជ្ជានេះទាក់ទងខាងជីវិត និងការរស់នៅដែលជាទំនាក់ទំនងជាមួយអ្នកដទៃ និងជាមួយព្រះជាម្ចាស់។

សាលាអប់រំជំនឿ សន្ត យ៉ូស្ទីន បានបង្កើតឡើងនៅចុងឆ្នាំ២០១១ ដោយលោកអភិបាលអូលីវីយេ ឆ្មីតអីស្លែរ ដោយមានព្រះគម្ពីរវិទ្យា ប្រវត្តិសាស្រ្តព្រះសហ-គមន៍ ជីវិតខាងផ្លូវវិញ្ញាណ ទេវវិទ្យា គោលលិទ្ធិគ្រីស្តសាសនាតាមព្រះសហគមន៍កាតូលិក សីលធម៌ព្រះសគមន៍កាតូលិក ព្រមទាំងមានកម្មវិធីរិះគិតអំពីសង្គមតាមរយៈវាគ្មិននានា ជាពិសេសសាលាបានផ្ដល់ឱកាសឲ្យនិស្សិតបានចុះកម្មសិក្សាដើម្បីឈ្វេងយល់អំពីជីវិតព្រះសហគមន៍នៅតាមបណ្ដាប្រទេសមួយចំនួនផងដែរ។

*ដោយដាលីស*



ថតដោយ: អេន ហំ

# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាបើកឆ្នាំសិក្សាថ្មីសាលាអប់រំជំនឿសន្តយ៉ូស្វីន
# ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៧



អត្ថបទទី១៖ យអ ៤,១២-២១
ដំណឹងល្អ៖ លក ១១,២៧-២៧

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងបានស្តាប់ព្រះបន្ទូលមួយដ៏ល្អដើម្បីបើកឆ្នាំនេះ **"អ្នកណាស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ហើយអនុវត្តតាម គឺអ្នកនោះហើយដែលមានសុភមង្គលពិតមែន"**។ ព្រះយេស៊ូណែនាំឲ្យយើងជានិស្សិតសាលាសន្តយ៉ូស្វីន ឲ្យយើងយកចិត្តទុកដាក់៖

**ទីមួយស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់** កុំឲ្យយើងយល់ថាស្តាប់ព្រះបន្ទូលព្រះជាម្ចាស់តែនៅពេលចូលអភិបូជាប៉ុណ្ណោះ។ តាមពិតនៅក្នុងគ្រប់មុខវិជ្ជាដែលលោកឪពុកគ្រប់គ្នានឹងបង្រៀននៅឆ្នាំនេះ ជាឱកាសមួយដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ យើងយល់អំពីព្រះជាម្ចាស់តាមមុខវិជ្ជានីមួយៗនៅក្នុងជីវិតព្រះយេស៊ូនៅក្នុងព្រះសហគមន៍នៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធនៅក្នុងអគ្គសញ្ញាដែលខ្ញុំនឹងបង្រៀនជាព្រះជាម្ចាស់ដែលកំពុងនិយាយដល់យើងជាព្រះជាម្ចាស់ដែលកំពុងបំភ្លឺយើងតែម្តង។ លោកដាមីញាំងនឹងបំភ្លឺយើងអំពីសម្ព័ន្ធមេត្រីចាស់។ លោកឪពុកលីបង្រៀនសីលធម៌ គឺព្រះជាម្ចាស់មានព្រះបន្ទូលច្បាស់ហើយនៅក្នុងសីលធម៌នៅក្នុងរបៀបដែលយើងរស់នៅប្រចាំថ្ងៃ។ លោកឪពុកប៊ិប់បង្រៀនប្រវត្តិសាស្រ្ត គឺព្រះជាម្ចាស់មានព្រះបន្ទូលនៅក្នុងប្រវត្តិសាស្រ្តព្រះសហគមន៍ទាំងអស់។ ដូច្នេះសម្រាប់យើងដែលជានិស្សិតសន្តយ៉ូស្វីនយើងដឹងថារាល់ថ្ងៃសុក្រ ថ្ងៃសៅរ៍នៅពេលយើងជួបជុំគ្នា យើងស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដោយយកចិត្តទុកដាក់ស្តាប់មេរៀន គិតអំពីមេរៀនរបស់យើង រៀបចំសំណួររៀបចំចម្លើយរៀបចំប្រឡងយកចិត្តទុកដាក់អានសៀវភៅ ឬស្រាវជ្រាវតាមអ៊ីនធឺណែតថែមទៀត។ នៅក្នុងសន្តយ៉ូស្វីន ខ្ញុំឆ្លៀតឱកាសដើម្បីរំឭកដែរ នៅថ្ងៃសៅរ៍នៅពេលយើងមានអភិបូជាពេលព្រឹក ឬនៅថ្ងៃសុក្រពេលល្ងាចយើងមានអធិដ្ឋាននៅទីនេះជាឱកាសមួយដើម្បីជិតស្និទ្ធជាមួយព្រះជាម្ចាស់ និងដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ថែមទៀត។ នេះជាអ្វីដែលសន្តយ៉ូស្វីនប្រគល់ឲ្យយើងជារៀងរាល់អាទិត្យ កុំឲ្យយើងភ្លេចការសិក្សាអភិបូជាការអធិដ្ឋាន ដើម្បីឲ្យសាលារបស់យើងមានជីវិត និងរីកចម្រើនថែមទៀត។ មួយវិញទៀត កុំឲ្យយើងភ្លេចជីវិតជាក្រុមនៅពេលដែលយើងលាងចាននៅពេលយើងហូបបាយយើងរៀបចំក្រុមដើម្បីរិះគិតពីសំណួរនេះជាឱកាសមួយដែរដើម្បីស្តាប់គ្នាទៅវិញទៅមក និងម៉្យាងដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែរ។

**ចំនុចទីពីរយើងបានស្តាប់ព្រះជាម្ចាស់តាមរយៈជីវិតរស់នៅរបស់យើងជាប្រចាំថ្ងៃ**។ យើងត្រូវការសួរខ្លួនឯងថា **"ខ្ញុំជាគ្រីស្តបរិស័ទម្នាក់នៅព្រះសហគមន៍ប្រទេសកម្ពុជា ខ្ញុំជានិស្សិតនៃសាលាអប់រំជំនឿសន្តយ៉ូស្វីន តើខ្ញុំទទួលតួនាទីអ្វីខ្លះ តើខ្ញុំទទួលខុសត្រូវអ្វីខ្លះនៅក្នុងសង្គមបច្ចុប្បន្ននេះ?"** នេះជាអ្វីដែលយើងត្រូវការគិតពិចារណាដែរដើម្បីឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់អាចចូលនៅក្នុងសង្គមតាមរយៈយើងដែលស្តាប់និងចេះអនុវត្ត និងឲ្យបងប្អូនឯទៀតៗដែលមិនមែនគ្រីស្តបរិស័ទនៅក្នុងសង្គមនៅកន្លែងធ្វើការ អាចស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់តាមរយៈយើង។ យើងបានស្តាប់ ឧទាហរណ៍ខ្លះៗនៅក្នុងសំណួរទាក់ទងនឹងប្រទេសម៉ាឡេស៊ីនិងជាពិសេសយើងអាចគិតថែមទៀតនៅក្នុងឆ្នាំនេះអំពីសំណួរមួយដ៏សំខាន់ **យើងរស់នៅមិនមែននៅក្នុងពិភពមួយដែលមានវប្បធម៌តែមួយប៉ុន្តែយើងរស់នៅក្នុងសង្គមនៅក្នុងសង្គមអន្តរវប្បធម៌។ យើងធ្វើដូចម្តេចដើម្បីឲ្យវប្បធម៌នីមួយៗអាចចូលជាមួយវប្បធម៌យើង មិនមែនដើម្បីបំផ្លាញវប្បធម៌យើង ប៉ុន្តែដើម្បីឲ្យវប្បធម៌យើងរីកចម្រើនថែមទៀត? ជាពិសេសនៅក្នុងតំបន់អាស៊ានរបស់យើងដែលមានដប់ប្រទេសតើយើងធ្វើយ៉ាងម៉េចដើម្បីរស់នៅយ៉ាងសមរម្យ? យ៉ាងសុខដុមរមនានៅក្នុងវប្បធម៌ដែលជាអន្តរវប្បធម៌?** ជាសំណួរមួយដែលយើងអាចសួរនិងយើងអាចធ្វើជាព្រះបន្ទូលរបស់ព្រះជាម្ចាស់សម្រាប់សញ្ជាតិនានាដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជា ដើម្បីរស់ជាមួយគ្នាយ៉ាងសុខសាន្ត។

អំពីអន្តោរប្រវេសន៍ យើងបានដឹងមាននៅប្រទេសម៉ាឡេស៊ីនៅក្នុងប្រទេសកម្ពុជាក៏មានច្រើន។ សាលាសន្តយ៉ូស្វីន ត្រូវគិតដើម្បីទទួលស្វាគមន៍ជនបរទេសដែលជួបជាប្រចាំនៅកន្លែងធ្វើការ និងកន្លែងយើងនៅ។ លើសពីនេះទៀតយើងគិតអំពីកម្មករមួយលាននាក់ ដែលកំពុងធ្វើការនៅប្រទេសកម្ពុជា ក្នុងនោះមានគ្រីស្តបរិស័ទតិចណាស់។ ខ្ញុំគិតថាព្រះសហគមន៍របស់យើងមានសកម្មភាពស្ទើរមែនទែន ទោះបីយើងមានគណៈកម្មាការពលករសព្វថ្ងៃ។ **ប៉ុន្តែយើងអាចធ្វើអ្វីខ្លះ ដើម្បីឲ្យពលករអាចស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់បាន?** អ្វីដែលខ្ញុំកំពុងនិយាយ ខ្ញុំសង្ឃឹមអាចទៅជាគំនិតសម្រាប់គម្រោងការប្រកាសដំណឹងល្អដែលយើងរៀបចំនៅខាងមុខ។

យើងត្រូវការគិតអំពីការអប់រំយុវជន ខ្ញុំមិននិយាយតែអំពីក្រុមយុវជននៅក្នុងព្រះសហគមន៍កាតូលិកប៉ុណ្ណោះ គឺទាំងនៅក្នុងសង្គមដែលប្រែប្រួលលឿនទំនើបដែលប្រើបណ្តាញទំនាក់ទំនងសង្គម(Social Media) ក្នុងនាមយើងជាគ្រីស្តបរិស័ទអាចជួយអប់រំពួកគេយ៉ាងណា។ ខ្ញុំគិតថាជាមួយស៊ីអេសស៊ី ប៉ុន្តែជាមួយយើងដែរអាចរៀបចំវីដេអូខ្លីៗ មួយនាទីពីរនាទីអំពីប្រធានបទមួយដែលទាក់ទងនឹងយុវជន ហើយបង្ហោះនៅក្នុងហ្វេសប៊ុក យូធូប ដើម្បីអប់រំអំពីជីវិតប្រចាំថ្ងៃ អំពីសីលធម៌ អំពីគ្រឿងញៀន អំពីអ្វីៗទាំងអស់ដែលយើងមើលឃើញសព្វថ្ងៃជាបញ្ហាយ៉ាងធំនៅក្នុងសង្គមរបស់យើង ដើម្បីឲ្យព្រះបន្ទូលព្រះជាម្ចាស់ទៅដល់គេដែរ។

អំពីការការពារបរិស្ថាន ក៏ជាតួនាទរបស់ជាគ្រីស្តបរិស័ទ ប្រហែលលើសពីអ្វីៗទាំងអស់។ យើងដឹងថាព្រះជាម្ចាស់បានបង្កើតមនុស្សលោក និងធម្មជាតិ និងបានប្រគល់ឲ្យយើង។ ដូច្នេះយើងជាគ្រីស្តបរិស័ទត្រូវតែចូលនៅក្នុងសង្គមដើម្បីទៅជាសញ្ញាសម្គាល់នៃវត្តមានព្រះជាម្ចាស់ដើម្បីឲ្យបងប្អូនឯទៀតៗទទួលព្រះបន្ទូលដោយសារយើងដែរ។

**ចំនុចទីបី យើងទទួលតួនាទីមួយ ដើម្បីឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់អាចស្តាប់ឮថែមទៀតនៅក្នុងព្រះសហគមន៍ប្រចាំរបស់យើង**។ កុំឲ្យការអប់រំបន្ថែមរយៈពេល២ឆ្នាំនេះ មានព្រំដែនសម្រាប់យើងតែប៉ុណ្ណឹង ត្រូវនាំយកទៅឲ្យដល់ព្រះសហគមន៍នីមួយៗរបស់យើងផ្ទាល់ ធ្វើយ៉ាងម៉េចឲ្យព្រះសហគមន៍របស់យើងថែរក្សាឯកភាពគ្នាធ្វើយ៉ាងម៉េចដើម្បីឲ្យព្រះសហគមន៍របស់យើង អាចសម្រុះសម្រួលគ្នារួមជាមួយគ្នាជាធ្លុងតែមួយ ធ្វើយ៉ាងម៉េចដើម្បីឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់អាចអនុវត្តនៅក្នុងព្រះសហគមន៍យើងតែម្តង ដោយសារស្តាប់ស្រួលអនុវត្តពិបាកណាស់។

អំពីការត្រាស់ហៅដែរយើងជាព្រះសហគមន៍មួយត្រូវលើកទឹកចិត្តយុវជន ដើម្បីឲ្យគេយល់ថា ទោះបីឪពុកម្តាយគេមកពីពុទ្ធសាសនា ប៉ុន្តែឲ្យគេយល់ថា ជីវិតរបស់គេអាចទៅជាជីវិតមួយពិសេសដើម្បីបម្រើព្រះសហគមន៍អស់មួយជីវិត។ នៅក្នុងឆ្នាំនេះ អ្នកដែលរៀបការ និងអ្នកមានគ្រួសារសូមរិះគិតថែមទៀតថា **"គ្រួសារដ៏វិសុទ្ធជាអ្វី?"** ព្រះនាងម៉ារី សន្តយ៉ូសែបព្រះយេស៊ូប៉ុន្តែយើងក៏អាចទៅជាគ្រួសារគំរូនិងជួយណែនាំថែមទៀត។

**ចំនុចទីបួន ខ្ញុំអញ្ជើញបងប្អូនទាំងអស់ពិចារណាធ្វើយ៉ាងម៉េចដើម្បីជួយថែមទៀតបងប្អូនដែលទទួលពិធីជ្រមុជទឹកថ្មីៗមួយឆ្នាំទៅមួយឆ្នាំពន្លកថ្មីបាត់ច្រើនទៅៗ ដែលក្នុងមួយឆ្នាំៗ មានអ្នកជ្រមុជទឹកច្រើនទៅៗ** ប៉ុន្តែមនុស្សនៅបន្តបាត់ច្រើនទៅៗ។ ដូច្នេះខ្ញុំដែលជាគ្រីស្តបរិស័ទពីយូរហើយដែលកំពុងរិះគិត ដែលកំពុងជាគ្រីស្តបរិស័ទរឹងមាំនៅក្នុងជំនឿ នៅក្នុងសេចក្តីស្រឡាញ់ តើយើងធ្វើយ៉ាងណាដើម្បីទាក់ទាញ ដើម្បីស្រឡាញ់ដើម្បីណែនាំឲ្យពន្លកថ្មីបន្តរស់នៅក្នុងព្រះសហគមន៍ និងបន្តអធិដ្ឋាននៅជាប់ជាមួយព្រះជាម្ចាស់?

ដូច្នេះយើងគិតដើម្បីទទួលព្រះបន្ទូលនេះសម្រាប់ពេញមួយឆ្នាំ និងអនុវត្តរបៀបពិសេសសម្រាប់យើង **"អ្នកណាស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ហើយអនុវត្តតាម គឺអ្នកនោះហើយដែលមានសុភមង្គលពិតមែន"**។អាម៉ែន៕



លិខិតថ្វាយព្រះពរ

សូមព្រះជាម្ចាស់ប្រោសប្រទានពរជ័យ សិរីមង្គល មហាប្រសើរ ថ្វាយ ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង

**ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី**

ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

**ក្នុងឱកាសព្រះរាជពិធីគម្រប់ខួប ១៣ឆ្នាំ នៃការឡើងគ្រងរាជ្យសម្បត្តិ**

ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមព្រះរាជានុញ្ញាត ក្រាបបង្គំទូលថ្វាយនូវព្រះសព្ទសាធុការពរ

សូមព្រះអង្គ ទ្រង់ប្រកបដោយ ព្រះរាជសុខភាពល្អបរិបូណ៌

ព្រះកាយពលមាំមួន ព្រះបញ្ញាញាណវាងវៃ ព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា

ដើម្បីទ្រង់គង់ជាម្លប់ដ៏ត្រជាក់ និងសេចក្តីសុខក្សេមក្សាន្ត ដល់ប្រជានុរាស្ត្ររបស់ព្រះអង្គ ក្នុងការអភិវឌ្ឍប្រទេសកម្ពុជា

ឆ្ពោះទៅរកភាពសម្បូរសប្បាយ ចុំផ្តើងរុងរឿងជានិច្ចនិរន្តរ៍។

ក្រាបបង្គំទូលថ្វាយពី

ព្រះសហគមន៍កាតូលិកនៅកម្ពុជា